ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ដំណើរស្វែងរកយុត្តិធម៌នៅតែបន្តទៅមុខ

◆ សាក្សីបន្តផ្ដល់សក្ខីកម្មទាក់ទងខេត្តបាត់ដំបង និងស្រុកត្រាំកក់

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២០៩ ខែឧសភា ឆ្នាំ២០១៧

លេខ២០៩ ខែឧសភា ឆ្នាំ២០១៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ដំណើរស្វែងរកយុត្តិធម៌នៅតែបន្តទៅមុខ ........................................១

**ផ្នែកឯកសារ**

◆ កំណត់ហេតុប្រវត្តិរបស់ ដូត ញោ សមាជិកវរសេនាតូច៧០១ ............២

◆ ដំណើផយុវជន-យុវនារីបដិវត្តន៍ ..................................................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ២០ ឧសភា ជាថ្ងៃដែលនាំឲ្យមានការចងចាំ ..................................១៣

◆ ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជា .................២០

◆ ការសិក្សាអំពីរបបខ្មែរក្រហមជំរុញឲ្យស្រឡាញ់សន្តិភាព ....................២៣

◆ ប្រវត្តិជីតាខ្ញុំ ..........................................................................២៦

◆ ជីវិតកុមារីវ័យ៩ឆ្នាំក្នុងរបបខ្មែរក្រហម ........................................២៨

◆ អតីតកងនារី ៖ រៀបរាប់ជីវិតក្នុងរបបខ្មែរក្រហម រហូតមកដល់ .........៣០

◆ ដំណើរជីវិតយាយ វ៉ា ប៉ុក ឆ្លងកាត់របបខ្មែរក្រហម ........................៣២

◆ ហូរ ចូច រម្លឹកពីជីវិតរស់នៅក្នុងរបបខ្មែរក្រហម ..............................៣៦

◆ ការស្នួរនាំពីបទពិសោធជីវិតក្នុងរបបខ្មែរក្រហមរបស់សិស្ស ................៣៨

◆ ទន្លេជាជីវិត ...........................................................................៤២

◆ ការផ្លាស់ប្ដូរដ៏គួរឲ្យសោកស្ដាយ ...................................................៤៤

**ផ្នែកច្បាប់**

◆ សាក្សីបន្តផ្ដល់សក្ខីកម្មទាក់ទងខេត្តបាត់ដំបង និងស្រុកត្រាំកក់ .............៤៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ចំណាប់អារម្មណ៍របស់សិស្សានុសិស្សអំពីការសិក្សាប្រវត្តិសាស្ត្រ ..........៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ "សារាណីយ" ..........................................................................៥៧



ស្តូបតម្កល់អដ្ឋិធាតុនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ០២៩១ពម.៩៩

ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *ម៉ែន ពិចិត្រ, ផួន លីណា, លន់ ច័ន្ទសុចិត្រា, ឡាង ស្រីលក្ខណ៍, ផួន លីណា, ស៊ឹម ស្រីនីត, ធឿប សារឿត, លីអូនី គីដេស្តី, មីន សាណាស់, គ្រីស៊ីន ឡោ, ដាន់ សុផល* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ និង ឆេង វើង* ***អ្នកបកប្រែ*** ៖ *លន់ សុចិត្រា និង ឡាង ស្រីល័ក្ខ* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *សន ល័ក្ខ* **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org, www.truthcambodia.com**

# ដំណើរការស្វែងរកយុត្តិធម៌នៅតែបន្តទៅមុខ

ថ្មីៗនេះមានព័ត៌មានអំពីការផ្អាកជាអចិន្ត្រៃយ៍នៃដំណើរការជានីតិវិធីក្នុងការកាត់ក្តីរបស់ មាស មុត, អោ អាន និង យឹម ទិត ដោយសារតែការខ្វះខាតថវិកាដែលគឺជារឿងគួរឲ្យខកចិត្តសម្រាប់ប្រជាជនដែលចង់បានយុត្តិធម៌ ។ ការខកខានមិនបានពិចារណាលើច្បាប់ និងអង្គហេតុ គឺជារឿងមួយដ៏គួរឲ្យអស់សំណើចនៅក្នុងតុលាការ ។ ស្របពេលដែលកំពុងតែមានការខកចិត្តដោយសារតែព័ត៌មាននេះ ខ្ញុំក៏មានសេចក្តីទុកចិត្តដោយសារតែភាពជោគជ័យជាច្រើនរបស់តុលាការ ហើយដំណើងនេះក៏មិនមានការប៉ះពាល់ដល់សេចក្តីទុកចិត្តរបស់ខ្ញុំក្នុងការងារលើកកម្ពស់សិទ្ធិមនុស្ស យុត្តិធម៌ និង នីតិរដ្ឋនៅកម្ពុជានោះទេ ។

ដំណឹងនេះបានរាប់បញ្ចូលក្នុងភាពបរាជ័យ កំហុស និង ការវិនិច្ឆ័យមិនល្អជាច្រើន នៅក្នុងដំណើរការយុត្តិធម៌របស់ប្រទេសកម្ពុជា ។ យើងចំណាយពេលអស់ជាច្រើនឆ្នាំ ឬអាចថាច្រើនទសវត្សរ៍ ដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមនេះឡើង ហើយជនរងគ្រោះ និងជនដែលរស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើន រួមមានរូបខ្ញុំ និងម្តាយរបស់ខ្ញុំ (ដែលបច្ចុប្បន្នមានវ័យ៨៩ឆ្នាំ) បានមានការរំពឹងទុកយ៉ាងខ្ពស់ចំពោះតុលាការនេះ ។ គ្រួសាររបស់អ្នកដែលបានបាត់បង់ជីវិតបានងាកមករកតុលាការនេះដើម្បីស្វែងរកការពិត និងការទទួលស្គាល់ពីការបាត់បង់របស់ខ្លួន ។ ជនរងគ្រោះបានបែរមកតុលាការនេះដើម្បីស្វែងរកការទទួលស្គាល់ពីភាពឈឺចាប់របស់ខ្លួន ។ ចំណែកឯជនជាប់ចោទបានមើលមកតុលាការនេះដើម្បីស្វែងរកការកាត់ក្តីដោយយុត្តិធម៌ ក៏ដូចជាឱកាសដើម្បីដោះសារ និងការពារខ្លួនដែរ ។ បើទោះបីជាស្ថាប័ននេះមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ប្រទេសកម្ពុជា និងពិភពលោកយ៉ាងណាក៏ដោយ ក៏ការចោទប្រកាន់អំពីអំពើពុករលួយ និងភាពចម្រូងចម្រាស់ផ្សេងៗនៅតែកើតមានឡើង ដែលបង្កឲ្យមានការប៉ះពាល់ដល់ភាពស្របច្បាប់នៃស្ថាប័ន និងដំណើរការយុត្តិធម៌ ។

ការពិត គឺជាអ្វីដែលប្រកបដោយពិសិដ្ឋភាព ហើយដំណើរការស្វែងរកការពិត ត្រូវតែទទួលបានការគោរព និងមានតម្លា



សម្តេចព្រះមហាក្សត្រីយ៍ នរោត្តម មុនីនាថ សីហនុ រាជានុញ្ញាតឲ្យម្តាយរបស់លោក ឆាំង យុ ឧបាសិកា កែវ ណាន លោក ឆាំង យុ និងចៅរបស់លោក ឆាំង យុ សារខាន់ មុន្នីពង្ស ចូលគាល់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧

ភាព ។ ខ្ញុំមានអារម្មណ៍សោកស្តាយចំពោះព័ត៌មាននេះ ពីព្រោះសារសំខាន់ដ៏ពិសិដ្ឋនៃការពិត ត្រូវបានបូជានៅលើអាសនៈនៃការចំណាយថវិកាដ៏ច្រើនលើសលុប ។ ការបកស្រាយពីកង្វះខាតផ្នែកហិរញ្ញវត្ថុ មិនមានតម្លៃអ្វីឡើយចំពោះស្ត្រីម្នាក់ដែលចង់ដឹងថា តើហេតុអ្វីបានជាគាត់បាត់បង់មនុស្សជាទីស្រឡាញ់នៅក្នុងរបបខ្មែរក្រហម ឬក៏អាចជួយឲ្យក្មេងជំនាន់ក្រោយជាច្រើនយល់ពីមូលហេតុដែលពួកវាគ្មានជីដូនជីតានឹងគេ ។ ការពិត គឺមិនគ្រាន់តែការងាយស្រួលនោះទេ ប៉ុន្តែវាជាឧត្តមគតិដែលជំរុញឲ្យយើងធ្វើនូវរឿងដែលត្រឹមត្រូវ បើទោះបីជាកាលៈទេសៈផ្នែកនយោបាយ ឬហិរញ្ញវត្ថុធ្វើឲ្យការសម្រេចចិត្តមានភាពលំបាកក៏ដោយ ។

បើទោះបីជាខ្ញុំមានការសោកស្តាយយ៉ាងនេះក្តី ក៏ខ្ញុំមានសេចក្តីទុកចិត្តដោយសារតែភាពជោគជ័យជាច្រើនរបស់តុលាការនេះដែរ ហើយព័ត៌មានយ៉ាងនេះ ក៏មិនបានរាំងស្ទះការជឿជាក់របស់ខ្ញុំចំពោះសមត្ថភាពរបស់ប្រជាជនកម្ពុជា ក្នុងការឆ្ពោះទៅមុខដើម្បីយុត្តិធម៌ ។

តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម គឺជាកត្តាដ៏សំខាន់ក្នុងការជំរុញឲ្យមានការជជែកពិភាក្សា ក៏ដូចជាការផ្សះផ្សាប្រទេសជាតិទាំងមូលជាមួយនឹងអតីតកាលមួយរបស់ខ្លួន ។ ជាក់ស្តែង តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម បានជំរុញឪពុកម្តាយឲ្យពិភាក្សាជាមួយកូនចៅរបស់ខ្លួនអំពីប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ហើយវាក៏បានជំរុញយុវជនឲ្យសួរសំណួរត្រិះរិះពិចារណាអំពីតួនាទីរបស់រដ្ឋាភិបាល សិទ្ធិមនុស្ស និងអាជ្ញាធរ ។ ខ្ញុំជឿជាក់ថា ប្រសិនបើគ្មានតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមទេនោះ ប្រជាជនជាច្រើនប្រហែលជាមិនជឿថា មានការកាប់សម្លាប់រង្គាលដ៏សាហាវឃោរឃៅបានកើតឡើងនោះឡើយ ។

តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម បានឲ្យតម្លៃចំពោះរឿងរ៉ាវរបស់ជនរងគ្រោះ ហើយបង្ហាញពីឧត្តមភាពនៃអរិយធម៌ ដែលខ្ពង់ខ្ពស់ជាងភាពអមនុស្សធម៌ ។ គ្មានសំណងសម្រាប់ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ណាដែលប្រសើរជាងការទទួលស្គាល់ពីភាពឈឺចាប់របស់គាត់ ការរំពុកពីអ្នកជាទីស្រលាញ់ដែលបានបាត់បង់ជីវិត និងសេចក្តីថ្លៃថ្នូរនៃភាពជាមនុស្សឡើយ ហើយក៏គ្មានសំណងសម្រាប់សិទ្ធិរបស់ជនជាប់ចោទនាថ្ងៃអនាគតណាដែលប្រសើរជាងការគោរពសិទ្ធិរបស់ជនជាប់ចោទនៅពេលបច្ចុប្បន្នដែរ ។ តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម គឺជាស្ថាប័នផ្នែកច្បាប់ដ៏គួរឲ្យគោរពមួយដែលផ្តល់សំឡេងដល់ជនរងគ្រោះ ព្រមទាំងផ្តល់ឱកាសដល់ជនជាប់ចោទដើម្បីបកស្រាយពីបទឧក្រិដ្ឋដែលខ្លួនត្រូវបានចោទប្រកាន់ ។

ប៉ុន្តែ ប្រព័ន្ធយុត្តិធម៌នៃតុលាការមួយនេះមិនអាចជំនួសឲ្យការសាកសួរផ្នែកប្រវត្តិសាស្ត្រ ការជជែកពិភាក្សា ឬការអប់រំបានឡើយ ហើយព័ត៌មានដែលបានដាក់ចេញនៅពេលនេះក៏ពុំអាចលុបបំបាត់ការទទួលខុសត្រូវរបស់ប្រទេសជាតិចំពោះជនរងគ្រោះនៃប្រវត្តិសាស្ត្រនេះ ឬក្មេងជំនាន់ក្រោយបានដែរ ។

យើងត្រូវតែទទួលយកដំណើរការ មេរៀន និងលទ្ធផលរបស់តុលាការនេះ ហើយប្រើប្រាស់បទពិសោធន៍ទាំងនេះដើម្បីធ្វើឲ្យសង្គមយើងកាន់តែមានភាពល្អប្រសើរ និងដើម្បីបន្តការងារដើម្បីយុត្តិធម៌របស់យើងតទៅមុខទៀត ។ ខ្ញុំជឿជាក់ថា បើទោះបីជាការងាររបស់តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ត្រូវបានបញ្ចប់នៅត្រឹមករណីនេះយ៉ាងណាក៏ដោយ ក៏គ្មានអ្វីអាចរាំងស្ទះដល់ក្រសួងយុត្តិធម៌របស់កម្ពុជាក្នុងការបន្តទទួលបន្ទុកចំពោះការទទួលខុសត្រូវនេះនៅថ្ងៃអនាគតដែរ ។ អ្វីដែលសំខាន់បំផុតនោះគឺ ការបិទសំណុំរឿង ឬការបញ្ចប់កិច្ចការងាររបស់តុលាការ ប៉ុន្តែវាមិនបានបញ្ឈប់ការទទួលខុសត្រូវរបស់យើងក្នុងប្រព័ន្ធយុត្តិធម៌ ឬ ការស្វែងរកការពិតនោះឡើយ ។

ការពិត គឺត្រូវតែមិនមែនជាអ្នកទោសម្នាក់នៃកាលៈទេសៈនយោបាយ ដំណើរការច្បាប់ទាំងឡាយ ឬក៏ពេលវេលានោះទេ ។ យើងមានកាតព្វកិច្ចក្នុងការឆ្លើយសំណួររបស់តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ដែលមិនទាន់មានចម្លើយរួមទាំងសំណួររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីបន្តការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រ ការជជែកពិភាក្សា និងការអប់រំ ។ យើងមិនត្រឹមតែមានកាតព្វកិច្ចចំពោះខ្លួនយើង ជនរងគ្រោះ ឬសង្គមយើងតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាកាតព្វកិច្ចរបស់យើងចំពោះពិភពលោកដែរ ដែលការងាររបស់យើងនឹងត្រូវបានចងចាំជាភស្តុតាងនៃនិទណ្ឌភាព ឬការតាំងចិត្តរបស់មនុស្សជាតិ ។ **ឆាំង យុ**

# កំណាត់ហេតុប្រវត្តិរបស់ ជូត ញេ សមាជិកវរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤ ភូមិភាគកណ្ដាល

*ដកស្រង់ចេញពីឯកសារលេខ D៤១២៦៨*

ជូត ញេ មានអាយុ២៨ឆ្នាំ (ក្នុងឆ្នាំ១៩៧៧) កើតនៅភូមិជ្រលង ឃុំជ្រលង ស្រុកតាំងគោក ខេត្តកំពង់ធំ ។ មុនអង្គការចាប់ខ្លួន ញេ ជាសមាជិកវរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤ ភូមិភាគកណ្ដាល ។ ញេ ត្រូវបានអង្គការចាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៧ ។ សេចក្ដីកំណត់ហេតុប្រវត្តិរបស់ ជូត ញេ ត្រូវបានធ្វើចប់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ ដោយអ្នកសួរឈ្មោះ ហម និង ដេន ព្រមទាំងមានចុះហត្ថលេខារបស់អ្នកទាំងពីរនេះទៀតផង ។ សេចក្ដីកំណត់ហេតុប្រវត្តិរបស់ ជូត ញេ សរសេរដោយដៃ មានចំនួន១៨ទំព័រ ដែលបានរៀបរាប់ពីសកម្មភាពរបស់ខ្លួនតាំងពីឆ្នាំ១៩៦៣ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។ ខាងក្រោមនេះ ជាសេចក្ដីសង្ខេបដែលដកស្រង់ចេញពីសេចក្ដីកំណត់ហេតុប្រវត្តិរបស់ ជូត ញេ ៖

ឆ្នាំ១៩៦៣-១៩៦៥ ញេ បានចូលរៀននៅសាលាបឋមសិក្សាវត្តជ្រលង ដល់ថ្នាក់ទី១១ ។ បន្ទាប់មក រៀនបន្តនៅសាលាបឋមសិក្សាវត្តថ្វា ឃុំតាងៀង ក្នុងស្រុកតាំងគោកដល់ថ្នាក់ទី៨ ។ លុះដល់ឆ្នាំ១៩៦៩ ញេ ក៏បានឈប់រៀន ហើយមកបួសនៅវត្តជ្រលងអស់រយៈពេលប្រាំពីរខែ ។ បន្ទាប់ពីបួសបានប្រាំពីរខែរួចមក ក៏បានសឹកពីបួសនៅក្នុងឆ្នាំ១៩៧០ ហើយមករស់នៅជាមួយឪពុកម្ដាយវិញជួយធ្វើស្រែនៅស្រុកកំណើត ។ នៅឆ្នាំ១៩៧២ ញេ បានសម្រេចចិត្តឈប់ធ្វើស្រែ ហើយប្រកបមុខរបររកស៊ីទិញ



អ្នកទោសដែលជាប់ឃុំឃាំង និងសម្លាប់នៅអតីតមន្ទីរសន្តិសុខស-២១ ឬ គុកទួលស្លែង (រូបថតៈ ទួលស្លែង)

មាន់ពីតំបន់រំដោះ យកទៅលក់នៅតំបន់ខ្មាំង គឺនៅបន្ទាយតាំងគោក ។ នៅពេលដើរលក់មាន់ ញេ បានជួបជាមួយបងជីទួតមួយរបស់ខ្លួន (ជាអតីតកូនជំទប់ឃុំជ្រលង) ធ្វើជាទាហាននៅបន្ទាយតាំងគោកមានឈ្មោះ ធាយ ។ ពេលនោះ ធាយ បានបបួល ញេ ឲ្យចូលធ្វើទាហាន តែ ញេ មិនទាន់យល់ព្រមចូលធ្វើជាទាហាននៅឡើយទេ ។ លុះក្រោយមក ធាយ បានអប់រំ ញេ ឲ្យធ្វើជាគិញឲ្យឈ្មោះ ស៊ីការនី ទាហានស័ក្តិប្រាំនៅបន្ទាយតាំងគោក ។ ពេលនោះ ញេក៏បានយល់ព្រមធ្វើជាគិញឲ្យ ស៊ីការនី ដោយបានទទួលភារកិច្ចបីចំណុចយកមកអនុវត្តគឺៈ

១) ស៊ើបការណ៍រកពួកខ្មែរក្រហមនៅឃុំជ្រលង

២) កសាងកម្លាំងគិញ

៣) ឃោសនាបំផុសប្រជាជនឲ្យប្រឆាំងពួកខ្មែរក្រហម ។

បន្ទាប់មក មានឈ្មោះ ហ៊ុយ (អតីតលោកសង្ឃ និងធ្វើជាគណៈឃុំជ្រលងនៅឆ្នាំ១៩៧៣), ឈ្មោះ អោក ប្រធានសន្តិសុខស្រុកតាំងគោកឆ្នាំ១៩៧៣ និងឈ្មោះ ឈុន សមាជិកឃុំជ្រលងក្នុងឆ្នាំ១៩៧៣ បានមកទាក់ទងជាមួយ ញេ ដើម្បីចេញចូលតាំងគោករកស៊ីជាមួយគ្នា ។ ក្រោយមក អ្នកទាំងបីត្រូវបានពួកទាហានរបស់ ស៊ីការនី ចាប់យកទៅប្រគល់ឲ្យ ស៊ីការនី ហើយបន្ទាប់មកទៀត ស៊ីការនី ក៏បានអប់រំអ្នកទាំងបីនេះឲ្យចូលបម្រើគិញជាមួយនឹង ញេ ដែរ ដើម្បីទាក់ទងសហការគ្នាធ្វើសកម្មភាពស៊ើបការណ៍រកអ្នកបដិវត្តន៍ ។ ក្រោយមក នៅពេលដែលកងទ័ពបានចូលទៅធ្វើការអប់រំប្រជាជននៅភូមិត្រពាំងឈូក ក្នុងឃុំជ្រលង ញេ បានទាក់ទងជាមួយ ហ៊ុយ ហើយទៅរាយការណ៍ឲ្យ ស៊ីការនី បានដឹងពីរឿងនេះ ពេលនោះ ស៊ីការនី ក៏បានខទ្មេសនាមឲ្យ ញេ ស្គាល់ខ្សែរយៈម្នាក់ទៀតឈ្មោះ ឈៀង ជាប្រជាជននៅភូមិអណ្តូងច្រុះ ។ បន្ទាប់ពីបានទទួលសេចក្តីរាយការណ៍ពី ញេ ហើយ ស៊ីការនី បានបាញ់ផ្លោងដាក់កងទ័ព និងប្រជាជននៅភូមិត្រពាំងឈូក ធ្វើឲ្យប្រជាជននៅភូមិនោះ ស្លាប់អស់មួយចំនួន និងឆេះផ្ទះប្រជាជនអស់ជាច្រើន ។ បន្ទាប់មកទៀត ញេ, ហ៊ុយ, អោក និង ឈុន បានបន្តធ្វើសកម្មភាពដោយនាំទាហានមកពីវត្តតាំងគោកចំនួន១២នាក់ មកត្រៀមចាំបាញ់កងទ័ពបដិវត្តន៍ដែលចុះធ្វើការនៅតាមភូមិជ្រលង បណ្តាលឲ្យស្លាប់កងទ័ពចំនួនពីរនាក់ និងប្រមូលយកអាវុធបានពីរដើម ។ នៅចុងឆ្នាំ១៩៧២ អង្គការមានវិធានការជម្លៀសប្រជាជនចេញពីឃុំជ្រលង ឲ្យទៅរស់នៅក្នុងឃុំស្រឡៅវិញ ព្រោះឃុំជ្រលងជាតំបន់ប្រទាញប្រទង់ ហើយនៅក្នុងពេលនោះដែរ ហ៊ុយ ត្រូវបានអង្គការចាត់ឲ្យធ្វើជាគណៈឃុំជ្រលង និងចាត់តាំង អោក ឲ្យធ្វើជាប្រធានឈ្លបឃុំជ្រលង ។

ឆ្នាំ១៩៧៣ អោក និង ហ៊ុយ បានចាត់តាំង ញេ ឲ្យចូលបង្កប់ខ្លួនក្នុងជួរកងទ័ពបដិវត្តន៍របស់តំបន់៤២ ហើយ ហ៊ុយ ក៏បានណែនាំឲ្យទាក់ទងភ្ជាប់ខ្សែ សេ.អ៊ី.អា ជាមួយឈ្មោះ សុង ជាគណៈបច្ចេកទេសយោធារបស់តំបន់៤២ (តែ ញេ មានតួនាទីធ្វើជាគិញដដែល) ។ បន្ទាប់មក សុង ក៏បានណែនាំ ញេ ឲ្យមកភ្ជាប់ខ្សែជាមួយឈ្មោះ វេង អនុប្រធានកងពល១១៧, ហង់ (ស្លាប់ឆ្នាំ១៩៧៨) និង សៀង ប្រធានយោធាស្រុកស៊ឹងគ្រន់ តំបន់៤២ និងខ្សែរបស់ខ្លួនពីរនាក់ទៀតឈ្មោះ ព្រែក លេខាវរសេនាតូច៧០៩ និង ឈ្មោះ លឿន (ស្លាប់) សម្រាប់ទាក់ទងធ្វើសកម្មភាព ។ ក្រោយមក ញេ, ព្រែក, លឿន និង សៀង បានចូលរួមទទួលផែនការពី សុង ឲ្យៈ

១) បំផុសយុទ្ធជនឲ្យរត់ទៅផ្ទះ និងមិនឲ្យយុទ្ធជនមានជំនឿទៅលើបដិវត្តន៍ ។

២) បំផ្លាញកម្លាំងបដិវត្តន៍ពេលចូលសមរភូមិ និងបំផ្លាញអាវុធ គ្រាប់រំសេវរបស់អង្គការ ។

ពេលយុទ្ធជនចូលសមរភូមិ ហើយមានការខ្វះខាតស្បៀង ញេ ក៏បានទាក់ទងជាមួយ ព្រែក និង លឿន ធ្វើសកម្មភាពនៅសមរភូមិកំពង់ចាមដោយលើកថា យុទ្ធជនពេលចូលសមរភូមិស្លាប់ដូចខ្មោចឆ្កែ ខ្មោចឆ្មា ពេលត្រូវរបួស ជួនណាគេទុកចោលក្នុងសមរភូមិជាដើម ធ្វើឲ្យយុទ្ធជនមានការខ្លាចសមរភូមិ រត់ទៅផ្ទះជាបន្តបន្ទាប់ ។

ឆ្នាំ១៩៧៤ វេង, ហង់ និង សៀង បានបញ្ចូល ញេ, លឿន និង ព្រែក ឲ្យចូលក្នុងខ្សែ សេ.អ៊ី.អា វិញ ហើយបានខទ្មេសនាមឲ្យអ្នកទាំងបីបានស្គាល់ និងទាក់ទងខ្សែ សេ.អ៊ី.អា មួយចំនួនមានឈ្មោះ សៃ អនុលេខាវរសេនាតូច៧០១, ស៊ិន លេខាវរសេនាតូចរបស់តំបន់៤១ របស់ភូមិភាគកណ្តាល, សៀ សមាជិកវរសេនាតូច, នា សមាជិកវរសេនាតូច៧០១ (ចាប់ហើយ) ។ ក្រោយពី វេង ខទ្មេសនាមហើយ ញេ, លឿន និង ព្រែក បានទាក់ទងជាមួយ

សៀ និង នា ធ្វើសកម្មភាព ពេលខ្មាំងបុកខ្សែត្រៀម បានបំផុសបំភ្លៃឲ្យយុទ្ធជនរត់ចោលខ្សែត្រៀម ធ្វើឲ្យខ្មាំងមើលឃើញ បាញ់យុទ្ធជនស្លាប់អស់៩នាក់ នៅសមរភូមិលអាន ខាងជើងកំពង់ចាម ។ បន្ទាប់មកទៀត ក្រោយពីទទួលផែនការពីអង្គការលើកទិសឲ្យវាយសមរភូមិព្រែកត្នោត ញេ និងបក្ខពួក មានភារកិច្ចស៊ើបការណ៍ ហើយបាននាំកងទ័ពបដិវត្តន៍ឲ្យដើរជាន់មីនរបស់ខ្មាំងស្លាប់អស់ចំនួន៥នាក់ទៀត ។ នៅខែធ្នូ ឆ្នាំដដែល ញេ ត្រូវរបួស ហើយបានទៅដេកពេទ្យតំបន់៤២ ក្នុងពេលនោះដែរ ញេ បានធ្វើសកម្មភាពបំផុសយុទ្ធជនដែលត្រូវរបួសដេកនៅពេទ្យជាមួយគ្នា ឲ្យខ្លាចសមរភូមិ ដោយលើកឡើងថា ពេទ្យបដិវត្តន៍ពេលយុទ្ធជនត្រូវរបួស មិនសម្បូរថ្នាំចាក់ដូចនៅពេទ្យទាហានទេ ចាក់ថ្នាំតែដដែលៗ ពេលយុទ្ធជនឈឺខ្លាំង ពេទ្យមិនសូវយកចិត្តទុកដាក់ទេ ។ ក្រោយពី ញេ បំផុសរួចមក យុទ្ធជនភាគច្រើនមិនព្រមចេញទៅសមរភូមិវិញទេ ។

ឆ្នាំ១៩៧៥ នៅពេលជាសះពីរបួស ញេ បានចេញពីពេទ្យ ហើយទៅអង្គភាពរបស់ខ្លួនវិញ ។ ពេលនោះ ញេ បានទៅទាក់ទងជាមួយ នួន និង ហៀង ធ្វើសកម្មភាពនៅខាងក្រោយ គឺបំផុសយុទ្ធជនឲ្យខ្លាចសមរភូមិ ។ ពេលដែលអង្គការលើកទិសវាយផ្ដាច់ក្រុងកំពង់ចាម វេង បានដាក់ផែនការឲ្យ ញេ និងបក្ខពួកអនុវត្ត គឺធ្វើយ៉ាងណាត្រូវបំផ្លាញផែនការរបស់អង្គការ ពេលវាយចូលក្រុងកំពង់ចាម និងបំផ្លាញកម្លាំងបដិវត្តន៍ ពេលចូលវាយសមរភូមិកំពង់ចាម ។ ក្រោយមក ពេលវាយដាច់ក្រុងកំពង់ចាម វេង បានចាត់តាំង ញេ, នួន, សៀ, ហៀន និង នឿន ឲ្យដុតឃ្លាំងគ្រាប់នៅក្រុងកំពង់ចាមឆេះអស់ពីរឃ្លាំង ។

ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ អង្គភាព៤០៨ បានផ្លាស់មកជាអង្គភាពវរសេនាតូចលេខ១១៣វិញ ដែលមានឈ្មោះ រៀប ជាលេខា ឈ្មោះ សែ ជាអនុលេខា និងឈ្មោះ នា និង ស៊ិន ជាសមាជិក ចំណែក វេង ទទួលនាទីជាលេខាវរសេនាតូចទី២ និងជាសមាជិកកងពលលេខ១១៧ ។ បន្ទាប់មក អង្គភាពរបស់ ញេ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើស្រែ ។ ពេលធ្វើស្រែ ញេ និងបក្ខពួក បានទទួលផែនការពីឈ្មោះ សែ នៅស្រុកកំពង់សៀម ឲ្យបំផ្លាញស្រូវរបស់អង្គការ, កសាងកម្លាំងប្រឆាំងនឹងបដិវត្តន៍ និងបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះ ។ ក្រោយពីបានទទួលផែនការរួចមក ញេ និងបក្ខពួក បានយកផែនការមកអនុវត្តដោយបំផុសយុទ្ធជនឲ្យរត់ទៅផ្ទះជាបន្តបន្ទាប់ ដោយឡែក នៅក្នុងអង្គភាពរបស់ ញេ យុទ្ធជនបានរត់ទៅផ្ទះអស់បីនាក់ ។ បន្ទាប់មក អង្គការបានដក វេង ឲ្យទៅទទួលគ្រប់គ្រងវរសេនាធំទី២ នៅកំពង់ធំ ។ មុនពេលផ្លាស់ទៅ វេង បានណែនាំបក្ខពួកមួយចំនួនឲ្យចាំទទួលផែនការពីឈ្មោះ រៀប លេខាវរសេនាធំ៦០១ (ចាប់ខ្លួនហើយ) ដើម្បីយកមកអនុវត្តបន្ត ។

ឆ្នាំ១៩៧៦ ញេ បន្តទាក់ទងរួមសកម្មភាពជាមួយខ្សែចាស់របស់ខ្លួន គឺធ្វើការបំផុសលើកពាក្យស្លោកវាយមាគ៌ារបស់បក្សដោយលើកថា «ធ្វើស្រែនឹងទឹកភ្លៀង ស៊ីបាយ ធ្វើស្រែនឹងប្រឡាយ ស៊ីបបរ» ពេលនោះយុទ្ធជនខ្លះត្រូវអសកម្មនឹងការងារដោយមិនបានសម្រេចកិច្ចការតាមផែនការដែលអង្គការបានដាក់ចុះ ។ បន្ទាប់មក អង្គការបានចាត់តាំងអង្គភាពវរសេនាតូច៧០១ ឲ្យទៅតាមដានចោរព្រៃនៅស្រុកព្រៃឈរ ។ ពេលនោះ រៀប បានចាត់តាំង ញេ, នួន និង ហឿន រួមជាមួយយុទ្ធជនចំនួន១០នាក់ផ្សេងទៀតទៅជាមួយ ។ រៀប បាននាំយុទ្ធជនទាំង១០នាក់ឲ្យទៅសម្រាកនៅព្រៃលួសក្នុងស្រុកកំពង់សៀម ហើយបានប្រាប់យុទ្ធជនទាំងនោះថា ខ្លួនទៅមើលភូមិសាស្ត្ររកចោរព្រៃ ។ បន្ទាប់មក រៀប បាននាំបក្ខពួកពីរបីនាក់ទៀត ស្កាត់ទៅជួបមេចោរព្រៃឈ្មោះ វិន ហៅ ម៉ាសុខុម ដើម្បីឲ្យស្គាល់គ្នាងាយស្រួលទាក់ទងគ្នា ហើយបានកំណត់ឲ្យ ញេ, នួន និង ហឿន មកទាក់ទងជាមួយមេចោរព្រៃឈ្មោះ វិន នេះ នៅព្រៃឡខ្សូងវេលាម៉ោងប្រាំល្ងាចដោយបង្វែងដានយុទ្ធជនទាំង១០នាក់ថា ដើរធ្វើការនៅតាមផ្លូវជាតិ ហើយឲ្យយុទ្ធជនត្រៀមតាមភូមិ ហើយ ញេ និងបក្ខពួកបានធ្វើសកម្មភាពជាមួយមេចោរព្រៃ វិន បាញ់ឡានចំនួនបីដងនៅតាមផ្លូវជាតិលេខ២៤ បាញ់លើកទីបីត្រូវអ្នកបើកបរស្លាប់ម្នាក់ ។ បន្ទាប់មក ញេ និង បក្ខពួកបានរួមជាមួយចោរព្រៃធ្វើសកម្មភាពប្លន់ប្រជាជននៅម៉ោង១២យប់ នៅភូមិត្រពាំងលាក់ បានបាញ់ប្រជាជនស្លាប់ម្នាក់ ប្លន់អង្ករបានពីរបាវ ហើយក៏បានប្រគល់អង្ករនោះទៅឲ្យមេចោរព្រៃឈ្មោះ វិន ។

ខែមិថុនា ឆ្នាំ១៩៧៦ អង្គការបានដកអង្គភាពវរសេនាតូច៧០១ ដែលទៅរកចោរព្រៃឲ្យមកធ្វើស្រែវិញនៅជិតភ្នំ ក្នុងស្រុកកំពង់សៀម ។ ពេលមកដល់ ញេ បានទទួលផែនការពី រៀប ឲ្យ ៖

១) រៀបចំកម្លាំងវាយអង្គការ ពេលបុណ្យខួបនៅខែកញ្ញា

ឆ្នាំ១៩៧៦ ។

២) បំផ្លាញស្រូវពេលធ្វើស្រែនៅរដូវវស្សា

៣) បន្តកសាងកម្លាំងប្រឆាំងនឹងបដិវត្តន៍ ។ ក្រោយពីទទួលផែនការហើយ ញ៉ េ បានទាក់ទងជាមួយឈ្មោះ អឿន និង ផុន តាមការខ្ទេសនាមរបស់ រៀប ឲ្យធ្វើសកម្មភាពបង្ហូរទឹកពន្លិចសន្ទូងរលួយខូចអស់បីហិកតា ។ ក្រោយមក ញ៉ េ កសាងកម្លាំងបានពីរនាក់ឈ្មោះ ឆុន និង ចាន់ ដោយបានលើកឲ្យអ្នកទាំងពីរមើលឃើញពីការលំបាកក្នុងសង្គមបដិវត្តន៍ ហើយទៅអនាគតនឹងមានការលំបាកកាន់តែខ្លាំងឡើយថែមទៀត ។

ខែសីហា ឆ្នាំ១៩៧៦ អង្គការបានដកអង្គភាពវរសេនាតូច ៧០១ ឲ្យទៅជួយធ្វើស្រែប្រជាជននៅភូមិវិហារធំ ក្នុងស្រុកកំពង់សៀម តំបន់៤១ ។ ញ៉ េ នៅរក្សាការទាក់ទងខ្សែរយៈ សេ.អ៊ី.អា ចាស់ដដែល ហើយបានសហការរួមធ្វើសកម្មភាពជាមួយ ផា និង សៀ បំផុសប្រជាជនដែលមានសមាសភាពជាទាហានចាស់ ឲ្យរត់ចូលព្រៃ ដោយឃោសនាបំភ្លៃថា អ្នកដែលមានសមាសភាពមិនល្អ អង្គការនឹងយកទៅកម្ទេចចោលមិនខាន ។ ពេលបំផុសហើយ មានប្រជាជនចំនួនប្រាំនាក់ បានសុខចិត្តរត់ចូលព្រៃ ហើយ ញ៉ េ បាននាំប្រជាជនទាំងប្រាំនាក់នោះ ទៅប្រគល់ឲ្យ វិន (មេចោរព្រៃ) នៅព្រៃអារោង ។ បន្ទាប់ពីបានទទួលអ្នកទាំងប្រាំនាក់ហើយ វិន បានស្នើមក ញ៉ េ វិញ ឲ្យជួយដោះស្រាយបញ្ហាស្បៀង ខោអាវ និងអាវុធ ។ ញ៉ េ បាននាំយកសំណើនេះ មករាយការណ៍ប្រាប់ដល់ នា និង សែ ឲ្យបានដឹងពីការស្នើសុំរបស់ វិន ។ ខែតុលា ពេលជួយស្ទូងស្រូវប្រជាជននៅភូមិវិហារធំរួចរាល់ហើយ អង្គការក៏ដកអង្គភាពរបស់ ញ៉ េ ឲ្យមកធ្វើស្រែនៅជិតភ្នំប្រុសភ្នំស្រី ដែលជាកន្លែងចាស់វិញ ពេលនោះ រៀប បានចាត់ ញ៉ េ និង ផា ឲ្យដឹកអង្ករចំនួនបីបាវ យកទៅប្រគល់ឲ្យ វិន តាមការស្នើសុំ ។ ក្រោយមកទៀតកងពល១១៧ ត្រូវទៅច្រូតស្រូវនៅកំពង់ធំ ។ នៅពេលដែលប្រជាជនចេញទៅច្រូតស្រូវអស់ពីភូមិ ឈ្មោះ នា និង សែ បានចាត់ ញ៉ េ និង នួន ឲ្យធ្វើសកម្មភាពដុតបំផ្លាញស្រូវនៅក្នុងលាន ឆេះអស់ប្រហែល៥០ថាំង ។ ពេលនោះ ដើម្បីកុំឲ្យអ្នកផ្សេងៗ មានការសង្ស័យមកលើខ្លួនជាអ្នកលួចដុត ញ៉ េ បានរត់ទៅហៅគេឯងឲ្យមកជួយពន្លត់ភ្លើង ។

នៅចុងឆ្នាំ១៩៧៦ ក្រោយពីបានទទួលផែនការហើយ រៀប បានចាត់តាំង ញ៉ េ ឲ្យទៅជិះរំគ្រើងក្នុងស្រុកកំពង់សៀម ។ ពេលនោះ ញ៉ េ មានភារកិច្ចការពារផ្លូវជាតិលេខ២៤ និងបានធ្វើការទាក់ទងជាមួយឈ្មោះ សែន ជាប្រធានពេទ្យប្រចាំជិះរំគ្រើង (ឆ្នាំ១៩៧៧ សែន បានរត់ទៅធ្វើជាចោរនៅព្រៃបឹងធំ ក្នុងស្រុកព្រៃឈរ) ហើយក៏បាននាំ សែន ឲ្យមកជួបជាមួយ រៀប ដើម្បីពិភាក្សាគ្នាលើកផែនការកសាងកម្លាំង សេ.អ៊ី.អា នៅតាមភូមិ ។ ពេលនោះ សែន បានណែនាំឲ្យអ្នកទាំងពីរបានស្គាល់កម្លាំងចោរព្រៃពីរនាក់មានឈ្មោះ ងួន និងឈ្មោះ ជឹម (អ្នកទាំងពីរត្រូវអង្គការចាប់ខ្លួនហើយ) ។ បន្ទាប់មក សែន បានធ្វើសកម្មភាពលួចអង្ករ របស់មន្ទីរពេទ្យគ្រើងចំនួនមួយបាវកន្លះ ហើយបានឲ្យ ញ៉ េ ជួយនាំអង្ករទាំងនោះទៅទុកនៅព្រៃបឹងធំ ។

ឆ្នាំ១៩៧៧ ញ៉ េ បានដាច់ការទាក់ទងជាមួយ សែន ដោយ សែន បានរត់ចូលក្នុងព្រៃបឹងធំ ។ បន្ទាប់ពីដាច់ការទាក់ទងជាមួយ សែនមក ញ៉ េ បានធ្វើការទាក់ទងជាមួយឈ្មោះ ផា, នួន, សៀ និង ហៀង ដែលជាខ្សែរយៈចាស់វិញនៅក្នុងអង្គភាពវរសេនាតូច ៧០១ ហើយបានរួមគ្នាទទួលផែនការពី រៀប ៖

១) កសាងកម្លាំង សេ.អ៊ី.អា

២) ពង្រឹងការទាក់ទងខ្សែ សេ.អ៊ី.អា ឲ្យកាន់តែខ្លាំង

៣) បន្តលាក់ស្រូវ អង្ករដើម្បីទុកចិញ្ចឹមចោរព្រៃ

៤) បំផ្លាញសន្ទូងពេលធ្វើស្រែ ។

ក្រោយពីបានដាក់ផែនការហើយ រៀប បានចាត់ ញ៉ េ ឲ្យទទួលនាទីជាសមាជិកវរសេនាតូច៧០១ ហើយបានណែនាំឲ្យធ្វើការទាក់ទងជាមួយឈ្មោះ វឿន អនុលេខាវរសេនាធំ៦០១ (ចាប់ខ្លួនហើយ) ដើម្បីចាំទទួលផែនការពេលដែល រៀប មិននៅ ។ ក្រោយពីបានទទួលការចាត់តាំងហើយ ញ៉ េ បានធ្វើការទាក់ទងជាមួយ វឿន ហើយតាមរយៈ វឿន នេះ បានណែនាំឲ្យ ញ៉ េ ធ្វើសកម្មភាពជាមួយឈ្មោះ សៀ ដែលជាកម្លាំងចាស់របស់ខ្លួន ហើយបានបំផុសយុទ្ធជននៅក្នុងអង្គភាពវរសេនាតូច៧០២ ឲ្យរត់ទៅផ្ទះអស់ចំនួន៥នាក់ ។ ខែមីនា ឆ្នាំ១៩៧៧ អង្គការបានចាត់អង្គភាពវរសេនាតូច៧០១ ឲ្យទៅតាមដានសកម្មភាពរបស់ពួកចោរព្រៃនៅក្នុងស្រុកព្រៃឈរ និងស្រុកចម្ការលើ ។ តាមរយៈការ

ងារនេះ រៀប បានចាត់កម្លាំងក្បត់របស់ខ្លួនមានឈ្មោះ នួន និង ញេ ឲ្យទៅតាមដានចោរព្រៃនៅស្រុកព្រៃឈរ រួមជាមួយយុទ្ធជនចំនួន ២០នាក់ និងចាត់ឈ្មោះ ផា រួមជាមួយយុទ្ធជន២០នាក់ផ្សេងទៀតដែរ ឲ្យទៅតាមដានចោរព្រៃនៅស្រុកចម្ការលើ ។ ក្រោយពីទទួលការចាត់តាំងហើយ នួន និង ញេ បាននាំកងទ័ព២០នាក់ទៅស្រុកព្រៃឈរ ហើយបានធ្វើសកម្មភាពបង្វែងដានកងទ័ពមិនឲ្យចូលកន្លែងឈ្មោះ វិន មេចោរព្រៃស្នាក់នៅទេ ។ ក្នុងសកម្មភាពតាមដាននេះទៀត ញេ បានចាប់ប្រជាជនចាស់ចំនួនពីរនាក់ដែលកំពុងកាប់ពោតនៅជិតភូមិបុសខ្នុរ ដោយចោទប្រកាន់ថា អ្នកទាំងពីរកាប់ពោតយកទៅចិញ្ចឹមពួកចោរព្រៃ ។ ពេលយប់ ញេ បាននាំកងទ័ពមកឈប់សម្រាកនៅតាមផ្ទះប្រជាជននៅភូមិបុសខ្នុរ ហើយបាននិយាយប្រាប់យុទ្ធជនថា ទៅធ្វើការនៅត្រើង តែតាមការពិត ញេ និង នួន បានចាត់កម្លាំងឲ្យទទួលខុសត្រូវបណ្ដោះអាសន្ននៅទីនេះ ហើយអ្នកទាំងពីរបានទៅទាក់ទងជាមួយឈ្មោះ វិន នៅព្រៃអាវេង ដើម្បីចង់ដឹងពីកម្លាំងរបស់ វិន ថាមានប៉ុន្មាននាក់ ហើយបានឲ្យ វិន ដឹកនាំកម្លាំងចេញប្លន់យកស្រូវអង្ករពីប្រជាជននៅភូមិព្រៃស្រឡាង ។ ក្នុងការតាមដានចោរព្រៃអស់រយៈពេលបួនខែ នួន និង ញេ បានធ្វើការបង្វែងដានយុទ្ធជនរហូត ហើយបានបើកឲ្យពួកចោរព្រៃធ្វើសកម្មភាពប្លន់ប្រជាជនជាបន្តបន្ទាប់ ។

នៅខែសីហា ឆ្នាំ១៩៧៧ អង្គការបានដក នួន និង ញេ ឲ្យមកនៅក្នុងអង្គភាព៧០១វិញ ពេលនោះ រៀប បានចាត់ឲ្យអ្នកទាំងពីរទៅធ្វើស្រែនៅវាសារិត និងបានដាក់ផែនការឲ្យអ្នកទាំងពីរគឺៈ

១) កសាងកម្លាំង សេ.អ៊ី.អា

២) បំផុសយុទ្ធជន និងប្រជាជន ឲ្យស្អប់អង្គការដើម្បីប្រមូលកម្លាំងក្បត់

៣) បំផ្លាញស្រូវ សន្ទូង

និង៤) ទាក់ទងខ្សែ សេ.អ៊ី.អា ក្នុងអង្គភាពវរសេនាធំ ៦០១ ដើម្បីរៀបចំកម្លាំងវាយអង្គការដឹកនាំ និងវាយយកឃ្លាំងអាវុធ គ្រាប់រំសេវនៅក្នុងក្រុងកំពង់ចាម ។ ក្រោយពីដាក់ផែនការហើយ រៀប បានប្រាប់បក្ខពួកបន្ថែមពីផែនការវាយបក្សនៅខែកញ្ញា ឆ្នាំ១៩៧៧ ។ ទីកន្លែង និងមុខសញ្ញាដែលត្រូវវាយ គឺត្រូវវាយយកក្រុងកំពង់ចាមមុនគេ ដើម្បីយកអាវុធ និងគ្រាប់រំសេវ ហើយបន្ទាប់មក វាយចេញមកពង្រីកយកដីក្នុងខេត្តកំពង់ចាមទាំងមូល រីឯកម្លាំងដែលត្រូវមករួមវាយប្រយុទ្ធនោះគឺ កម្លាំងមកពីសៀមរាប និងកំពង់ធំ ដោយត្រូវមកចាប់ដៃគ្នានៅផ្ដុំស្គន់ ហើយឈានទៅវាយយកទីក្រុងភ្នំពេញ ។ បើផែនការនេះមិនបានសម្រេចទេ ត្រូវរៀបចំកម្លាំងជាពីរផ្នែក ផ្នែកទីមួយត្រូវរត់ចូលសៀម ដើម្បីទាក់ទងកម្លាំងសៀមចូលមកវាយអង្គការទៀត ផ្នែកទី២ ត្រូវរៀបចំកម្លាំងបង្កប់ក្នុងអង្គភាពកងទ័ព និងបង្កប់តាមប្រជាជន ដើម្បីធ្វើសកម្មភាពកសាងកម្លាំង សេ.អ៊ី.អា សម្រាប់វាយបក្សនៅថ្ងៃមុខទៀត ។ បន្ទាប់ពីបានយល់ជ្រួតជ្រាបពីផែនការហើយ នួន និង ញេ បានចូលរួមធ្វើសកម្មភាពបំផ្លាញស្រូវ សន្ទូង អស់ប្រាំហិកតា ដោយលួចបើកទឹកឲ្យចូលស្រែពេលស្រូវកំពង់បែកគុម្ព ។ ក្រៅពីនេះទៀត អ្នកទាំងពីរ បានធ្វើសកម្មភាពទាក់ទងជាមួយឈ្មោះ ផុន ប្រធានយោធាកងធំ វរសេនាតូច៧០៤ វរសេនាធំ៦០១ កងពល១៧៤, អឿន អនុប្រធានកងធំ វរសេនាតូច៧០៤ វរសេនាធំ៦០១ កងពល១៧៤, ញាក់ សមាជិកកងធំ វរសេនាតូច៧០៥ វរសេនាធំ៦០១ កងពល១៧៤, ផា សមាជិកកងធំ វរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤, នួន អនុប្រធានកងធំ វរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤, ហឿន សមាជិកកងធំ វរសេនាតូច៧០១ វរសេនាធំ៦០១ កងពល១៧៤ ដើម្បីរៀបចំកម្លាំងវាយអង្គការ ។ នៅពេលកំពុងធ្វើសកម្មភាពរៀបចំទាក់ទងកម្លាំងវាយបក្ស ក៏ត្រូវអង្គការចាប់ខ្លួនតែម្ដង នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ។ **ឆេង ម៉េង**

## អានទស្សនាវដ្ដីតាមគេហទំព័រ

ទស្សនាវដ្ដីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ដំណឹងយុវជន-យុវនារីបដិវត្តន៍

***ដកស្រង់ចេញឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ៤ ខែមេសា ឆ្នាំ១៩៧៧ D២១៤០០***

*ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៧ ជាថ្ងៃខួបឆ្នាំទីពីរ នៃមហាជ័យជម្នះ ១៧ មេសា ដ៏មហាអស្ចារ្យ និងកំណើតកម្ពុជាប្រជាធិបតេយ្យដ៏រុងរឿង ។ យុវជន យុវនារីកម្ពុជា ទូទាំងប្រទេសទទួលអំណរបុណ្យខួបឆ្នាំទីពីរនេះ ក្នុងបរិយាកាសរំភើបរីករាយ សកម្មប្រយុទ្ធ និងស្មារតីប្រឡូងប្រណាំងគ្នា វាយសម្រុកសម្រេចភារកិច្ចនយោបាយឆ្នាំ១៩៧៧នេះ យ៉ាងក្លៀវក្លា មោះមុតបំផុត ។*

*ក្នុងឱកាសមហាមង្គល ទទួលអំណរខួបឆ្នាំទីពីរ នៃមហាជ័យជម្នះ១៧មេសា ដ៏មហាអស្ចារ្យ និងកំណើតកម្ពុជាប្រជាធិបតេយ្យ យុវជន យុវនារីកម្ពុជា ទាំងកងទ័ពបដិវត្តន៍ ទាំងកម្មករសហជីព ទាំងកសិករសហករណ៍ ទាំងយុវជន-យុវនារីក្រសួងមន្ទីរទាំងអស់នៅទូទាំងប្រទេស បានឡើងចាប់អារម្មណ៍ដោយក្តីរំភើបរីករាយឥតឧបមា ចំពោះមហាជ័យជម្នះ ដ៏ធំធេងលើគ្រប់វិស័យ របស់ប្រជាជាតិ-ប្រជាជនកម្មករ-កសិករសមូហភាពកម្ពុជាយើង និងកងទ័ពបដិវត្តន៍យើង ដែលទទួលបានក្នុងរយៈមួយឆ្នាំកន្លងទៅ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងត្រឹមត្រូវនៃបក្សកុម្មុយនីស្តកម្ពុជា ។ មិត្តយុវជន យុវនារីកម្ពុជាយើង សុទ្ធតែបានឡើងធ្វើសេចក្តីប្តេជ្ញាចិត្តយ៉ាងខ្ពង់ខ្ពស់ ថានឹងប្តេជ្ញាបន្តធ្វើពលិកម្មគ្រប់បែបយ៉ាង ប្រយុទ្ធវាយសម្រុកសម្រេចភារកិច្ចនយោបាយរួម និងភារកិច្ចស្នូលរបស់បក្សក្នុងឆ្នាំ១៩៧៧ ឲ្យបានជោគជ័យទាំងស្រុង ហើយនឹងលើសផែនការទៀត ។*

*តទៅនេះ សូមជូនការចាប់អារម្មណ៍ និងសេចក្តីប្តេជ្ញាចិត្តរបស់តំណាងយុវជនម្នាក់ៈ*



*កងសិល្បៈខ្មែរក្រហមកំពុងសម្តែងសិល្បៈពីជ័យជម្នះ ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥*

◆ សូមគោរពបក្ស ជាទីគោរព ។

◆ សូមគោរពបងៗ និងមិត្តទាំងអស់ជាទីគោរពស្នេហា ។

ថ្ងៃនេះ យើងខ្ញុំមានការរំភើបរីករាយយ៉ាងខ្លាំង ដោយមានកិត្តិយសបានមកចូលរួមក្នុងអង្គមីទីង និងរួមស្ដាប់បទទេសនាមរបស់តំណាងអង្គការបក្ស ក្នុងឱកាសទទួលអំណរខួបឆ្នាំទីពីរ នៃមហាជ័យជម្នះ១៧មេសា និងកំណើតនៃកម្ពុជាប្រជាធិបតេយ្យយើង ។

យើងខ្ញុំជាតំណាងឲ្យផ្នែកយុវជនទាំងអស់ ក្នុងមីទីងនេះ ក្រោយពីបានស្ដាប់ដោយយកចិត្តទុកដាក់នូវបទទេសនាម ដ៏ក្បោះក្បាយ ប្រកបដោយខ្លឹមសារតស៊ូវណ្ណៈជ្រាលជ្រៅនេះមក យើងខ្ញុំទាំងអស់គ្នា កាន់តែមើលឃើញច្បាស់ថែមទៀត នូវអត្ថន័យ និងតម្លៃនៃមហាជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ ដ៏ស្អាតបរិសុទ្ធ ហើយកាន់តែមានមោទកភាពបដិវត្តន៍ និងកាន់តែមានជំនឿជឿជាក់លើបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង ដែលបានប្រយុទ្ធពុះពារគ្រប់ឧបសគ្គ ដឹកនាំយើងខ្ញុំទាំងអស់គ្នា និងដឹកនាំប្រជាជនកម្ពុជាទូទាំងប្រទេស ធ្វើការតស៊ូបដិវត្តន៍រហូតដល់រំដោះប្រទេសជាតិ និងប្រជាជនកម្ពុជាយើង ពីខ្ញុំកញ្ជះចក្រពត្តិ និងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទ បានទាំងស្រុង បានទាំងអស់ និងជាស្ថាពរ ហើយបានវាយរំលំ គាស់រំលើងនូវវប្បធម៌សក្ដិភូមិ របបនាយទុន និងរបបឯកជន នៅក្នុងប្រទេសយើងបានជាមូលដ្ឋាន និងចាត់តាំងពង្រឹងពង្រីករបបសមូហភាព នៅទូទាំងកម្ពុជាប្រជាធិបតេយ្យយើង ព្រមទាំងកំពុងដឹកនាំយើងខ្ញុំទាំងអស់គ្នា និងប្រទេសជាតិកម្ពុជាទាំងមូល បន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសយ៉ាងជ្រាលជ្រៅ និងយ៉ាងផុសផុលខ្លាំងក្លាក្នុងពេលបច្ចុប្បន្ននេះ ។

យើងទាំងអស់គ្នា កាន់តែពេញចិត្តពេញថ្លើម និងកាន់តែមានជំនឿជឿជាក់ លើកម្លាំងមហាជន ប្រជាជន និងកងទ័ពបដិវត្តន៍ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានប្រពៃណីតស៊ូបដិវត្តន៍ ប្រឆាំងនឹងការជ្រៀតជ្រែក ឈ្លានពាន ជិះជាន់របស់ចក្រពត្តិ និងពួកវណ្ណៈជិះជាន់គ្រប់ប្រភេទ និងធ្លាប់មានប្រវត្តិលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត ទាំងមនោសញ្ចេតនា ទាំងកូនចៅប្ដីសឹរហូតដល់លះបង់សាច់ស្រស់ឈាមស្រស់ និងជីវិតដ៏ខ្ពង់ខ្ពស់ឧត្តមថ្លៃថ្លារបស់ខ្លួនទៀត ដើម្បីបុព្វហេតុរំដោះជាតិ រំដោះវណ្ណៈក្រីក្រ ។ ហើយបច្ចុប្បន្ននេះ កំពុងវាយសម្រុកប្រែក្លាយទឹកដីកម្ពុជាយើងឲ្យទៅជាអាងទឹក ព្រែកជីក ទំនប់ ប្រឡាយ ប្រព័ន្ធភ្លឺថ្មី រោងចក្រ ៗ ឲ្យកម្ពុជាប្រជាធិបតេយ្យទៅជាសួនស្រូវ និងសួនដំណាំយុទ្ធសាស្ត្រគ្រប់ប្រភេទ យ៉ាងស្រស់បំព្រង និងកំពុងប្រយុទ្ធយ៉ាងស៊ិតស្វាញការពារព្រំដែនគោក-ដែនទឹក-សមុទ្រ-កោះ របស់យើងឲ្យគង់វង្ស ស្ថិតស្ថេរ យ៉ាងល្អប្រសើរ ។

តាមពន្លឺនៃការទេសនាមនេះដែរ យើងខ្ញុំទាំងអស់គ្នាក៏បានជ្រួតជ្រាបកាន់តែច្បាស់ អំពីមហាជ័យជម្នះ របស់បក្សកុម្មុយនីស្តកម្ពុជា របស់ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជា ក្នុងរយៈពេលមួយឆ្នាំកន្លងទៅ ទាំងជ័យជម្នះលើភារកិច្ចធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេស គឺបក្សយើងបានដឹកនាំការតស៊ូ វាយកម្ទេចគណៈបញ្ជាការ និងខ្សែពួកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងអស់ជាមូលដ្ឋាន ដែលជាបច្ច័យយ៉ាងល្អប្រសើរបំផុត ដល់ចលនាបដិវត្តន៍សង្គមនិយម និងកិច្ចកសាងសង្គមនិយម នៅកម្ពុជាយើងទាំងមូល ។ ពោលគឺបក្សយើងបានពង្រឹង ពង្រីក ទីតាំងសមូហភាពបានជាទូទៅ នៅក្នុងសង្គមជាតិយើងទាំងមូល និងសម្រេចបានជ័យជម្នះ យ៉ាងធំធេងអស្ចារ្យ លើភារកិច្ចបង្កើនផលស្បៀង ពិសេសដំណាំស្រូវ ទោះបីជាពួកអាក្បត់វាវាំងរា និងបំផ្លិចបំផ្លាញយ៉ាងណាក៏ដោយ ដែលធ្វើឲ្យប្រជាជនទូទាំងប្រទេស អនុវត្តបានមួយរយភាគរយ នូវរបបហូបឆ្នាំ១៩៧៧ ដែលបក្សបានកំណត់ និងមានសល់ស្រូវរាប់សែនតោននាំចេញទៅលក់នៅក្រៅប្រទេសទៀត ។

យើងខ្ញុំទាំងអស់គ្នា សប្បាយរីករាយណាស់ ដោយឃើញអត្តភាព-កិត្យានុភាពជាតិយើង ល្បីរន្ទឺសុះសាយ និងលេចឡើងខ្ពស់ត្រដែតត្រដឹមលើឆាកអន្តរជាតិ ព្រមទាំងប្រជាជនសកលលោកកោតស្ញប់ស្ញែង ហើយគោរពរៀនសូត្រពីគំរូវីរភាពបដិវត្តន៍យ៉ាងខ្ពង់ខ្ពស់ ពីគំរូលះបង់ដោយគ្មានលក្ខខណ្ឌ និងពីគោលជំហរសមូហភាព ជំហរឯករាជ្យម្ចាស់ការដ៏រឹងប៉ឹងមាំមួន របស់ប្រជាជននិងកងទ័ពបដិវត្តន៍ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ ទន្ទឹមនេះ យើងខ្ញុំទាំងអស់គ្នា ក៏កាន់តែស្គាល់ និងមើលឃើញកាន់តែច្បាស់ នូវឧបាយកលពិសពុល ខ្មៅងងឹតរបស់ចក្រពត្តិអាមេរិក និងខ្មាំងសត្រូវគ្រប់ប្រភេទ ពិសេស

ខ្ទបាយកលវាយផ្តួលរំលំខាងគោលជំហរបដិវត្តន៍ ដើម្បីបំផ្លិចបំផ្លាញលទ្ធផល នៃមហាជ័យជម្នះរបស់យើង និងប៉ុនប៉ងវាយរំលំបដិវត្តន៍យើង ហើយដណ្តើមត្រួតត្រាលើប្រទេសជាតិយើងឡើងវិញ ។ តាមរយៈនេះ យើងខ្ញុំទាំងអស់គ្នា ក៏កាន់តែចាប់អារម្មណ៍ពីសកម្មភាព គ្រប់បែបយ៉ាងរបស់ពួកខ្មាំងបង្កប់ស៊ីរូង ដែលជាឆ្កែបម្រើចក្រពត្តិបរទេស គ្រប់ប្រភេទមានពួកភ្នាក់ងារ “ស.អ.អ” (សេ.អ៊ី.អា) “ក.ស.ប” (កា.ហ្សេ.បេ) និងពួកអាភ្នាក់ងារជាឆ្កែបម្រើ “យ”(យួន) លេបទឹកដី ដែលបង្កប់ស៊ីរូងផ្ទៃក្នុងប្រជាជន និងជួរបដិវត្តន៍យើង ។

យើងខ្ញុំទាំងអស់គ្នាឈឺចាប់ណាស់ ហើយចងគំនុំវណ្ណៈជារៀងរហូត ជាមួយចក្រពត្តិអាមេរិក បរិវារ និងពួកអាក្បត់ជាតិឯទៀតទាំងអស់ ហើយនឹងប្តេជ្ញាប្រែក្លាយកំហឹង និងគំនុំវណ្ណៈនេះ ឲ្យទៅជាជំហរប្រយុទ្ធជាក់ស្តែង ក្នុងការប្រយុទ្ធវាយសម្រុកបំពេញភារកិច្ចតូចធំទាំងអស់ ដែលបក្សប្រគល់ឲ្យ ឲ្យក្តៅ ឲ្យខ្លាំងក្លាបំផុត ដោយស្មារតីទទួលខុសត្រូវ និងដោយគោលជំហរឯច្ចប្រឌិត កសាងរស់រវើកជាប់ជានិច្ច តាមមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនរបស់បក្សកុម្មុយនីស្តកម្ពុជាយើង ។

◆ ប្តេជ្ញាគោរពរៀនសូត្រ នូវគំរូប្រយុទ្ធដាច់ខាត គំរូលះបង់លះបង់ដោយគ្មានលក្ខខណ្ឌ ដើម្បីបដិវត្តន៍ប្រទេសជាតិ និងប្រជាជន របស់មហាជនបដិវត្តន៍ ក្រោមការដឹកនាំរបស់បក្ស ឲ្យកាន់តែស៊ីជម្រៅខ្លាំងក្លាដាច់ខាត ។

◆ ប្តេជ្ញា លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ឲ្យខ្ពស់ជាប់ជានិច្ច ដើម្បីការពារបក្ស ការពារប្រជាជន ការពារទឹកដី ការពាររដ្ឋអំណាចបដិវត្តន៍ឲ្យបានគង់វង្សដាច់ខាត ។

◆ ប្តេជ្ញា បោសសម្អាតពួកភ្នាក់ងារ “ស.អ.អ” “ក.ស.ប” និងពួកភ្នាក់ងារឆ្កែបម្រើ “យ” លេបទឹកដី ដែលបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យស្អាតដាច់ខាត ។

◆ ប្តេជ្ញា ក្តាប់ឲ្យជាប់ និងអនុវត្តឲ្យបានល្អប្រសើ និងមានប្រសិទ្ធភាពបំផុត នូវមាគ៌ាធ្វើបដិវត្តន៍ សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសរបស់បក្សដាច់ខាត ។

◆ ប្តេជ្ញា ពង្រឹង-ពង្រីកមហាសាមគ្គីភាព ឯកភាពផ្ទៃក្នុងឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច ។

◆ ប្តេជ្ញា កម្ចាត់គោលជំហរអនុធន នាយទុន សក្តិភូមិ ព្រមទាំងកសិករ និងសិប្បករ ហើយបំពាក់ និងពង្រឹងគោលជំហរអធន



កងនារីបដិវត្តន៍ខ្មែរក្រហមកំពុងធ្វើការនៅតាមរោងចក្រ

របស់បក្ស ដាច់ខាត ។

◆ ប្តេជ្ញា វាយកម្ទេចកម្មសិទ្ធិ សួនតួ ខាងសម្ភារ សិទ្ធិអំណាច អាជ្ញា ខាងមុខមាត់ បុណ្យសក្តិនិយម នាម៉ឺននិយម ការិយាល័យនិយម ដាច់ខាត ។

◆ ជយោ បក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាង មហាអស្ចារ្យ ។

◆ ជយោ បដិវត្តន៍កម្ពុជា ដ៏ខ្លាំងក្លា មហាអស្ចារ្យ ។

◆ ជយោ ប្រជាជនកម្ពុជា ដ៏មហិមា មហាអស្ចារ្យ ។

◆ ជយោ កងទ័ពបដិវត្តន៍កម្ពុជា ដ៏អង់អាចក្លាហាន និងខ្លាំងពូកែ មហាអស្ចារ្យ ។

◆ ជយោ ខួបឆ្នាំទីពីរ នៃមហាជ័យជម្នះ ១៧ មេសា និងកំណើតកម្ពុជាប្រជាធិបតេយ្យដ៏រុងរឿង ។

នៅទីបញ្ចប់នេះ យើងខ្ញុំសូមជូនពរចំពោះបក្ស សូមឲ្យមានសុខភាពល្អបរិបូរ កម្លាំងមាំមួន ដើម្បីបន្តដឹកនាំយើងខ្ញុំទាំងអស់គ្នា ធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យបានកាន់តែខ្លាំងក្លា ជ្រាលជ្រៅថែមទៀត និងសូមជូនពរឲ្យបងៗ និងមិត្តទាំងអស់ មានសុខភាពបរិបូរ កម្លាំងខ្លាំងក្លាស្វាហាប់ ទស្សនៈ សតិអារម្មណ៍បដិវត្តន៍ភ្លឺស្វាង និងគោលជំហរប្រយុទ្ធមោះមុតស៊ិតស្វាញ ដើម្បីវាយសម្រុកបំពេញភារកិច្ចជូនបក្ស ឲ្យបានខ្លាំងក្លាជាប់ជានិច្ច និងសូមឲ្យទទួលបានជ័យជម្នះធំៗ ថ្មីៗ ទៀត លើគ្រប់ភារកិច្ចទាំងអស់ ។

### ការចាប់អារម្មណ៍ និងសេចក្តីប្តេជ្ញាចិត្តរបស់តំណាងនារី

◆ ជាដំបូង សូមគោរពបងតំណាងអង្គការបក្សជាទីគោរព ។

◆ សូមគោរពបងៗ និងមិត្តទាំងអស់ ជាទីស្នេហា ។

ថ្ងៃនេះយើងខ្ញុំទាំងអស់គ្នា ជាតំណាងផ្នែកខាងយុវនារី នៅក្នុងអង្គមីទ្ទីងទាំងមូល មានការរំភើប និងរីករាយឥតឧបមា ដោយបានចូលរួមធ្វើមីទ្ទីង ទទួលអំណរបុណ្យខួបឆ្នាំទីពីរ នៃមហាជ័យជម្នះ ១៧មេសា ដ៏មហាអស្ចារ្យ និងកំណើតកម្ពុជាប្រជាធិបតេយ្យយើងដ៏រុងរឿង ។

ក្រោយពីបានស្តាប់បទឧទ្ទេសនាមរបស់បងតំណាងអង្គការបក្ស ដែលមានខ្លឹមសារយ៉ាងជ្រាលជ្រៅបំផុតមក យើងខ្ញុំ តំណាងឲ្យយុវនារី រឹតតែមានមោទកភាពយ៉ាងខ្ពង់ខ្ពស់ និងមានជំនឿជឿជាក់យ៉ាងស្មោះត្រង់ចំពោះបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ហើយសូមធ្វើការចាប់អារម្មណ៍ដូចតទៅៈ

◆ យើងខ្ញុំបានយល់កាន់តែច្បាស់ថែមទៀត នូវអត្ថន័យយ៉ាងជ្រាលជ្រៅ នៃមហាជ័យជម្នះថ្ងៃ១៧ មេសា ដែលជាមហាជ័យជម្នះ មានលក្ខណៈជាប្រវត្តិសាស្ត្រ ដែលមិនធ្លាប់មានឡើយនៅក្នុងសង្គមកម្ពុជាយើងជាងពីរពាន់ឆ្នាំមកហើយ ។ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ នៃបក្សកុម្មុយនីស្តកម្ពុជាយើង មហាជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ គឺពិតជាបានមកពីការបូជាសាច់ស្រស់ ឈាមស្រស់របស់ប្រជាជន ពិសេសប្រជាជនក្រីក្រ និងកងទ័ពបដិវត្តន៍កម្ពុជា ធ្វើបដិវត្តន៍ និងធ្វើការតស៊ូវណ្ណៈយ៉ាងតឹងតែង ស៊ិតស្វាញ សន្ធោរសន្ធៅ រហូតដល់វាយកម្ទេចចក្រពត្តិអាមេរិក និងបរិវារអស់ពីទឹកដីកម្ពុជាយើង វាយកម្ទេច និងបោសសម្អាត វណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និងវណ្ណៈជិះជាន់គ្រប់ប្រភេទ អស់ទាំងស្រុង និងជាស្ថាពរពីក្នុងសង្គមកម្ពុជាយើង ។ ព្រមជាមួយនេះ យើងខ្ញុំបានឃើញនូវលទ្ធផលដ៏ល្អប្រសើរ ដែលយើងខ្ញុំទាំងអស់គ្នាក្នុងទីនេះ ព្រមទាំងប្រជាជន និងកងទ័ពបដិវត្តន៍យើង ក្រោមការដឹកនាំរបស់បក្ស យើងឯកភាពគ្នា បានប្រយុទ្ធកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ប្រយុទ្ធកម្ចាត់កម្មសិទ្ធិឯកជន និងប្រយុទ្ធកសាងប្រទេសយើង ឲ្យរីកចម្រើនគ្រប់ផ្នែកដោយល្បឿនមហាលោតផ្លោះ ថ្មីថែមទៀត នៅក្នុងឆ្នាំ១៩៧៦ កន្លងទៅនេះ ។ ទន្ទឹមនឹងមហាជ័យជម្នះ ដ៏ត្រចេះត្រចង់គ្រប់ផ្នែកនៅក្នុងប្រទេស យើងខ្ញុំក៏បានឃើញថែមទៀត នូវកិត្យានុភាព និងកិត្តិយសដ៏ខ្ពង់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាយើង របស់បដិវត្តន៍ប្រជាជន និងកងទ័ពបដិវត្តន៍យើង ដែលបានលេចធ្លោខ្ពស់ត្រដែតត្រដឹម និងកំពុងតែលេចត្រដែតត្រដឹមនៅលើសកលលោកថែមទៀតដែរ ។

◆ តាមបទឧទ្ទេសនាមដ៏មានខ្លឹមសារយ៉ាងជ្រាលជ្រៅនេះ យើងខ្ញុំទាំងអស់គ្នាបានយល់ និងបានឃើញកាន់តែច្បាស់ នូវឧបាយកលដ៏មានពិសពុល និងខ្មៅងងឹតរបស់ខ្មាំងសត្រូវ ទាំងនៅក្រៅប្រទេស ដែលប៉ុនប៉ងវាយរំលំបដិវត្តន៍កម្ពុជា ប៉ុនប៉ងលេបយកទឹកដីកម្ពុជាយើង និងខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងនៅក្នុងប្រទេស ដែលលក់ក្បាលយ៉ាងថោកទាបបំផុតឲ្យចក្រពត្តិគ្រប់ប្រភេទ ធ្វើជា

ភ្នាក់ងារ “ស.អ.អ” និង “ក.ស.ប” និងធ្វើជាខ្ញុំកញ្ជះ “យ” លេបទឹកដី ហើយប៉ុនប៉ងវាយផ្តួលខាងគោលជំហរបដិវត្តន៍ និងរាំងរាដល់ចលនាការពារ និងកសាងប្រទេសយើងបច្ចុប្បន្ននេះ មិនឲ្យលឿនលោតផ្លោះ ទៅមុខ ហើយរួមដៃជាមួយចក្រពត្តិគ្រប់ប្រភេទ ប៉ុនប៉ងវាយរំលំបដិវត្តន៍កម្ពុជា និងយកប្រទេសកម្ពុជាយើង ទៅធ្វើជាខ្ញុំកញ្ជះចក្រពត្តិបរទេសថែមទៀត ។ តាមរយៈនេះ យើងខ្ញុំកាន់តែលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ កម្រិតខ្ពស់បំផុត ប្រយុទ្ធកម្ទេចឲ្យអស់ នៅគ្រប់ឧបាយកលដ៏ខ្មៅងងឹត និងពិសពុលរបស់ខ្មាំងគ្រប់ប្រភេទ យើងប្តេជ្ញាប្រយុទ្ធការពារបក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យរបស់យើងដាច់ខាត ។

◆ ទន្ទឹមនេះ យើងខ្ញុំក៏បានឃើញយ៉ាងច្បាស់ នូវកម្លាំងមហាសាមគ្គីរបស់មហាជន ប្រជាជន និងកងទ័ពបដិវត្តន៍យើងទាំងមូល ដែលឯកភាពគ្នាជាធ្លុងមួយ ក្រោមការដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាយើង ប្រយុទ្ធការពារបក្សកុម្មុយនីស្តកម្ពុជាយើង និងការពារមាតុភូមិយើងដាច់ខាត ។ តាំងពីដើមរៀងមក មហាជន ប្រជាជន និងកងទ័ពបដិវត្តន៍យើង បានលះបង់អ្វីៗទាំងអស់ រហូតដល់លះបង់សាច់ឈាមស្រស់ និងអាយុជីវិតដ៏ថ្លៃថ្លា ដើម្បីការពារបក្សយើងដាច់ខាត និងដើម្បីបុព្វហេតុដ៏ឧត្តុង្គឧត្តម រំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះវណ្ណៈក្រីក្រ ។ ទាំងអស់នេះ ធ្វើឲ្យយើងកាន់តែមានមោទកភាព និងមានជំនឿជឿជាក់ លើកម្លាំងមហាជន ប្រជាជន និងកងទ័ពបដិវត្តន៍យើងថែមទៀត និងសូមរៀនសូត្រនូវគំរូដ៏ថ្លៃថ្លារបស់មហាជន ប្រជាជន និងកងទ័ពបដិវត្តន៍ជារៀងរហូត ដើម្បីប្រយុទ្ធការពារបក្សកុម្មុយនីស្តកម្ពុជាយើង និងការពារមាតុភូមិដាច់ខាត ។

◆ ជយោ បក្សកុម្មុយនីស្តកម្ពុជា ដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ !

◆ ជយោ បដិវត្តន៍កម្ពុជា ដ៏ខ្លាំងក្លាមហាអស្ចារ្យ !

◆ ជយោ បុណ្យខួបឆ្នាំទីពីរ នៃមហាជ័យជម្នះថ្ងៃ ១៧ មេសា ដ៏មហាអស្ចារ្យ !

◆ ប្តេជ្ញា លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ ឲ្យខ្ពស់ជាប់ជានិច្ច កម្ទេចគ្រប់ឧបាយកលរបស់ខ្មាំង ដើម្បីការពារបក្ស ការពារប្រជាជន និងការពាររដ្ឋអំណាចបដិវត្តន៍ដាច់ខាត !

◆ ប្តេជ្ញា វាយកម្ទេច និងបោសសម្អាតពួក “ស.អ.អ” “ក.ស.ប” និងភ្នាក់ងារជាន្លែបម្រើ “យ” លេបទឹកដី ដែលបង្កប់ស៊ីរូងផ្ទៃក្នុងឲ្យស្អាតដាច់ខាត !

ជាទីបញ្ចប់ សូមគោរពជូនពរចំពោះបក្ស សូមមានសុខភាពបរិបូរ មានកម្លាំងមាំមួនគ្រប់ពេលវេលា ដើម្បីដឹកនាំយើងទាំងអស់គ្នា បន្តធ្វើបដិវត្តន៍សង្គមនិយម កសាងសង្គមនិយម និងការពារប្រទេសឲ្យបានគង់វង្ស និងចំរើនរុងរឿងជារៀងរហូត ។

សូមជូនពរដល់បងៗ និងមិត្តទាំងអស់ សូមមានសុខភាពមាំមួន មានកម្លាំងចិត្តក្លៀវក្លា ដើម្បីវាយសម្រុក សម្រេចគ្រប់ភារកិច្ចទាំងអស់ ដែលបក្សប្រគល់ជូន ។ **ឆេង ខេង**



យុវជនកងចល័តកំពុងវាយសម្រុកជីកប្រឡាយ

# ២០ ឧសភា ជាថ្ងៃដែលនាំឱ្យមានការចងចាំ

រាជរដ្ឋាភិបាលកម្ពុជា តែងតែរៀបចំប្រារព្ធ «ទិវារំលឹកថ្ងៃចងចាំ២០ ឧសភា» នៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បឹងជើងឯករៀងរាល់ឆ្នាំ ដោយមានការចូលរួមពីមន្ត្រីរដ្ឋាភិបាល ប្រជាជនកងកម្លាំង ប្រដាប់អាវុធ សិស្ស និស្សិត និងគ្រូបង្រៀន ។ ពិធីនេះបានចាប់ផ្តើមជាមួយការសូត្រមន្តបង្សុកូលរបស់ព្រះសង្ឃឧទ្ទិសដល់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត ការឡើងថ្លែងសុន្ទរកថាពីតំណាងមន្ត្រីរដ្ឋាភិបាលទាក់ទងអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម រួមជាមួយការសម្តែងឡើងវិញនូវឈុតឆាកដែលខ្មែរក្រហមបានប្រព្រឹត្តការធ្វើទារុណកម្ម និងការកាប់សម្លាប់មកលើប្រជាជន ។ «ពិធីរំឭកថ្ងៃចងចាំ២០ ឧសភា បានប្រារព្ធធ្វើដំបូងចាប់តាំងពីឆ្នាំ១៩៨៣ ដោយរបបរដ្ឋកម្ពុជា ដែលពេលនោះមានឈ្មោះថា «ទិវាចងកំហឹង ២០ ឧសភា» ដែលរំឭកទៅដល់ការឈឺចាប់ ទុក្ខវេទនា ការព្រាត់ប្រាស់ និងការកាប់សម្លាប់យ៉ាងព្រៃផ្សៃរបស់ក្រុមខ្មែរក្រហមមកលើប្រជាជនស្លូតត្រង់ ។ ការប្រារព្ធទិវាចងកំហឹង២០ ឧសភា នៅពេលនោះក៏ជាការអំពាវដល់ប្រជាជនរួមទាំងសហគមន៍អន្តរជាតិឲ្យប្រឆាំងនឹងរបបខ្មែរក្រហម ដែលបានប្រមូលផ្តុំកម្លាំងរបស់ខ្លួនឡើងវិញ នៅតាមបណ្តោយព្រំដែន និងកំពុងមានអាសនៈនៅអង្គការសហប្រជាជាតិ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៨០ ។

ក្រោយមក តាមរយៈកិច្ចដំណើរការចរចារកសន្តិភាពឆ្នាំ១៩៩១ ការរៀបចំបោះឆ្នោត ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្ន (ហៅកាត់ អ៊ុនតាក់) ឆ្នាំ១៩៩៣ (ដោយមានការចូលរួមពីភាគីខ្មែរក្រហម) ការផ្តាច់ខ្លួនរបស់ក្រុមខ្មែរក្រហមដែលនៅសេសសល់ចុះចូលជាមួយរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៧ រួមទាំង ដំណើរស្វែងរកយុត្តិធម៌តាមរយៈការចរចារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីបង្កើតសាលាក្តី



អដ្ឋិធាតុជនរងគ្រោះនៅខេត្តស្វាយរៀង ក្រោយរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

កាត់ទោសមេដឹកនាំខ្មែរក្រហម និងដំណើរការផ្សះផ្សាជាតិទាំងមូល «ទិវាចងកំហឹង២០ ឧសភា» ត្រូវបានប្តូរឈ្មោះមកជា «ទិវារំឭកការចងចាំ២០ ឧសភា» រហូតដល់បច្ចុប្បន្ន។

មុី ម៉ុន អាយុ៦៨ឆ្នាំ ជាប្រធានក្រុមប្រជាជន រស់នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលតែងតែទៅចូលរួមពិធីរំឭកការចងចាំនេះតាំងពីដំបូង បានមានប្រសាសន៍ថា គាត់នៅតែមានការឈឺចាប់ និងចងចាំ។ ទោះបីជាមានការផ្លាស់ប្តូរឈ្មោះទិវាថ្ងៃ២០ ឧសភា យ៉ាងណាក៏ដោយ។ ម៉ុន បានបន្តថា គាត់ជាអតីតទាហាន លន់ នល់ នៅឆ្នាំ១៩៧៣។ ក្រោយពេលខ្មែរក្រហមទទួលជ័យជម្នះ នៅឆ្នាំ១៩៧៥ គាត់ និងប្រពន្ធ រួមទាំងឪពុកម្តាយ និងបងប្អូនបង្កើត ប្រមាណជាង១០នាក់ ត្រូវបានខ្មែរក្រហមជម្លៀសពីសង្កាត់ជើងឯក ឲ្យទៅរស់នៅឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ នៅទីនេះ គាត់ត្រូវបានចាត់តាំងឲ្យភ្ជួររាស់ស្រែក្នុងក្រុមដែលមានសមាជិកប្រមាណជា១០នាក់ ដែលក្រោយមកក្រុមរបស់គាត់បានបាត់ខ្លួនជាបន្តបន្ទាប់នៅសល់តែពីរនាក់ប៉ុណ្ណោះ។ នៅទីនោះ គាត់ត្រូវបានចាត់តាំងឲ្យធ្វើការចាប់ពីព្រឹកព្រលឹម រហូតដល់ពេលល្ងាចទើបឈប់សម្រាកហូបអាហារបន្តិចបន្តួចប៉ុណ្ណោះ។ ឪពុករបស់គាត់ និងកូនរបស់គាត់ម្នាក់បានស្លាប់បាត់បង់ជីវិត ដោយសារអត់អាហារ។ គាត់បានរស់នៅស្រុកកណ្តាលស្ទឹង រហូតដល់វៀតណាមចូលមករំដោះ ឆ្នាំ១៩៧៩ ទើបគាត់ត្រឡប់មកស្រុកកំណើតនៅជើងឯកវិញ។ មកដល់ភូមិដំបូង គាត់ត្រូវបានរដ្ឋអំណាចចាត់តាំងឲ្យធ្វើជាសេនាជនក្នុងភូមិ និងត្រូវស្នាក់នៅយាមការពារភូមិជាមួយកងទ័ពវៀតណាម ដែលមានទីតាំងនៅលើរណ្តៅសាកសពបឹងជើងឯក ដែលកាលនោះមានដើមឈើជាច្រើនដុះព័ទ្ធជុំវិញ។ ពេលនោះគាត់មិនបានដឹងថា កន្លែងដែលគាត់ស្នាក់នៅយាមការពារជាកន្លែងសម្លាប់មនុស្សឡើយ។ ក្រោយមកដោយសាររដ្ឋអំណាចស្រាវជ្រាវដឹង ទើបមានការគាស់សាកសពដើម្បីធ្វើកោសល្យវិច័យ ដោយមានការសហការជាមួយជំនាញការវៀតណាម។ ចាប់តាំងពីពេលនោះមក ទីតាំងកប់សាកសពបឹងជើងឯកត្រូវបានប្រារព្ធធ្វើពិធីរំឭកញាណក្ខន្ធជារៀងរាល់ឆ្នាំ ឬដែលហៅថា «ទិវាចងកំហឹង ២០ ឧសភា»។ នៅពេលនោះដែរ គាត់ក៏ត្រូវបានជ្រើសរើសឲ្យសម្តែង



ស្តូបតម្កល់អដ្ឋិធាតុនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បឹងជើងឯក



មុី ម៉ុន កំពុងរៀបរាប់ពីរឿងរ៉ាវពីរបបខ្មែរក្រហម

ជាប្រជាជនដែលរងអំពើឃោរឃៅពីយោធាខ្មែរក្រហមនៅក្នុងក្រុមមួយដឹកនាំដោយ កែវ ចិន្តា ។ គាត់បានបន្តថា នៅរាល់ពេលប្រារព្ធទិវាចងកំហឹង២០ ឧសភា នៅពេលនោះ តែងតែមានការស្លុតការសូត្រកំណាព្យ ការឡើងថ្លែងពីទុក្ខសោក វេទនា ការព្រាតប្រាស់ការវាយ និងដុតរូបតុក្កតាតំណាងឲ្យមេដឹកនាំខ្មែរក្រហម ដែលបានប្រព្រឹត្តអំពើឃោរឃៅមកលើប្រជាជនស្លូតត្រង់ ។ នៅខណៈនោះ ព្រះសង្ឃ ប្រជាជន មន្ត្រីរដ្ឋការ ទាហាន សិស្ស និស្សិត គ្រូពេទ្យ ដែលបានចូលរួមក្នុងពិធីនេះ រួមទាំងគាត់ផ្ទាល់ ដែលមានសាច់ញាតិបងប្អូន និងឪពុកម្តាយស្លាប់ តែងតែបញ្ចេញនូវមនោសញ្ចេតនាសោកសង្រេង លាយឡំជាមួយការយំសោក ។ ម៉ុន ឲ្យដឹងថា សម្រាប់គាត់រហូតមកដល់បច្ចុប្បន្ន គាត់មិនបានគំគួន និងចងកំហឹងជាមួយខ្មែរក្រហមទេ ប៉ុន្តែគាត់នៅតែមានការការឈឺចាប់ និងការចងចាំ ទោះបីជាមានការផ្សះផ្សា និងមានសាលាក្តីខ្មែរក្រហមហើយក៏ដោយ ។

ចំណែក ឆាយ ប៉ោយ រស់នៅខណ្ឌដង្កោ រាជធានីភ្នំពេញ បានមានប្រសាសន៍ថា គាត់តែងតែទៅចូលរួម «ទិវានៃការចងចាំ ២០ ឧសភា» នៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បឹងជើងឯកជារៀងរាល់ឆ្នាំ ។ ប៉ោយ និងក្រុមគ្រួសារបានទិញគ្រឿងឧបភោគបរិភោគប្រគេនដល់ព្រះសង្ឃ ដើម្បីបង្សុកូលឧទ្ទិសកុសលដល់បងប្អូនញាតិមិត្ត ក៏ដូចជាប្រជាជនខ្មែរស្លូតត្រង់ដទៃទៀត ដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ ថ្ងៃ២០ ឧសភា បានរម្លឹកដល់ ប៉ោយ ពីដំណើរជីវិតដ៏លំបាកវេទនាដែលគាត់ និងគ្រួសារធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ជាពិសេស គឺមរណភាពរបស់បងប្រុសរបស់គាត់ ដែលជាបុគ្គលម្នាក់ បានចូលរួមតស៊ូជាមួយចលនាខ្មែរក្រហម ប៉ុន្តែ នៅទីបំផុត ត្រូវបានខ្មែរក្រហមសម្លាប់ដោយចោទថា ជាទាហានរត់ចោលជួរ ។

ប៉ោយ មានស្រុកកំណើតនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលមានឪពុកម្តាយជាកសិករ ។ គាត់មានបងប្អូនប្រុស៦នាក់ ហើយក្នុងនោះ បងប្អូនប្រុសបីនាក់ បានចូលរួមចលនាតស៊ូជាមួយខ្មែរក្រហម ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមសីហនុ ។ ប៉ោយ មិនបានចូលរួមជាមួយបងប្អូនគាត់ទេ គឺនៅធ្វើស្រែចម្ការជាមួយឪពុកម្តាយ ។

ក្រោយជ័យជម្នះ១៧ មេសា ឆ្នាំ១៩៧៥ របស់ខ្មែរក្រហម ទោះបីជា គ្រួសាររបស់ ប៉ោយ មានបងប្អូនដែលជាយោធាខ្មែរក្រហម ក៏អ្នកទាំងអស់គ្នាត្រូវបានអង្គការបាត់តាំងឲ្យធ្វើការងារដូចប្រជាជនដម្ទៀសដទៃដែរ ។ បងប្អូនរបស់ ប៉ោយ ដែលស្ម័គ្រចូលរួមជាមួយខ្មែរក្រហមក៏មិនដែលបានជួបគ្នាដែរ បន្ទាប់ពីប្រទេសត្រូវបានរំដោះហើយ ។ គាត់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកងភ្ជួរ ដែលមានសមាជិកទាំងប្រុសទាំងស្រីចំនួន៧០នាក់ ។ ប៉ោយ បានឲ្យដឹងថា សមាជិកក្រុម៧០នេះ គឺទទួលបានរបបអង្ករតែប្រាំកំប៉ុងប៉ុណ្ណោះ សម្រាប់បបរចែកគ្នាក្នុងមួយពេល ។ គ្មាននរណាម្នាក់បរិភោគគ្រប់គ្រាន់ឡើយ ហើយក៏គ្មាននរណាម្នាក់ហ៊ានជំទាស់តវ៉ាដែរ ។ អំឡុងឆ្នាំ១៩៧៧-៧៨ សមាជិកក្នុងក្រុមរបស់គាត់ ត្រូវបានអង្គការចាប់យកទៅជាបណ្តើរៗ ។ អ្នកទាំងនោះត្រូវបានអង្គការមើលឃើញថា ជាអ្នកដែលមានគំនិតប្រឆាំងនឹងអង្គការ តវ៉ា ឬស្ពឹកស្រពន់ក្នុងការងារ ។ អ្នកដែលមិនធ្វើការគ្រប់ដែនការដែលអង្គការដាក់ឲ្យមួយដងជាពីរដង នោះអង្គការនឹងចាប់យកទៅដូចគ្នា ។

**សោម ប៊ុនថន និង ឆាន សារៈមុន្និន្ទ**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវ
# សហសម័យវិទ្យាស្ថានស្លឹករឹត ក្នុងបរិវេណវិទ្យា









# ត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិចិត្រសាល ្ឋានជាតិអប់រំ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៧









# ការិយាល័យព័ត៌មានសាធារណៈ

*«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងទិន្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អ៊ុន សុដាវី តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthsodavy.u@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា




*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ម៉ែន ពិចិត្រ ទូរសព្ទលេខ ៖ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthmpechet@dccam.org*

# ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅកម្ពុជា

កាលពីពេលថ្មីៗ នេះក្រសួងអប់រំយុវជន និងកីឡា បានចុះកិច្ចព្រមព្រៀងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ - ១៩៧៩) ដល់គ្រូមូលដ្ឋាន គរុសិស្ស មកពី៦ភូមិភាគនៅទូទាំងប្រទេសកម្ពុជា (រួមមានៈ ភូមិភាគភ្នំពេញ ភូមិភាគកណ្ដាល ភូមិភាគបាត់ដំបង ភូមិភាគតាកែវ ភូមិភាគកំពង់ចាម និងភូមិភាគព្រៃវែង) គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ និងសិស្សនៅតាមសាលាចំណេះទូទៅ ។

កម្មវិធីបង្រៀននេះ នឹងរៀបចំធ្វើក្នុងរយៈប្រាំឆ្នាំ (ពីឆ្នាំ ២០១៨ ដល់ ឆ្នាំ២០២២) ក្នុងគោលបំណងផ្ដល់នូវចំណេះដឹងពីរបបខ្មែរក្រហមទូលំទូលាយ និងស៊ីជម្រៅដល់សិស្ស និស្សិត និងលោកគ្រូអ្នកគ្រូ ។ ទន្ទឹមនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានផ្ដល់នូវការបណ្ដុះបណ្ដាលពីវិធីបង្រៀនថ្មីពីប្រវត្តិសាស្ត្រខ្មែរដល់លោកគ្រូអ្នកគ្រូ ដោយលោកគ្រូអ្នកគ្រូក៏អាចប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនដែលឆ្លងកាត់របបខ្មែរក្រហមដែរ ។ វិធីសាស្ត្រនេះនឹងធ្វើឲ្យការបង្រៀនរបស់លោកគ្រូអ្នកគ្រូកាន់តែមានប្រសិទ្ធភាពថែមទៀត ។

រយៈប្រមាណជាង២២ឆ្នាំ មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការប្រមែរប្រមូល ចងក្រង បោះពុម្ព និងផ្សព្វផ្សាយពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានផ្ដល់ឯកសារប្រមាណជិត១លានទំព័រទាក់ទងនឹងរបបខ្មែរក្រហម ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា សាលាក្ដីខ្មែរក្រហម ដើម្បីជាភ័ស្ដុតាងក្នុងដំណើរការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះពីរបបនេះ ។ បន្ទាប់


ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ - ៧៩) ដល់សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រែកកំពឹស

ពីតុលាការនេះបញ្ចប់ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងនៅតែបន្តកិច្ចការរបស់ខ្លួន ដោយផ្តោតសំខាន់ទៅការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) រួមជាមួយនឹងជំរុញឲ្យមានការផ្សះផ្សានៅក្នុងប្រទេស ។

ទាក់ទងនឹងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកវិទ្យាស្ថានស្លឹករឹត បានមានប្រសាសន៍លម្អិតថា ៖

កម្មវិធីបង្រៀនកម្ពុជាប្រជាធិបតេយ្យ យើងធ្វើតាំងពីឆ្នាំ ២០០៨ ដែលគិតមកមកដល់សព្វថ្ងៃ មានរយៈពេលជាង១០ឆ្នាំហើយ ជាមួយក្រសួងអប់រំនេះ គឺយើងធ្វើបន្តបន្ទាប់ ដើម្បីធានាឲ្យបានប្រសិទ្ធភាពនៃការបង្រៀន ហើយដើម្បីធានាថាប្រជាជនសិស្សានុសិស្សទាំងអស់ ទទួលបានការអប់រំពីបញ្ហានេះ ។ យើងនឹងនៅតែបន្តកិច្ចការរបស់យើង ហើយយើងពង្រីកកិច្ចការនេះជាមួយដៃគូផ្សេងទៀតនៅក្នុងវិស័យអប់រំ ។

លោកបានបន្តថា ក្រៅពីការបង្រៀនគ្រូបង្គោល និងបណ្តុះបណ្តាលគ្រូខេត្តនៅក្នុងប្រព័ន្ធអប់រំដែលយើងមានរួចហើយ យើងមានសិក្ខាសាលានៅក្រៅថ្នាក់រៀន មានការចងក្រងប្រវត្តិភូមិនៅទូទាំងប្រទេសកម្ពុជា មានការជួបប្រជុំលោកគ្រូអ្នកគ្រូទាំងអស់ប្រចាំឆ្នាំដើម្បីតម្រង់ទិសនៃការបង្រៀននេះឲ្យមានប្រសិទ្ធភាព ។

ជារួម គោលដៅរបស់យើងចំពោះការបង្រៀននេះ គឺប្រែក្លាយការបង្រៀន និងកម្មវិធីនេះ ទៅជាគណៈកម្មាធិការស្វែងរកការពិតជាប្រវត្តិសាស្ត្រមួយដែលបំពេញឲ្យនូវកង្វះខាត ដែលផ្តល់ឲ្យដោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្នុងន័យនេះ កម្មវិធីនេះមិនត្រឹមតែបង្រៀនគ្រូ បង្រៀនសិស្ស សិក្ខាកាម និងប្រមូលប្រវត្តិនៅតាមភូមិស្រុកតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាគោលដៅធ្វើឲ្យប្រវត្តិសាស្ត្រក្លាយជាមេរៀនមួយសម្រាប់ប្រទេសជាតិ ក្លាយទៅជាមេរៀនមួយសម្រាប់ចែករំលែកទៅប្រទេសដទៃទៀតក្នុងពិភពលោក ។

ក្នុងនោះលោក ឆាំង យុ ក៏បានពន្យល់ទាក់ទងនឹងប្រវត្តិភូមិថា ៖ ជាទូទៅនៅពេលបង្រៀន យើងត្រូវការឯកសារផ្សេងៗ ដូចជា សិល្បៈ ល្ខោន ចម្រៀង រូបភាព ហើយរឿងដែលសំខាន់ គឺរឿងរ៉ាវដែលកើតឡើងនៅតាមភូមិ ព្រោះការស្រាវជ្រាវរបស់យើងមិនទាន់បានស៊ីជម្រៅនៅឡើយ ។ ដូច្នេះយើងបានស្នើសុំឲ្យលោកគ្រូអ្នកគ្រូដែលជាកម្មសិក្សា ក្លាយទៅជាអ្នកស្រាវជ្រាវមួយឲ្យកម្មវិធីរបស់យើង ដើម្បីឲ្យគាត់សរសេររឿងរ៉ាវផ្សេងៗដែលយើងមិនបានដឹង ហើយការសរសេរនេះ គឺជាឯកសារបន្ថែមសម្រាប់ពេលបង្រៀន ។ ឧទាហរណ៍ លោកគ្រូអ្នកគ្រូបង្រៀននៅខេត្តកំពង់ធំ គាត់មិនបានដឹងរឿងដែលបានកើតឡើងនៅខេត្តកំពង់ចាមទេ ។ ដូច្នេះ យើងចងក្រងរឿងរ៉ាវភូមិនេះ គឺទី១) យើងបង្កើតឲ្យមានអ្នកប្រវត្តិវិទូតាមភូមិ ។ ទី២) យើងពង្រីក និងប្រមូលសាច់រឿង និងទិន្នន័យឲ្យបានទូលំទូលាយដើម្បីចែករំលែកនូវរឿងរ៉ាវដែលបានឆ្លងកាត់ប្រទេសកម្ពុជាទាំងមូល ។ លោកគ្រូអ្នកគ្រូរបស់យើងនៅមូលដ្ឋានស្រាប់ ដូច្នេះជាការងាយស្រួល ហើយដោយឆ្លងកាត់វគ្គបណ្តុះបណ្តាល និងប្រាក់ឧត្ថម្ភខ្លះគាត់អាចអនុវត្តកិច្ចការនេះបាន ហើយនឹងមានប្រយោជន៍ច្រើន ។ យើងនឹងបើកទូលាយឲ្យលោកគ្រូអ្នកគ្រូសរសេរដូចជា រឿងជនដៃដល់ រឿងជនរងគ្រោះ ការអភិវឌ្ឍ ការសាងសង់ទំនប់ទឹក ការជីកប្រឡាយ និងការបង្កើតឲ្យមានសហករណ៍ជាដើម ។ យើងធ្វើកិច្ចការនេះ ដើម្បីបង្កើតឲ្យមានស្មារតីស្រឡាញ់ភូមិដ្ឋាន ការពារបរិស្ថាន គោរពដល់សិទ្ធិមនុស្ស ដោយសារថាបញ្ហានេះ ជាបញ្ហារបស់យើងទាំងអស់គ្នា ។ យើងធ្វើឲ្យអ្នកស្រុកស្រឡាញ់ស្រុកភូមិរបស់គាត់ ហើយការចែករំលែកនេះនឹងធ្វើឲ្យសិស្សានុសិស្សបានដឹងទូលំទូលាយ ជាជាងដឹងតែតំបន់ដែលខ្លួនកំពុងរស់នៅ ។

ទាក់ទងនឹងកម្មវិធីបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅក្នុងក្រសួងអប់រំ លោក ឆាំង យុ បានបញ្ជាក់ថា ក្រសួងអប់រំបានដាក់បញ្ចូលមុខវិជ្ជានេះ ដូចជាមុខវិជ្ជាផ្សេងៗទៀតដែរ ដោយរៀបចំឲ្យមានសំណួរសម្រាប់ចេញពេលប្រលងសញ្ញាបត្រទុតិយភូមិ ។ ប៉ុន្តែអ្វីដែលថ្មី គឺយើងបញ្ចូលការបង្រៀននេះទៅក្នុងកម្មវិធីរបស់សាលាគរុកោសល្យទាំង៦ភូមិភាគ ។

ចំពោះវិធីសាស្ត្របង្រៀន លោកគ្រូអ្នកគ្រូ អាចជ្រើសរើសវិធីផ្សេងដើម្បីបង្រៀន ឧទាហរណ៍ គ្រូនៅខាងតាកែវម្នាក់ចូលចិត្តសិល្បៈ ដូច្នេះ គាត់យកល្ខោន«ទម្លាយភាពស្ងប់ស្ងាត់» ដែលនិយាយពីការលើកលែងទោសឲ្យកម្មាភិបាលថ្នាក់ក្រោម មកបង្រៀន និងមានការសន្ទនាមួយរវាងជនរងគ្រោះ និងជនដៃដល់ ។



សិស្សឡើងសរសេរពីការយល់ដឹង និងចម្ងល់ទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)

ចំណែកអ្នកគ្រូម្នាក់ទៀតនៅខេត្តក្រចេះ បានបង្រៀនពី "ប្រអប់សង្គ្រោះជីវិត" ដែលនៅក្នុងមេរៀននោះនិយាយអំពីរបៀបរស់នៅ នៅពេលដែលយើងជួបភាពអត់ឃ្លាន ។ យើងបានបង្រៀនគ្រូប្រមាណជិត៣.០០០នាក់រួចមកហើយ ហើយគ្រូប្រមាណ៣០ ទៅ៣៥ភាគរយជាជនរងគ្រោះ ។ គ្រូប្រមាណ៦០ ទៅ៦៥ភាគរយ កើតក្រោយសម័យខ្មែរក្រហម ។ គ្រូប្រមាណ១០ ទៅ១៥ភាគរយ ធ្លាប់រស់នៅមូលដ្ឋានខ្មែរក្រហម ។ ដោយសារប្រវត្តិបុគ្គលខុសៗគ្នា ទើបយើងឲ្យជម្រើសគ្រូចំពោះវិធីសាស្ត្របង្រៀន ។ សំខាន់មួយទៀត ការបង្រៀននេះ គឺយើងឲ្យមានការប្រៀបធៀបពីអំពើប្រល័យពូជសាសន៍ នៅយូហ្គោស្លាវី អាល្លឺម៉ង់ រ៉្វាន់ដា អ៊ីរ៉ាក់ និងប្រទេសកម្ពុជា ។ យើងចង់បង្ហាញថា ខ្មែរយើងមិនមែនជជនរងគ្រោះម្នាក់ឯងទេ គឺអំពើនេះកើតមានឡើងនៅប្រទេសផ្សេងៗទៀតជុំវិញពិភពលោក ហើយការសិក្សាពីប្រទេសផ្សេងៗទៀតនោះគឺប្រើវិធីសាស្ត្រឲ្យសិស្សសិក្សាជាក្រុម ។

ទាក់ទងនឹងការបង្រៀនដែរ យើងមានសៀវភៅបង្រៀនសម្រាប់សិស្ស និងបានកំណត់ទៅតាមកម្រិតចំណេះដឹងរបស់សិស្ស ប៉ុន្តែក្រៅពីនេះ ក៏យើងមិនបានកម្រិតថា មិនឲ្យមានមេរៀនផ្សេងទៀតដែរ ។ សិស្សមួយចំនួនមានសំណួរជ្រៅជាងសៀវភៅដែលយើងបង្រៀនដោយ សារការរីកចម្រើននៃបច្ចេកវិទ្យា ។ ដូច្នេះ ហើយបានជាយើងបង្កើតឲ្យមានវាគ្មិន ដោយលោកគ្រូអ្នកគ្រូអាចយកអ្នកនៅក្នុងមូលដ្ឋាន ឬអ្នកនៅខាងក្រៅដើម្បីឆ្លើយសំណួរ ។ យើងក៏បង្កើតឲ្យមានកម្មវិធីវេទិកាសាធារណៈពិភាក្សាក្រៅថ្នាក់រៀន ដោយមានការជួបជុំរវាង សិស្ស គ្រូ វាគ្មិន និងជនរងគ្រោះផ្ទាល់ ។ ដូច្នេះ គ្រូអាចយកបទពិសោធន៍នៅខាងក្រៅ មកត្រៀមឆ្លើយសំណួររបស់សិស្ស ដែលមិនមាននៅក្នុងសៀវភៅណែនាំស្ដីពីការបង្រៀន ។

លោក ឆាំង យុ បានបន្តថា "កម្មវិធីប្រវត្តិសាស្ត្រ" នេះ គឺជារបស់ជាតិ ដូច្នេះវាជាកាតព្វកិច្ច ហើយគ្រូត្រូវតែបង្រៀន ហើយលោកក៏ធ្លាប់ទាមទារសូមឲ្យបន្ថែមពេលវេលាបង្រៀនទៀតដែរ ។ ចំពោះការវាយតម្លៃគ្រូពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលា លោកបានធ្វើក្នុងរយៈពេលបីឆ្នាំម្ដង ហើយរហូតមកដល់ពេលនេះលោកបានធ្វើបានចំនួនពីរយសាលារួចមកហើយ ក្នុងចំណោមសាលារៀនចំនួនជាងមួយពាន់ ។ តាមរយៈការបង្រៀនកន្លងមក យើងក៏មានបញ្ហាមួយចំនួនដែរ ដោយលោកគ្រូអ្នកគ្រូខ្លះមានឪពុកម្ដាយ និងសាច់ញាតិស្លាប់នៅក្នុងរបបខ្មែរក្រហម ដែលប៉ះពាល់អារម្មណ៍របស់គាត់ ចំណែកសិស្សមួយចំនួនមានឪពុកម្ដាយ និងសាច់ញាតិជាជនដៃដល់ ។ ដោយសារការបង្រៀននេះបានប្រឈមនឹងបញ្ហាអតីតកាល ដូច្នេះយើងបានព្យាយាមរកវិធីដើម្បីឲ្យយើងបានធូរស្បើយទាំងអស់គ្នា ។

លោក ឆាំង យុ បានមានប្រសាសន៍ទៀតថា លោកមានសុទិដ្ឋិនិយមចំពោះកម្មវិធីបង្រៀននេះដោយសារយើងបានដោះស្រាយដោយសន្តិវិធី ហើយយើងបានដើរទៅមុខ ហើយនៅតាមសាលាយើងក៏បានរៀបចំកសាងពាក្យស្លោក ដើម្បីរំឭកសិស្សថា "ការសិក្សានេះជាការអត់ឱន ការផ្សះផ្សា ការអធ្យាស្រ័យ" ។ យើងក៏បានបង្កើតជាកម្មវិធីវិទ្យុ កម្មវិធីចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការបោះខិតបណ្ណផ្សព្វផ្សាយ ដើម្បីជំរុញដល់កម្មវិធីសិក្សានេះឆ្ពោះទៅមុខដែរ ។ លោកបានកត់សម្គាល់ថា ប្រទេសកម្ពុជា គឺជាប្រទេសតែមួយគត់ក្នុងពិភពលោកដែលផ្ដួចផ្ដើមការបង្រៀនប្រវត្តិសាស្ត្រនេះដោយខ្លួនឯង នៅក្នុងរូបភាពផ្សេងតាំងពីឆ្នាំ១៩៧៩ មកម្ល៉េះ ហើយក៏បានចែករំលែកបទពិសោធន៍របស់ខ្លួនទៅកាន់ពិភពលោកទាំងមូល ។

**សោម ប៊ុនថន**

# ការសិក្សាអំពីរបបខ្មែរក្រហមជំរុញឱ្យស្រឡាញ់សន្តិភាព

កាលពីព្រឹក ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកា ថ្នាក់រៀនស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ជាមួយសិស្សថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្តន៍ ចំនួន៧១នាក់ ។ កម្មវិធីនេះរៀបចំឡើងក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងទទួលបានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ *(USAID)* កម្មវិធីប្រព្រឹត្តទៅនៅវិចិត្រសាលសហសម័យវិទ្យាស្ថានស៊ីករីត ដែលផ្តល់ទីតាំងដោយឥតគិតថ្លៃ ដល់សិល្បករគ្រប់រូបសម្រាប់ដាក់តាំងបង្ហាញស្នាដៃសិល្បៈរបស់ខ្លួនជូនសាធារណជន ។ វេទិកាថ្នាក់រៀននេះ រួមបញ្ចូលសកម្មភាពចំនួនពីរគឺ ការធ្វើបទបង្ហាញខ្លីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវិធីសាស្ត្រសម្ភាសន៍ ។

មុននឹងផ្តើមនៃការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ លោក ដេង ពង្សរ៉ាស៊ី ប្រធានក្រុមគម្រោងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានស្នើឲ្យសិស្សដែលចូលរួមឡើងសរសេរអំពីអ្វីដែលខ្លួនបានដឹងអំពីរបបខ្មែរក្រហម និងអ្វីដែលខ្លួនចង់ដឹងអំពីរបបខ្មែរក្រហម ។ សិស្សមួយចំនួនបានសរសេរថា របបខ្មែរក្រហមជារបបឃោរឃៅដែលបានធ្វើទារុណកម្មប្រជា



ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩) ដល់សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ព្រែកកំពឹស

ជន បង្ខំឲ្យប្រជាជនធ្វើការងារធ្ងន់ និងបង្អត់អាហារប្រជាជន ។ សិស្សផ្សេងទៀតបានសរសេរថា ប្រជាជនប្រហែលមួយភាគបួនបានស្លាប់នៅក្នុងរបបខ្មែរក្រហម ដែលភាគច្រើនជាមន្ត្រីរាជការពីរបបចាស់ និងអ្នកចេះដឹង ។ សិស្សមួយចំនួនទៀតបានលើកឡើងថា ខ្មែរក្រហមបានបំបិទសាលារៀន ហាមប្រាមប្រជាជនមិនឲ្យប្រណិប័តន៍សាសនា និងបានបំបែកក្រុមគ្រួសារមិនឲ្យរស់នៅជុំគ្នា ។ រីឯអ្វីដែលសិស្សចង់ដឹងបន្ថែមគឺ តើខ្មែរក្រហមជានរណា? នរណាជាមេដឹកនាំខ្មែរក្រហម? ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជន? ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជន? សិស្សានុសិស្សហាក់ដូចជាចង់ចេះដឹងកាន់តែច្បាស់អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយបានចោទសួរសំណួរជាច្រើនទៅកាន់ លោក ផេង ពង្សរ៉ាស៊ី ។

បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ លោក ឡុង ដានី ប្រធានក្រុមគម្រោងជំរុញឲ្យមានការទទួលខុសត្រូវ បានពន្យល់សិស្សានុសិស្សអំពីវិធីសាស្ត្រសម្ភាសន៍ ។ មុននឹងលោកចាប់ផ្តើម លោកបានសាកសួរទៅកាន់សិស្សានុសិស្សថាតើធ្លាប់បានសម្ភាសឪពុកម្តាយ ជីដូនជីតា ឬសាច់ញាតិរបស់ខ្លួនពីមុនមកទេ អំពីបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម ។ សិស្សមួយចំនួនបាននិយាយថាខ្លួនធ្លាប់សួរនាំឪពុកម្តាយអំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ លោក ឡុង ដានី បានណែនាំថា ដើម្បីសម្ភាសអ្នករស់រានមានជីវិតអំពីរបបខ្មែរក្រហម អ្នកសម្ភាសន៍គួរតែបញ្ជាក់អំពីវត្ថុបំណងរបស់ខ្លួនឲ្យបានច្បាស់លាស់ ជៀសវាងការភាន់ច្រឡំ និងត្រូវរៀបចំកម្រងសំណួរ ។ មិនតែប៉ុណ្ណោះ អ្នកសម្ភាសន៍ត្រូវសុំការអនុញ្ញាតយល់ព្រមពីអ្នកផ្តល់បទសម្ភាសន៍ ។ អ្នកសម្ភាសន៍ត្រូវយកចិត្តទុកដាក់ស្តាប់ និងចេះកត់ត្រានូវព័ត៌មានសំខាន់ៗដែលអ្នកផ្តល់បទសម្ភាសន៍បានរៀបរាប់ប្រាប់ ។

ជាកិច្ចបញ្ចប់កម្មវិធី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា


សិស្សវិទ្យាល័យអនុវត្ត កំពុងសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-៧៩)

បានចែកសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)" ដល់សិស្សានុសិស្សដែលបានចូលរួមវេទិកាថ្នាក់រៀននេះ ។ ជាងនេះទៅទៀតសិស្សានុសិស្សមួយចំនួនបានបញ្ចេញមតិយោបល់របស់ខ្លួនទាក់ទងនឹងការចូលរួមរបស់ខ្លួនដូចខាងក្រោមៈ

ម៉ាប់ សុខីតា អាយុ១៧ឆ្នាំ កំពុងរៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត បានលើកឡើងថា ម្តាយរបស់ខ្ញុំធ្លាប់និយាយប្រាប់ខ្ញុំអំពីរបបខ្មែរក្រហមនៅពេលខ្ញុំមានអាយុ១០ឆ្នាំ ។ គាត់បាននិយាយអំពីការបង្អត់អាហារនៅក្នុងរបបខ្មែរក្រហម ។ នៅពេលនោះ ខ្ញុំមិនសូវជឿប៉ុន្មានទេ ដោយសារតែខ្ញុំ គិតថាប្រហែលជាគាត់និយាយរឿងនេះ ដើម្បីបន្ទាចខ្ញុំដោយសារតែគាត់ឃើញខ្ញុំខ្ជះខ្ជាយម្ហូបអាហារនៅលើតុ ។ ប៉ុន្តែ ឥឡូវនេះខ្ញុំជឿទៅលើអ្វីដែលគាត់បាននិយាយ បន្ទាប់ពីខ្ញុំបានរៀននៅសាលា ។ ខ្ញុំគិតថា វេទិកាថ្នាក់រៀននេះសំខាន់ ដែលបានផ្តល់ឱកាសដល់រូបនាងខ្ញុំបានយល់ដឹងបន្ថែមអំពីរបបខ្មែរក្រហម ។ ចំពោះនាងខ្ញុំ របបខ្មែរក្រហមជារបបមួយឃោរឃៅ ។

ក្នុងនាមជាយុវជនជំនាន់ក្រោយ យើងគួរតែសិក្សាស្វែងយល់អំពីរបបខ្មែរក្រហម ដោយសារតែការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមអាចជួយឲ្យយើងចេះគិតអំពីផលប៉ះពាល់អវិជ្ជមានមកលើប្រពៃណី និងវប្បធម៌របស់ខ្មែរ ។ ហេតុដូច្នេះ យើងគួរចេះសាមគ្គីគ្នា ដើម្បីកសាងសង្គមជាតិ និងរក្សាសន្តិភាពរបស់ប្រទេសកម្ពុជា ។ ខ្ញុំនឹងបន្តចែករំលែក និងផ្សព្វផ្សាយអំពីរបបខ្មែរក្រហមដល់កូនចៅរបស់ខ្ញុំនៅថ្ងៃអនាគត ។

សៀង សុវណ្ណរ៉ង្សា អាយុ១៧ឆ្នាំ កំពុងរៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត បាននិយាយថាៈ ខ្ញុំស្តាប់ឮរឿងរ៉ាវអំពីរបបខ្មែរក្រហមដំបូងនៅពេលខ្ញុំអាយុ១២ឆ្នាំ ។ ជីដូនជីតា និងឪពុកម្តាយខ្ញុំសុទ្ធតែធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ។ ជាសំណាងល្អ គ្រួសារខ្ញុំមិនមានបាត់បង់សមាជិកណាម្នាក់នៅក្នុងរបបខ្មែរក្រហមនោះឡើយ ។

ពីដំបូងឡើយ ខ្ញុំស្ទើរតែមិនជឿថា ខ្មែរក្រហមអាចកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ខ្ញុំមិននឹកស្មានថា ខ្មែរក្រហមអាចសម្លាប់ប្រជាជនឯងនោះទេ ។ ប៉ុន្តែ រឿងរ៉ាវនេះគឺជាការពិត ។ ខ្ញុំត្រេកអរដែលបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀននេះ ។ ខ្ញុំបានដឹងបន្ថែមអំពីមេដឹកនាំខ្មែរក្រហម និងប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនជាងមុន ។ ខ្ញុំយល់ឃើញថា ការយល់ដឹងអំពីរបបខ្មែរក្រហមជួយឲ្យជៀសផុតការប្រព្រឹត្តកំហុសឆ្គងពីអតីតកាល និងជួយឲ្យយើងចេះសាមគ្គីគ្នានៅក្នុងសង្គម ។

អឿន ស៊ីណា អាយុ១៨ឆ្នាំ កំពុងរៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត បានរៀបរាប់ថាៈ ម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមបង្ខំឲ្យរស់នៅផ្សេងពីឪពុកម្តាយរបស់គាត់ បើទោះបីជាគាត់នៅក្មេងនៅឡើយ ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរចំពោះម្តាយរបស់ខ្ញុំ ដោយសារតែគាត់នៅក្មេង និងមិនអាចរស់នៅជួបជុំជាមួយក្រុមគ្រួសាររបស់គាត់ ។ មិនតែប៉ុណ្ណោះ គាត់មិនបានទៅសាលារៀនទេ ។ ម្តាយខ្ញុំនិយាយថា ឪពុករបស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំសង្កេតឃើញថា ខ្ញុំហាក់ដូចជាយល់ដឹងច្រើនជាងមុនអំពីរបបខ្មែរក្រហម បន្ទាប់ពីការចូលរួមនៅក្នុងវេទិកាថ្នាក់រៀននេះ ។ ការសិក្សាអំពីរបបខ្មែរក្រហមជំរុញឲ្យយើងចេះស្រឡាញ់សន្តិភាព ។ ដើម្បីកសាងសន្តិភាពបាន យើងត្រូវចេះស្វែងរកសន្តិភាពនៅក្នុងខ្លួនយើងជាមុនសិន បន្ទាប់មកនៅក្នុងគ្រួសាររបស់យើង មុននឹងឈានទៅដល់ការរក្សាសន្តិភាពនៅក្នុងសង្គម និងប្រជាជាតិទាំងមូល ។

អ៊ុន មុន្នី អាយុ១៧ឆ្នាំ កំពុងរៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត បានចែករំលែកថាៈ ខ្ញុំធ្លាប់សួរពូរបស់ខ្ញុំអំពីជើងពិការរបស់ជីតាខ្ញុំ ។ ពូរបស់ខ្ញុំបានប្រាប់ខ្ញុំថា ជើងរបស់ជីតាខ្ញុំបានបាក់នៅក្នុងរបបខ្មែរក្រហម ។ រីឯជីដូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមបាញ់សម្លាប់ដោយសារតែគាត់ឃាត់មិនឲ្យខ្មែរក្រហមឡើងលើផ្ទះ ។ នៅក្នុងរបបខ្មែរក្រហម ពូរបស់ខ្ញុំរស់នៅស្រុកមេសាង ខេត្តព្រៃវែង ។ ខ្ញុំគិតថា ការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជួយឲ្យយើងចេះត្រិះរិះពិចារណា និងជួយទប់ស្កាត់កុំឲ្យរឿងរ៉ាវឃោរឃៅកើតឡើងនៅក្នុងប្រទេសរបស់យើង ។

សរុបសេចក្តីមក សិស្សានុសិស្សហាក់ដូចជាចាប់អារម្មណ៍ទៅលើវេទិកាថ្នាក់រៀននេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថា វេទិកាថ្នាក់រៀននេះនឹងជំរុញឲ្យសិស្សានុសិស្សបន្តជជែកពិភាក្សាជាមួយក្រុមគ្រួសារ និងមិត្តភក្តិអំពីរបបខ្មែរក្រហម ។

**ម៉ែន ពិចិត្រ**

# ប្រវត្តិជីតាខ្ញុំ


ធូ សុន ថតនៅអំឡុងឆ្នាំ១៩៧៣-៧៤

កើតក្នុងគ្រួសារអ្នកស្រែចម្ការ ជីតារបស់ខ្ញុំមានជីវភាពលំបាកណាស់ទៅហើយ ថែមពីលើនេះទៀតគាត់បានជួបប្រទះសង្គ្រាមស៊ីវិលក្នុងប្រទេសដែលរឹតតែធ្វើឲ្យជីវិតរបស់គាត់កាន់តែលំបាកថែមទៀត ។ ជីតារបស់ខ្ញុំមានឈ្មោះ ធូ សុន មានស្រុកកំណើតនៅឃុំត្រពាំងឈូក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ គាត់មានបងប្អូនពីរនាក់ ហើយគាត់ជាកូនទីពីរក្នុងគ្រួសារ ។ ជីតាខ្ញុំបានរស់នៅ និងបានឆ្លងកាត់រឿងរ៉ាវជាច្រើននៅក្នុងរបបខ្មែរក្រហម ។

ជីតាខ្ញុំបានរៀបរាប់ពីទុក្ខលំបាករបស់គាត់ប្រាប់ខ្ញុំថា ដោយសារគាត់ជាកូនអ្នកស្រែមិនមានថវិកាគ្រប់គ្រាន់ក្នុងការសិក្សា ទើបគាត់បានចូលរៀននៅពេលដែលមានអាយុ១១ឆ្នាំទៅហើយ ខុសពីកូនអ្នកនៅភ្នំពេញដែលបានចូលរៀនតាំងពីអាយុប្រាំមួយឆ្នាំម្ល៉េះ ។ សាលារៀនដំបូងដែលគាត់បានចូលរៀន គឺ សាលាបឋមសិក្សាវត្តស្វាយទាប ។ ប្រាំមួយឆ្នាំក្រោយមក គាត់ក៏បានបន្តការសិក្សានៅអនុវិទ្យាល័យមួយក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ដោយសារការខំប្រឹងប្រែង ទើបគាត់អាចបន្តការសិក្សាមកដល់ភ្នំពេញទាំងវិទ្យាល័យ និងមហាវិទ្យាល័យ ។ គាត់រៀនបណ្តើរធាក់ស៊ីក្លូបណ្តើរនៅពេលយប់ ដើម្បីយកប្រាក់មកចំណាយលើការសិក្សារៀនសូត្រ ។ កាលដែលគាត់កំពុងរៀន សង្គ្រាមក៏ផ្ទុះឡើងជាបន្តបន្ទាប់ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៣ និង១៩៧៤ ខ្មែរក្រហមបានផ្លោងគ្រាប់ប្រមាណពី៤ទៅ៥គ្រាប់ ចូលទីក្រុងភ្នំពេញ ស្ទើររាល់យប់ ដោយគ្រួសារខ្លះត្រូវគ្រាប់ស្លាប់បងប្អូន សាច់ញាតិ ហើយគ្រួសារខ្លះទៀតដែលមានផ្ទះឈើក៏ឆេះគ្មានសល់ ។ ចំណែកជីតាខ្ញុំមានសំណាងដែលអាចរួចផុតពីគ្រោះថ្នាក់ ។

លុះដល់ថ្ងៃទី១៧ មេសា ១៩៧៥ យោធាខ្មែរក្រហមបានចូលមករំដោះប្រជាជន នៅទីក្រុងភ្នំពេញចេញពីការគ្រប់គ្រងរបស់ លន់ នល់ ។ ខណៈនោះសំណើចសើចក្អាកក្អាយ ស្រែកអបអរសាទរជោគជ័យរបស់ខ្មែរក្រហមបានបន្លឺឡើង ដោយប្រជាជនខ្លះបានចេញទៅទទួលយោធាខ្មែរក្រហមនៅតាមដងផ្លូវ ប៉ុន្តែសម្រាប់ក្រុមខ្មែរក្រហមមិនបានសាទរជាមួយនឹងប្រជាជននោះទេ ហើយក៏មិនស្វាគមន៍ដែរ ។ ភ្លាមនោះ យោធាខ្មែរក្រហមក៏បានប្រកាសតាមស្ថានីយវិទ្យុពីជ័យជម្នះរបស់ខ្លួនថា ជាជ័យជម្នះដែលកើតឡើងដោយសារការបង្ហូរឈាម មិនមែនជាការចរចាទេ ។ ទោះបីយ៉ាងណា ពេលនោះមានមន្ត្រីខ្លះដែលធ្វើការក្នុងរបប លន់ នល់ ក៏សុខចិត្តស្លាប់ដោយបន្តរស់នៅក្នុងប្រទេស ហើយអ្នកខ្លះទៀតក៏បានរត់ភៀសខ្លួនទៅនៅក្រៅប្រទេសដោយសារការភ័យខ្លាច ។ ដោយឡែកប្រជាជនក្រីក្រ និងសាមញ្ញ ដូចជាជីតាខ្ញុំត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ក្នុងរយៈពេលតែបីថ្ងៃប៉ុណ្ណោះ ។ ដូច្នេះហើយទើបប្រជាជនខ្លះ នាំគ្នាដឹកអង្ករ ទឹកត្រី អំបិល ប្រហុកទៅតាមខ្លួន ព្រោះប្រជាជនបានស្តាប់ការប្រកាសរបស់ខ្មែរក្រហមថា បើមិននាំគ្នាចេញពីទីក្រុងភ្នំពេញទេ នោះកងទ័ពអាកាសរបស់អាមេរិកនឹងមកទម្លាក់គ្រាប់បែកកម្ទេចមិនខាន ។ ដូច្នេះដើម្បីសុខសុវត្ថិភាព ទើបអង្គការជម្លៀសប្រជាជនឲ្យចេញទៅតាមខេត្ត ។ ប្រជាជនពេលនោះនៅមានសិទ្ធិអាចជ្រើសរើសស្រុកដែលខ្លួនចង់ទៅដោយសេរី ។ ដោយឡែកភ្នំពេញ អង្គការមិនអនុញ្ញាតឲ្យមានប្រជាជនរស់នៅទេ លើកលែងតែកងយោធា ។ នៅពេលនោះ ប្រសិនបើមាននរណារឹងរូស និងមិនស្តាប់តាមបញ្ជា យោធាខ្មែរក្រហមនឹងបាញ់សម្លាប់អ្នកតវ៉ានោះនៅនឹងមុខមហាជនតែម្តង ដើម្បីជាការគំរាមដល់អ្នកផ្សេងទៀត ។

ជីតារបស់ខ្ញុំបានបណ្តើរកង់ ដោយមានចងអីវ៉ាន់សំពីងសំពោងជាមួយផង ។ គាត់ធ្វើដំណើររយៈពេលប្រមាណបីទៅ

ប្អូនថ្ងៃទើបទៅដល់ស្រុកកំណើតវិញ ។ លុះពេលទៅដល់ភូមិជីតារបស់ខ្ញុំឃើញផ្ទះឪពុកម្តាយគាត់ត្រូវភ្លើងឆេះគ្មានសល់ដែលធ្វើឲ្យគាត់សោកស្តាយយ៉ាងខ្លាំង ។ តែទោះបីយ៉ាងណា ពេលនោះក៏អង្គការមិនអនុញ្ញាតឲ្យគាត់រស់នៅភូមិចាស់ដែរ គឺគាត់ត្រូវបានផ្លាស់ឲ្យទៅរស់នៅភូមិអង្គក្រសាំង ឃុំស្នួងក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺវិញ ។ នៅទីនោះ អង្គការបានចាត់ចែងប្រជាជនឲ្យធ្វើការងារជាក្រុម និងកង ។ សម្រាប់អ្នកមិនទាន់មានគ្រួសារ (នៅលីវ) ត្រូវអង្គការបញ្ជូនទៅធ្វើការក្នុងកងចល័តយុវជន ដោយធ្វើការងារជីកព្រែក ជីកប្រឡាយ និងលើកភ្លឺស្រែ ។ ក្រៅពីក្រុម អង្គការបានបែងចែកមនុស្សធ្វើការក្នុងកងផ្សេងៗ មានដូចជា ៈ កងរយ កងហា កងពាន់ និងកងតំបន់ ក្នុងនោះមានទ័ពស្រួចដែលមានយុទ្ធជន និងយុទ្ធនារី ជាកម្លាំងស្នូល ហើយអ្នកទាំងនោះធ្វើការដោយមិនសូវមានពេលឈប់សម្រាកដូចចាស់ៗទេ ។ ចំណែកឯការហូបចុកវិញ អង្គការបានចែករបបអង្ករ និងអំបិល ឲ្យខាងចុងភៅសម្រាប់ហូបរួម ដោយក្នុងមនុស្សម្នាក់ទទួលបានបបរពីរទៅបីវែក ហើយមួយថ្ងៃទទួលបានពីរពេល ។ រៀងរាល់ពេលប្រជុំ ពេលសម្រាក ពេលហូបបាយ ពេលធ្វើការ អង្គការតែងតែគោះរគាំងដើម្បីផ្តល់ដំណឹងជាមុន ។ នៅពេលនោះ ប្រជាជនធ្វើការទៅតាមការបែងចែក និងជំនាញរៀងខ្លួន ដូចជា ជីកព្រែក ជីកប្រឡាយ និងឡើងត្នោត ដោយការងារទាំងនេះធ្វើចាប់តាំងពីម៉ោង៤ភ្លឺ រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបឈប់សម្រាកហូបបាយរយៈពេល១៥នាទី រួចបន្តធ្វើរហូតដល់ម៉ោង៥ល្ងាច ។ នៅសម័យនោះ អង្គការមិនឲ្យជីតាខ្ញុំឈប់សម្រាកទេទោះបីផុតម៉ោង៥ ហើយក៏ដោយ គឺអង្គការចាត់ឲ្យគាត់ទៅលើកទំនប់ថែមទៀត ។

ជីតាខ្ញុំធ្វើការបែបនេះជារៀងរាល់ថ្ងៃអស់រយៈពេលបីឆ្នាំ ហើយនៅពេលរដូវវស្សាចូលមកដល់ អង្គការចាត់តាំងគាត់ឲ្យមកសម្រុកដាំដំណាំវិញ ។ តែពេលនោះ ប្រសិនបើមានអ្នកធ្វើបាក់បែកឧបករណ៍សម្រាប់ដាំដំណាំម្តងជាពីរដង ច្បាស់ជាអង្គការចាប់យកទៅរៀនសូត្រមិនខាន ។ យកទៅរៀនសូត្រពេលនោះ មានន័យថា ឈ្លបដាក់ច្រវាក់ដៃ និងជើង រួចឃុំឃាំង ដោយមិនឲ្យអាហារបរិភោគ និងទឹកផឹកឡើយ ។ ជីតាខ្ញុំបានឃើញ ប្រជាជនខ្លះហូបក្តាម ខ្យងទាំងរស់ដែលរើសបាននៅតាមវាលស្រែដោយសារតែការស្រេកឃ្លាន តែនៅពេលដែលអង្គការឃើញ អង្គការប្រាកដជាចាប់ខ្លួនដោយចោទថា ធ្វើខុសនឹងវិន័យរបស់អង្គការមិនខាន ។ រៀងរាល់រដូវវស្សា អង្គការតែងបង្ខំប្រជាជនឲ្យសម្រុកធ្វើការងារ ដោយត្រូវថែមម៉ោងរហូតបំពេញភារកិច្ចតាមផែនការចប់រួចរាល់ ។

ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ ជីតាខ្ញុំមិនដែលគិតឃើញពីអនាគតប្រសើរនោះទេ គាត់ឃើញតែការបង្ខំ ការធ្វើទារុណកម្ម និងការអត់អាហារ ។ ពេលខ្លះគាត់មានអារម្មណ៍ថា បើគាត់ស្លាប់បានឆាប់គឺកាន់តែប្រសើរ ប្រសិនបើរបបខ្មែរក្រហមនៅតែបន្តដឹកនាំ ។ គាត់បានរស់នៅទាំងវេទនា និងគ្មានសេរីភាព ។ គាត់បានសរសេរពាក្យទាំងនេះដើម្បីចំណាំនៅលើថ្មដោយប្រើពូថៅ នៅពេលដែលអង្គការចាត់តាំងគាត់ឲ្យទៅកាប់ដើមឫស្សីនៅលើភ្នំ ។

នៅក្នុងឆ្នាំ១៩៧៦ ជីតាខ្ញុំក៏បានរៀបការជាមួយយាយរបស់ខ្ញុំ តែមិនបានរៀបចំទៅតាមទំនៀមទម្លាប់ប្រពៃណីទេ គឺពេលនោះគាត់គ្រាន់តែឡើងប្តេជ្ញាចិត្តនៅមុខអង្គការ និងប្រធានក្រុមប៉ុណ្ណោះ ។ ពេលរៀបការរួច អង្គការឲ្យគាត់រស់នៅបែកគ្នា គឺប្រុសរស់នៅផ្សេង ហើយស្រីរស់នៅផ្សេងតាមកងរៀងៗខ្លួន តែអង្គការបានអនុញ្ញាតឲ្យគាត់មកជួបជុំគ្នានៅផ្ទះក្នុងមួយអាទិត្យម្តង ។

នៅក្នុងរបបខ្មែរក្រហម ប្រជាជនតម្រូវឲ្យស្លៀកពាក់ខ្មៅទាំងអស់ ដូច្នេះជីតារបស់ខ្ញុំក៏បានយកសម្លៀកបំពាក់ដែលជាក្រណាត់ពណ៌មកជ្រលក់ព្រីងដើម្បីធ្វើឲ្យខ្មៅ ។

លុះដល់ឆ្នាំ១៩៧៨ ទើបម្តាយរបស់ខ្ញុំកើតមក ។ រហូតដល់ពេលម្តាយខ្ញុំអាចដើរបាន និងអាចនិយាយបានខ្លះ ក៏អង្គការហាមមិនឲ្យម្តាយខ្ញុំនិយាយពាក្យ "ម៉ាក់ប៉ា" ទៅកាន់យាយតារបស់ខ្ញុំដែរ គឺត្រូវហៅ "ម៉ែឪ ឬសមមិត្ត" ជំនួសវិញ ។ មួយឆ្នាំក្រោយមក គឺឆ្នាំ១៩៧៩ សំឡេងគ្រាប់កាំភ្លើងក៏ផ្ទុះឡើង យាយតាខ្ញុំគិតថា គាត់នឹងត្រូវបានរំដោះពីរបបឃោរឃៅនេះមិនខាន តែនៅពេលនោះគាត់ និងគ្រួសារទាំងអស់ត្រូវបានខ្មែរក្រហមកេណ្ឌយកទៅជាមួយរហូតដល់ខេត្តពោធិ៍សាត់ ។ ពេលទៅដល់ទីនោះ គាត់និងគ្រួសារក៏គេចខ្លួនត្រឡប់មកភូមិកំណើតវិញ ដោយបានធ្វើដំណើរអស់រយៈពេលកន្លះខែ ។ ក្រោយមក ជីតារបស់ខ្ញុំក៏បាននាំក្រុមគ្រួសារមករស់នៅ រកស៊ី និងធ្វើការនៅទីក្រុងភ្នំពេញរហូតមកដល់សព្វថ្ងៃ ។ **លន់ ច័ន្ទសុចិត្រា**

# ជីវិតកុមារីវ័យ៥ឆ្នាំក្នុងរបបខ្មែរក្រហម

ខ្ញុំបានជួបសម្ភាសជាមួយមីងម្នាក់ដែលមានវ័យ៤៧ឆ្នាំ អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ។ គាត់មានឈ្មោះ ណៅ នាលី សព្វថ្ងៃរស់នៅភូមិតាងួន សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ ក្រុងភ្នំពេញ ។

នាលី បានចែករំលែកបទពិសោធន៍ដ៏ជូរចត់របស់គាត់ជាមួយខ្ញុំថា ៖ គាត់មានស្រុកកំណើតនៅស្រុកគីរីវង្ស ខេត្តតាកែវ ហើយជីវិតរបស់គាត់នៅពេលនោះមានភាពលំបាកខ្លាំងណាស់ ។ គាត់រស់នៅគ្មានសិទ្ធិសេរីភាព ហើយត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការងារជាច្រើនដែលគាត់មិនចង់ធ្វើ ។ នាលី បានបន្តទៀតថា កាលនោះគាត់ទើបតែមានអាយុជាង៥ឆ្នាំប៉ុណ្ណោះ ដូច្នេះគាត់ពុំសូវយល់ច្បាស់ពីហេតុការណ៍ដែលកំពុងកើតឡើងក្នុងប្រទេសនោះទេ ។ គាត់បានចងចាំថា ពីមុនឪពុករបស់គាត់ជាទាហាន លន់ នល់ ដូច្នេះឪពុករបស់គាត់តែងតែយកម្ដាយរបស់គាត់ទៅជាមួយ ដោយទុកគាត់ និងប្អូនស្រីម្នាក់ទៀតឲ្យរស់នៅជាមួយគ្រួសារម្ដាយមីង ។ កាលនោះ នាលី បានមករស់នៅក្រុងភ្នំពេញ ដូច្នេះពេលខ្មែរក្រហមជម្លៀស គាត់ក៏ត្រូវចាកចេញទៅតាមគ្រួសារម្ដាយមីងដែរ ។ គាត់បានបន្ថែមទៀតថា ដោយសារតែមានមនុស្សច្រើននៅតាមផ្លូវដំណើរទៅខេត្តតាកែវ ក្រុមគ្រួសារគាត់ក៏បានយកខ្សែមកចងដៃគ្នាដើម្បីកុំឲ្យវង្វេង ព្រោះមានសភាពរញេរញៃយ៉ាងខ្លាំង ។ នៅពេលនោះ គាត់រកមធ្យោបាយផ្សេងៗតាមដែលអាចធ្វើបានដើម្បីរកអាហារហូប ។ លើសពីនេះ គាត់ក៏ឃើញមនុស្សស្លាប់ជាច្រើននៅតាមផ្លូវដោយសារតែទ្រាំទ្រមិនរួច ។ បន្ទាប់ពីធ្វើដំណើរដ៏វែងឆ្ងាយ គាត់បានទៅដល់ខេត្តតាកែវដែលជាស្រុកកំណើតរបស់ឪពុកម្ដាយគាត់ ។ ពេលទៅដល់ជីដូនរបស់គាត់ឈ្មោះយាយ មុំ បានទទួលយកគាត់ និងប្អូនទៅនៅផ្ទះរបស់គាត់ ហើយដាំបាយឲ្យគាត់ហូប ។ មីង នាលី បាននិយាយលាយជាមួយទឹកមុខញញឹមថា វាជាអាហារមួយពេលដ៏ឆ្ងាញ់បំផុតដែលគាត់មិនអាចបំភ្លេចបានក្នុងរយៈពេល៣ឆ្នាំនោះ ។ ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង មេភូមិបានបំបែកគាត់ដោយហេតុថាគាត់ជាប្រជាជនថ្មី ដោយអនុញ្ញាតទុកតែប្អូនរបស់គាត់រស់នៅជាមួយយាយ មុំ ។

នាលី បានទៅរស់នៅជាមួយគ្រួសារម្ដាយមីងរបស់គាត់វិញ ដោយពេលនោះខ្មែរក្រហមបញ្ជូនឲ្យទៅត្នោតជុំ ក្នុងខេត្តតាកែវវិញ ដោយខ្មែរក្រហមយកឡានធំៗមកដឹកដែលមានមនុស្សជិះប្រជ្រៀតគ្នា ។ ការចេញដំណើរមានការយឺតយ៉ាវព្រោះមានឡានជាច្រើនបន្តកន្ទុយគ្នា ។ គាត់បានទៅដល់ភូមិថ្មីពេលល្ងាចទៅហើយ ហើយនៅតាមផ្លូវគាត់ព្រួក្មេងយំលាន់ឮរំពងដោយសារតែស្រេកឃ្លាន ដូច្នេះម្ដាយមីងរបស់គាត់តែងតែលួចខ្សឹបប្រាប់គាត់កុំឲ្យយំព្រោះខ្លាចគេយកទៅសម្លាប់ ។ រហូតដល់ពេលយប់ ទើបគាត់ទទួលបានរបបបបរ តែបបរនោះមានតែទឹក និងគ្រាប់អង្ករបន្តិចបន្តិចបន្តួចប៉ុណ្ណោះ ។

នៅថ្ងៃបន្ទាប់ នាលី ត្រូវបានបញ្ជូនទៅកងកុមារដើម្បីរើសអាចម៍គោដែលក្នុងមួយថ្ងៃ គាត់ត្រូវរើសអាចម៍គោឲ្យបានមួយបង្គី ទើបប្រធានកងអនុញ្ញាតឲ្យគាត់ហូបបបរ ។ ថ្ងៃមួយដោយសារតែសេចក្ដីស្រេកឃ្លាន គាត់បានលួចហូបអំពៅជាមួយនឹងក្មេងដទៃ ដោយពុំដឹងខ្លួនថាគាត់កំពុងធ្វើខុសនឹងច្បាប់អង្គការឡើយ ដោយសារតែគាត់នៅក្មេងពេក ។ ពេលនោះ គាត់ត្រូវឈ្លបចាប់បានដោយចោទគាត់ថាចោរ រួចបំបែកគាត់ចេញពីម្ដាយមីងឲ្យទៅធ្វើការ និងរស់នៅក្នុងកងកុមារតែម្ដង ។ ទោះបីគាត់មានអាយុទើបតែជាង៥ឆ្នាំ តែគាត់ចាប់ផ្ដើមយល់ពីរឿងរ៉ាវនៅជុំវិញខ្លួនចាប់តាំងពីហេតុការណ៍នោះកើតឡើងចំពោះគាត់ ។ ការងារនៅក្នុងកងកុមារមានដូចជា រើសអាចម៍គោ និងកាប់ទន្ទ្រានខេត្រ ។ ការរស់នៅក្នុងកងកុមារមានភាពលំបាក ដូច្នេះពេលខ្លះគាត់ក៏បានទៅលួចដឹកដំឡូង អំពៅ មកហូបដើម្បីបំបាត់ការស្រេកឃ្លាន ទោះបីដឹងថាខុសវិន័យអង្គការក៏ដោយ ។ ថ្ងៃមួយគាត់បានលួចហូបកន្ទក់

យ៉ាងច្រើនដែលធ្វើឲ្យគាត់ឆ្អល់ពោះ រហូតដើរពុំរួច ។

គាត់បានបន្តរស់នៅបែបនេះរហូតដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមករំដោះ ។ ពេលគាត់កំពុងចាំស្រែ ស្រាប់តែឃើញយន្តហោះមកទម្លាក់គ្រាប់បែកពេញវាលស្រែ ។ ភ្លាមៗនោះ គាត់បានរត់ទៅកន្លែងដែលគាត់ស្នាក់នៅដើម្បីជួបប្រធានកង ។ ប្រធានកងបាននិយាយថា វៀតណាមចូលមកហើយ ដូច្នេះយើងក្មេងៗអាចត្រឡប់ទៅរកបងប្អូនវិញ ឬរត់ឡើងភ្នំជាមួយគ្នា ។ នៅពេលនោះ នាលី បានសម្រេចចិត្តរត់ទៅរកបងប្អូនវិញ ។ ដោយសារមានការទម្លាក់គ្រាប់ច្រើននៅកន្លែង នាលី ស្នាក់នៅទើបធ្វើឲ្យមីងរបស់គាត់គិតថា គាត់ប្រហែលជាស្លាប់បាត់ហើយ ដូច្នេះគ្រួសារម្ដាយមីងគាត់ក៏បានរៀបចំអីវ៉ាន់ចេញទៅ ។ តែសំណាងនាលី បានរត់មកទាន់ ហើយក៏បានរួមដំណើរចេញទៅ ។

នៅតាមផ្លូវ នាលី បានឃើញទាហានវៀតណាមដេញបាញ់ខ្មែរក្រហម ។ គាត់បានបន្តដំណើររហូតដល់ស្ពានមួយ ដែលពេលនោះគាត់ឃើញមានមនុស្សឆ្លងកាត់រាប់ពាន់នាក់ ។ ដោយសារតែចិត្តនឹកជីដូន គាត់បានសំឡឹងមើលទៅហ្វូងមនុស្សក្រែងប្រទះឃើញគាត់ ។ ជារឿងនឹកស្មានមិនដល់ នាលី បានឃើញជីដូនធ្វើដំណើរតាមរទេះជាមួយបងប្អូនដទៃទៀត ។ ខណៈនោះ នាលី បានហៅឈ្មោះជីដូនបណ្ដើរ និងរត់បណ្ដើរព្រោះខ្លាចបាត់យាយក្នុងហ្វូងមនុស្ស ។ យាយរបស់គាត់បានឮសំឡេងចៅ ក៏រត់មកឱបក្ដាយំដោយក្ដីនឹករឭក ។ នាលី និងយាយរបស់គាត់បានបន្តដំណើរទៅស្រុកគិរីវង្ស ខេត្តតាកែវ ដែលជាស្រុកកំណើត ។ ពេលដែលប្រទេសមានសន្តិភាព ម្ដាយរបស់ នាលី បានមកយកគាត់ទៅនៅភ្នំពេញរហូតមកដល់សព្វថ្ងៃ ។

ជាចុងក្រោយ នាលី បានមានប្រសាសន៍ថា ដោយសារគាត់ធ្លាប់ឆ្លងកាត់ការលំបាកក្នុងរបបខ្មែរក្រហម ដូច្នេះគាត់មិនចង់ឲ្យក្មេងជំនាន់ក្រោយបានជួបនឹងបទពិសោធន៍បែបនេះទេ ។

**ឡាង ស្រីលក្ខណ៍**



ឡាង ស្រីលក្ខណ៍ និស្សិតស្ម័គ្រចិត្តផ្នែកបកប្រែផ្នែកទស្សនាវដ្ដីស្វែងរកការពិត

# អតីតកងនារី : រៀបរាប់ជីវិតក្នុងរបបខ្មែរក្រហម រហូតមកដល់អន្លង់វែង

អ៊ំស្រី ឡូន មានអាយុ៥២ឆ្នាំ មានស្រុកកំណើតនៅស្រុកជីក្រែង ខេត្តសៀមរាប ។ ឡូន មានកូន៤នាក់ ស្ថិតនៅក្នុងវ័យសិក្សាទាំងអស់ ។ ឡូន មានប្តីឈ្មោះ រ៉ន ហើយអ្នកទាំងពីរប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ ឡូន បានរៀបរាប់ពីដំណើរជីវិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ប្រាប់មកកាន់ខ្ញុំថា ៖

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមដណ្តើមអំណាចភ្លាម ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនដោយបង្ខំឲ្យចាកចេញពីផ្ទះសម្បែងទៅកាន់ទីជនបទដាច់ស្រយាល ដោយបានប្រាប់ប្រជាជនថា ឲ្យប្រជាជនចេញតែក្នុងរយៈពេលបីថ្ងៃប៉ុណ្ណោះ ។ នៅឯស្រុកជីក្រែង ខេត្តសៀមរាប ឯណោះវិញ ខ្មែរក្រហមក៏បានធ្វើការជម្លៀសប្រជាជនទាំងបង្ខំ ហើយថែមទាំងប្រើអំពើហិង្សា និងបាញ់សម្លាប់ ចំពោះជនណាដែលមិនព្រមធ្វើតាមបញ្ជាទៀតផង ។ កាលនោះ ឡូន ត្រូវបានខ្មែរក្រហមបំបែកចេញពីក្រុមគ្រួសារជាទីស្រឡាញ់របស់គាត់ឲ្យទៅធ្វើការនៅតាមអង្គភាពដែលនៅឆ្ងាយពីភូមិ ។ ជំនាន់នោះ ប្រជាជនទាំងក្មេងចាស់ ប្រុសស្រី ត្រូវបានខ្មែរក្រហមបញ្ជាឲ្យស្លៀកពាក់ឯកសណ្ឋានខោអាវពណ៌ខ្មៅគ្រប់ៗគ្នា ។


ឡួន លីណា សិស្សថ្នាក់ទី១២ វិទ្យាល័យអន្លង់វែង

ឡូន ត្រូវបានខ្មែរក្រហមចាត់តាំង ឲ្យលើកទំនប់ ភ្លឺស្រែ និងជីកប្រឡាយ ស្ទើរតែគ្មានពេលឈប់សម្រាក ។ កាលនោះថ្វីត្បិតតែ ឡូន មិនត្រូវបានខ្មែរក្រហមធ្វើបាប វាយដំដោយផ្ទាល់ក៏ពិតមែន តែគាត់ក៏មានអារម្មណ៍ឈឺចាប់ដូចប្រជាជនដទៃទៀតដែរ ។ ឡូន បានប្រាប់ឲ្យដឹងថា ខ្មែរក្រហមបានប្រព្រឹត្តអំពើដ៏ព្រៃផ្សៃ មកលើប្រជាជនកម្ពុជា រួមទាំងអ្នកចេះដឹង ចំណែកព្រះសង្ឃត្រូវបានខ្មែរក្រហមចាប់ផ្សឹក ។ ខ្មែរក្រហមបានប្រែក្លាយទីវត្តអារាមឲ្យទៅជាគុកឃុំឃាំងមនុស្ស ធ្វើទារុណកម្ម ឬធ្វើជាឃ្លាំងសម្រាប់ដាក់អាវុធ ឬដាក់សម្ភារផ្សេងៗ ។ ឡូន មិនដែលទទួលបានការសិក្សាអប់រំទេកាលពីជំនាន់នោះ ។ ចំពោះការរៀបអាពាហ៍ពិពាហ៍វិញ ខ្មែរក្រហមបានរៀបការម្តងៗមួយរយគូ ហើយអ្នកខ្លះត្រូវបានចាប់បង្ខំឲ្យរៀបការទាំងសាម៉ីខ្លួនមិនពេញចិត្ត តែដើម្បីរក្សាជីវិតអ្នកទាំងនោះត្រូវតែទ្រាំរស់ទាំងលំបាកវេទនា ។ ឡូន បានប្រាប់ឲ្យដឹងថា ពេលសុំច្បាប់ឈឺម្តងៗ អង្គការមិនដែលអនុញ្ញាតឲ្យគាតឈប់សម្រាកទេ ហើយថែមទាំងនិយាយចំអកឲ្យថា “គ្រុនញាក់ គ្រុនញ័រ គ្រុនគ្រាក់ទ័រ គ្រុនឡាន គ្រុនបាយបានគឺគ្រុនសតិអារម្មណ៍” ទៀតផង ។ ចំពោះការបរិភោគវិញ ឡូន បានឲ្យដឹងថា បើបានដំឡូង ឬត្រាវហូបនោះ គឺវាសំណាងណាស់ទៅហើយ តែផ្ទុយទៅវិញ

របបអាហាររបស់យើង គឺមានតែបបររាវកក្លូក ស្មើររកគ្រាប់អង្ករគ្មាន ហើយបើអ្នកណាទៅទាន់បានហូប តែបើអ្នកណាទៅ មិនទាន់នោះទេ ច្បាស់ជាអត់របប ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា រួមជាមួយកងទ័ពវៀតណាម បានវាយរំលំរបបខ្មែរក្រហម និងបានរំដោះប្រជាជននៅទូទាំងប្រទេសកម្ពុជាពីរបបខ្មែរក្រហម ។ ទោះបីយ៉ាងណា ខ្មែរក្រហមបានរត់ទៅរស់នៅក្នុងព្រៃតាមបណ្តោយព្រំដែនខ្មែរ-ថៃ និងនៅតាមជួរភ្នំដងរែក រួមទាំងតំបន់អន្លង់វែង ដែលគ្រប់គ្រងដោយ តាម៉ុក ។ ពេលនោះ ជីវភាពរបស់ប្រជាជនហាក់មានភាពល្អប្រសើរជាងមុន ។ តាម៉ុក បានកសាងផ្លូវ សាលារៀន មន្ទីរពេទ្យ ស្ពាន ហើយបានផ្គត់ផ្គង់ស្បៀងអាហារដល់ប្រជាជនថែមទៀត មានដូចជា ស្ករ អំបិល ប្រហុក អង្ករ និងថ្នាំសង្កូវផ្សេងៗ ។ នៅពេលនោះដែរ ប្រជាជនក៏មានសិទ្ធិសេរីភាពជាងមុន ហើយ ឡូន ក៏បានចូលរួមធ្វើការងារនៅក្នុងអង្គភាពនារី ។ ក្រោយពេលខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលមក ប្រជាជនបានចាប់ផ្តើមកសាងជីវភាពថ្មីក្នុងគ្រួសារឡើងវិញ ។

ចុងក្រោយ ឡូន មានប្រសាសន៍ថា គាត់ចង់ឲ្យរដ្ឋាភិបាលអភិរក្សតំបន់ប្រវត្តិសាស្ត្រអន្លង់វែងនេះ ព្រោះតំបន់នេះជាតំបន់កាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម ។ ម្យ៉ាងទៀត ការអភិរក្សតំបន់នេះ ដើម្បីជាភស្តុតាងឲ្យក្មេងជំនាន់ក្រោយធ្វើការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនដែលបានកើតមានឡើងនៅក្នុងអតីតកាលដែរ ។ ឡូន ក៏បានលើកឡើងពីព្រៃឈើដែលជាសម្បត្តិធម្មជាតិរបស់ប្រទេសកម្ពុជា ដែលត្រូវបានរងនូវការកាប់បំផ្លាញរបស់មនុស្សមួយក្រុមតូច ដែលនាំមកនូវផលប៉ះពាល់ជាច្រើន ពិសេសគ្រោះធម្មជាតិ និងការកើនកម្តៅរបស់ផែនដីនៅតំបន់នេះដែរ ។ ឡូន អំពាវនាវឲ្យមានការថែរក្សាព្រៃឈើ ក៏ដូចជាការដាំដើមឈើឡើងវិញ ដើម្បីជួយទប់ស្កាត់នូវគ្រោះមហន្តរាយផ្សេងៗដែលនឹងកើតមានឡើង ។

**ខួន លីណា**



ចម្ការដំឡូងមីនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# ដំណើរជីវិតយាយ វ៉ា ប៉ុក ឆ្លងកាត់របបខ្មែរក្រហម

លោកយាយ វ៉ា ប៉ុក សព្វថ្ងៃអាយុ៧៨ឆ្នាំ ស្វាមីរបស់គាត់ឈ្មោះ ប៊ុត រឿន (សព្វថ្ងៃបានទទួលមរណភាពហើយដោយជំងឺ) និង មានកូន៨នាក់ (ប្រុស៤ ស្រី៤) ។ ប៉ុក បានរៀបរាប់ប្រាប់អំពីដំណើរជីវិតដែលបានឆ្លងកាត់របបខ្មែរក្រហមប្រាប់ខ្ញុំថា៖

គាត់មានស្រុកកំណើតនៅភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម ។ ប៉ុក និងស្វាមីប្រកបរបរធ្វើស្រែចម្ការ និងមានជីវភាពសមរម្យ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះ ខ្មែរក្រហមបានជម្លៀសប្រជាជនពីទីក្រុងមកជនបទដោយយកលេសថា អាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅទីក្រុង ។ នៅពេលនោះក្នុងប្រទេសទាំងមូលមានភាពច្របូកច្របល់យ៉ាងខ្លាំង ។ ចំពោះអ្នកដែលមានទ្រព្យសម្បត្តិ ហើយយកទៅជាមួយត្រូវខ្មែរក្រហមដកហូតដាក់ជាទ្រព្យសម្បត្តិរួមទាំងអស់ ។

ប៉ុក បានបន្តទៀតថា គាត់ក៏បានចូលរួមប្រជុំជាមួយនឹងប្រជាជនដទៃទៀតទៅតាមការរៀបចំរបស់អង្គការដែរ ដោយបានណែនាំអំពីមេដឹកនាំប្រចាំភូមិរបស់គាត់ឈ្មោះ សួង ។ ក្នុងការប្រជុំនោះអង្គការក៏បានចែកអង្ករ និងសម្ភារប្រើប្រាស់ដល់ប្រជាជនដែលបានចូលរួមប្រជុំ ។ ប៉ុក បានបញ្ជាក់ថា ប្រជាជនស្រីៗ រួមទាំងគាត់ អង្គការឲ្យធ្វើការងារជាប្រចាំថ្ងៃគឺបញ្ជាន់ស្រូវ និងកិនស្រូវ ។ ប៉ុក បានរំឮកថា ការរស់នៅនាសម័យនោះមានភាពវេទនាខ្លាំងណាស់ គឺត្រូវធ្វើការលើសកម្លាំង បរិភោគមិនគ្រប់គ្រាន់ដោយហូបបបរដែលមានគ្រាប់អង្ករពីរទៅបីគ្រាប់ទៅតាមកន្ធែងដែលអង្គការចែកឲ្យ ។ នៅពេលដែលកូនៗរបស់គាត់ធ្លាក់ខ្លួនឈឺពុំមានពេទ្យព្យាបាលទេ ហើយអង្គការក៏មិនរវល់ជាមួយដែរ ។ សាលារៀនត្រូវបានកម្ទេច ឬយកធ្វើជារោងបាយ ហើយវត្តអារាមត្រូវប្រែក្លាយជាគុកដាក់អ្នកទោស និងបានលុបបំបាត់ទំនៀមទម្លាប់ប្រពៃណីជំនឿសាសនាចោលទាំងអស់ ។

ចំណែកឯការរៀបការវិញ គឺអង្គការជាអ្នករៀបចំឲ្យដែលធ្វើឡើងចាប់ពី៥០គូ ទៅ១០០គូ ដោយឲ្យខាងប្រុស និងស្រីឡើងមកចាប់ដៃគ្នា និងធ្វើការប្ដេជ្ញាចំពោះមុខអង្គការថា នឹងនៅបម្រើអង្គការអស់មួយជីវិត ។ នៅពេលចប់កម្មវិធី សួង ដែលជាអ្នកគ្រប់គ្រងភូមិ បានចាត់ឲ្យឈ្លបតាមមើល និងតាមដានថា ប្ដីប្រពន្ធទាំងនោះ ព្រមនៅជាមួយគ្នាដែរឬអត់ ។ បើមិនព្រមនៅជាមួយគ្នាទេ ត្រូវយកទៅសម្លាប់ចោល ហើយបើស្រឡាញ់គ្នាពេកក៏ត្រូវយកទៅសម្លាប់ចោលដែរ ។ នៅពេលយប់ សួង និងកងឈ្លបបានដើរមើលតាមផ្ទះរបស់ប្រជាជនដើម្បីស៊ើបរកអ្នកដែលលួចនិយាយអាក្រក់ពីអង្គការ ប្រសិនបើឃើញជនណាម្នាក់និយាយអាក្រក់ពីអង្គការ អ្នកទាំងនោះនឹងត្រូវយកទៅសម្លាប់ចោលទាំងគ្រួសារភ្លាមៗ ដើម្បីទុកជាការព្រមានដល់អ្នកផ្សេងទៀត ។ ការសម្លាប់មនុស្សចេះតែកើតមានជារៀងរាល់ថ្ងៃ ។

ប៉ុក បន្តប្រាប់ដោយទឹកមុខក្រៀមក្រំថា ប្ដីរបស់គាត់ត្រូវបានកងឈ្លបចាប់យកទៅឃុំឃាំងពីរយប់បីថ្ងៃ ដោយសារគាត់និយាយចម្អកឲ្យកម្មាភិបាលខ្មែរក្រហមថា «អាវខ្មៅ ខោខ្មៅ ម៉េចក៏មិនបង់ក្រមាខ្មៅដែរទៅ? ម៉េចអស់លោកបង់ក្រមាក្រហមអីចឹង?» ពាក្យទាំងអស់នេះហើយធ្វើឲ្យកម្មាភិបាលខ្មែរក្រហមមិនសប្បាយចិត្ត និងបញ្ជាឲ្យឈ្លបចាប់គាត់ ។ តែជាសំណាងដោយសារប្ដីរបស់យាយ ប៉ុក ជាមនុស្សល្អ និងមានកម្មាភិបាលម្នាក់ស្រឡាញ់អាណិតគាត់ ទើបបញ្ជាឲ្យឈ្លបដោះលែង ។ កម្មាភិបាលនោះនិយាយថា តានេះជាអ្នកពូកែធ្វើចម្ការ និងដាំដំណាំ ហេតុនេះទុកតានេះគ្រាន់ធ្វើការបម្រើអង្គការបន្តទៀត ជាការលុបលាងកំហុស ។

នៅឆ្នាំ១៩៧៦-៧៧ ខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាម ។ អង្គការបានប្រមូលក្មេងប្រុសជំទង់ៗទៅធ្វើជាកងទ័ពប្រយុទ្ធនឹងវៀតណាម ។ ការដើរប្រមូលនេះមាននៅតាមភូមិនីមួយៗ អ្នកខ្លះយំអង្វរ អ្នកខ្លះរត់គេច តែទោះបីមិនព្រមទៅក៏អង្គការចាប់បង្ខំយកទៅដែរ ។ ក្នុងចំណោមអ្នកទាំងអស់នោះក៏មានប្អូន និងកូនទីមួយរបស់ ប៉ុក បានទៅនឹងគេដែរ ។ ក្នុងការធ្វើសង្គ្រាមជាមួយនឹងវៀតណាមនេះ ខ្លះមានជីវិត និងខ្លះទៀតក៏បាត់បង់ជីវិតនៅសមរភូមិ ហើយប្អូនរបស់ ប៉ុក ក៏ត្រូវស្លាប់នៅពេលធ្វើសង្គ្រាមនោះទៅ ។ ចំណែកឯកូនរបស់ ប៉ុក វិញសំណាងល្អត្រូវបានក្រុមខ្មែរសជួយសង្គ្រោះទាន់ពេលវេលា ។ ខ្មែរសបានកាត់កេណ្ឌទាហានដែលអង្គការចាត់ទៅប្រយុទ្ធជាមួយវៀតណាមបានពាក់កណ្តាល ហើយក្នុងនោះក៏មានកូនទីមួយរបស់ ប៉ុក ដែរ ។ តែការកេណ្ឌនោះ មិនមែនឲ្យទៅនៅតាមលំនៅដ្ឋានរៀងៗខ្លួនវិញទេ គឺត្រូវមកប្រយុទ្ធជាមួយខ្មែរក្រហមវិញ ។

នៅដើមឆ្នាំ១៩៧៩ លោក ហេង សំរិន និងសមាជិកដទៃទៀត បានរំដោះប្រទេសកម្ពុជា និងប្រជាជនកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហម ។ ក្រុមគ្រួសាររបស់ ប៉ុក និងអ្នកភូមិដទៃផ្សេងទៀតបានមានសេរីភាពឡើងវិញ រួចផុតអំពីការគាបសង្កត់ ការធ្វើការងារលើសកម្លាំង និងការធ្វើបាបគ្រប់បែបយ៉ាងពីសំណាក់ខ្មែរក្រហម ។ ក្រុមគ្រួសារ ប៉ុក ក៏បានចាប់ផ្តើមជីវិតថ្មី ដោយប្រកបរបរធ្វើស្រែចម្ការ និងដាំដំណាំ ។ ចំពោះដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅពេលបច្ចុប្បន្ននេះ ប៉ុក បានផ្តល់ជាទស្សនៈផ្ទាល់ខ្លួនថា ការកាត់ទោសចំពោះមេដឹកនាំខ្មែរក្រហម គាត់មិនលម្អៀងទៅខាងណាឡើយ គឺអ្នកធ្វើខុស ត្រូវតែទទួលទោសតាមច្បាប់ ។

**ស៊ីម ស្រីនីត**



អ្នកភូមិនេសាទត្រីនៅបឹងតាម៉ុក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# ហូរ ចូច រំឭកពីជីវិតរស់នៅក្នុងរបបខ្មែរក្រហម

ហូរ ចូច មានអាយុ ៥១ឆ្នាំ រស់នៅភូមិប្រលានឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ គាត់មកពីខេត្តព្រះវិហារ ប្រពន្ធរបស់គាត់ឈ្មោះ ហម ណាយ អាយុ៤៥ឆ្នាំ អ្នកទាំងពីរមានកូនពីរនាក់ និងកូនចិញ្ចឹមប្រាំបីនាក់ផ្សេងទៀត ។ សព្វថ្ងៃ ចូច ជាកសិករ ។ ចូច បាន រៀបរាប់ប្រាប់ខ្ញុំពីដំណើរជីវិតរបស់គាត់ដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមដូចខាងក្រោមនេះ ៖

ស្ថិតនៅក្នុងខេត្តព្រះវិហារ កាលពីសម័យ លន់ នល់ ចូច មានអាយុប្រមាណ ១២-១៣ឆ្នាំប៉ុណ្ណោះ ។ ចូច បានប្រាប់ថា នៅសម័យ លន់ នល់ មានសង្គ្រាមរវាងរបបសាធារណរដ្ឋខ្មែរ ដែលគ្រប់គ្រងដោយលោកសេនាប្រមុខ លន់ នល់ និងអ្នកដែលស្រឡាញ់សម្តេច សីហនុ ។ របប លន់ នល់ កើតឡើងពីការធ្វើរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ដើម្បីដណ្តើមអំណាចក្រោមការជួយឧបត្ថម្ភ និងគាំទ្រពីប្រទេសមហាអំណាចសហរដ្ឋអាមេរិក ។ របប លន់ នល់ ដែលគាំទ្រដោយសហរដ្ឋអាមេរិក មានគោលបំណងចង់បណ្តុះលទ្ធិសេរីនៅក្នុងប្រទេសកម្ពុជា ។ អាមេរិកក៏បានផ្តត់ផ្គង់ជាស្បៀងអាហារ និងគ្រឿងសព្វាវុធដល់របបសាធារណរដ្ឋខ្មែរ ដើម្បីផ្តួលរំលំរដ្ឋាភិបាលរបស់សម្តេចសីហនុ ។ ចាប់ពីពេលនោះមក ប្រទេសកម្ពុជាបានចាប់ផ្តើមកើតមានសង្គ្រាមក្នុងស្រុក ហើយបានគំរាមកំហែងដល់អាយុជីវិតរបស់ប្រជាជន ធ្វើឲ្យប្រជាជនជួបការលំបាកក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិត ។

ចូច បានបន្តឲ្យដឹងថា យន្តហោះរបស់អាមេរិកបានមកទម្លាក់គ្រាប់បែកលើទឹកដីកម្ពុជាយើងដូចគ្រាប់ភ្លៀង ក្រោយមកបានបន្សល់ទុកនូវស្លាកស្នាមជារណ្តៅដូចរន្ធបាយខុមជាច្រើន ធ្វើឲ្យប្រជាជនមានការភ័យខ្លាច ។ ទោះបីរបប លន់ នល់ កើតមានសង្គ្រាមក៏ពិតមែន តែការរស់នៅរបស់ប្រជាជន គឺមានសកម្មភាពជាធម្មតា មានទីផ្សារ មានវត្តអារាម មានសាលារៀន និងមានការចាយលុយកាក់ជាធម្មតា ។ ឯការរស់នៅរបស់ប្រជាជនមានសិទ្ធិសេរីភាព គ្មានការរឹបអូសទ្រព្យសម្បត្តិ ឬ ប្រមូលមកទុកដាក់ជារបស់រួមនោះទេគឺប្រជាជនមានកម្មសិទ្ធិផ្ទាល់ខ្លួន ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានវាយបណ្តេញរបបសាធារណរដ្ឋខ្មែរ ហើយបានកាន់កាប់អំណាចទាំងស្រុង ។ ក្រោយពីខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងហើយ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងបង្ខំឲ្យចាកចេញពីទីក្រុងឲ្យមករស់នៅតាមជនបទដាច់ស្រយាលធ្វើស្រែចម្ការ ។ ពេលនោះ ខ្មែរក្រហមដឹកនាំប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសមួយដែលគ្មានអ្នកមាន និងគ្មានអ្នកក្រ ប្រជាជនរស់នៅស្មើភាពគ្នា ចុះប្រឡូកធ្វើស្រែចម្ការបង្កបង្កើនផលដូចៗគ្នា ។ ខ្មែរក្រហមបានលុបបំបាត់ទីផ្សារ មិនឲ្យចាយលុយ ហើយជំនឿសាសនា ក៏ត្រូវបានហាមឃាត់ មិនតែប៉ុណ្ណោះ ទ្រព្យសម្បត្តិ និងសម្ភារផ្សេងៗ ត្រូវបានខ្មែរក្រហមរឹបអូសយកមកដាក់រួមធ្វើជារបស់សមូហភាព មិនអនុញ្ញាតឲ្យមានកម្មសិទ្ធិឯកជនឡើយ ។

ចូច បានឲ្យដឹងទៀតថា ខ្មែរក្រហមបានចាប់បង្ខំព្រះសង្ឃឲ្យលាចាកសិក្ខាបទ ហើយបញ្ជូនឲ្យទៅធ្វើស្រែចម្ការ ជីកប្រឡាយ លើកទំនប់ និងធ្វើការងារនៅតាមវាលស្រែដូចជាប្រជាជនឯទៀតដែរ ។ ចំណែកវត្តអារាម និងសាលារៀន ត្រូវបានរុះយកឈើទៅធ្វើជារោងបាយរួម ឬរោងសម្រាប់ដេករួម ឬធ្វើជាឃ្លាំងសម្រាប់ដាក់សម្ភារប្រើប្រាស់ផ្សេងៗ ។ នៅពេលដែលប្រជាជនជម្លៀសមកដល់ជនបទហើយ ខ្មែរក្រហមបានបំបែកប្រជាជនឲ្យរស់នៅដោយឡែកៗពីគ្នា ។ បុរសត្រូវរស់នៅជាមួយក្រុមបុរស នារីត្រូវរស់នៅកន្លែងសម្រាប់នារី រីឯក្មេងៗវិញ ខ្មែរក្រហមបានបង្កើតជាកងកុមារ ហើយឲ្យរស់នៅជាក្រុមជាមួយគ្នា ដោយមាន

អ្នកគ្រប់គ្រងម្នាក់ ដែលហៅថាគ្រូៗ សម្រាប់មើលការខុសត្រូវចំពោះកុមារទាំងអស់នោះ ។ ចំណែកមនុស្សចាស់ជរាដែលដើរទៅធ្វើការ នៅតាមការដ្ឋានឆ្ងាយៗពីភូមិមិនបាន ខ្មែរក្រហមបានឲ្យពួកគាត់ (យាយៗ) មើលថែកុមារតូចនៅតាមភូមិ ឯតាៗវិញត្រូវបានចាត់ឲ្យធ្វើជាបង្គី ធ្វើកញ្ច្រែង ឬវេញខ្សែគោជាដើម ។ មនុស្សដែលមានកម្លាំងពេញ ខ្មែរក្រហមបានចាត់ឲ្យទៅធ្វើស្រែ លើកប្រឡាយ លើកទំនប់ ឆ្ការព្រៃ កាស់គល់ ដើម្បីវាតដីធ្វើស្រែចម្ការ ។ ចំណែកក្មេងៗដែលមានអាយុក្រោមដប់ឆ្នាំវិញ ខ្មែរក្រហមបានចាត់ឲ្យដើររើសអាចម៍គោតាមភូមិ និងរើសគួរស្រូវនៅតាមវាលស្រែក្បែរៗភូមិដែលខ្លួនរស់នៅ ។

នៅសម័យខ្មែរក្រហម ប្រជាជនទាំងអស់ត្រូវរស់នៅរួមគ្នា ហូបរួមគ្នា ធ្វើការរួមគ្នា គ្មានកម្មសិទ្ធិឯកជនទេ ហើយរបបអាហារដែលអង្គការផ្ដល់ឲ្យប្រជាជនហូប គឺមានតែបបររាវសុទ្ធតែទឹកលាយជាមួយពោត ដើមចេក ដើមល្ហុង ហើយការផ្ដល់អាហារទៀតសោត ក៏មិនបានគ្រប់គ្រាន់ដែរ ក្នុងមួយថ្ងៃបានរបបតែពីរពេលប៉ុណ្ណោះ ។ ហេតុនេះ ដើម្បីបំពេញនូវសេចក្ដីស្រេចឃ្លានម្នាក់ៗត្រូវដើរបេះត្រកួន ស្លឹកដំឡូងឈើ ដំឡូងជ្វា និងបន្លែផ្សេងៗទៀតឲ្យតែហូបកើត យកមកលាយជាមួយនឹងរបបបបរ ដើម្បីឲ្យក្រពះបានឆ្អែត ។ ប្រជាជនត្រូវបានចេញទៅធ្វើការងារ ពីព្រលឹមទល់ព្រលប់ ស្ទើរគ្មានពេលឈប់សម្រាក ។ ដោយសារការបរិភោគអាហារមិនគ្រប់គ្រាន់ ហើយណាមួយហូបរបស់ផ្ដេសផ្ដាសផងនោះរួមផ្សំនឹងការធ្វើការងារលើសកម្លាំង បានធ្វើឲ្យប្រជាជនធ្លាក់ខ្លួនឈឺ គ្មានថ្នាំព្យាបាល គ្មានពេទ្យដែលមានជំនាញច្បាស់លាស់ដើម្បីព្យាបាលជំងឺ បណ្ដាលឲ្យប្រជាជនជាច្រើននាក់ស្លាប់ ។ ចូច បានបញ្ជាក់ឲ្យដឹងថា ថ្នាំសម្រាប់ព្យាបាលជំងឺកាលពីជំនាន់នោះ គឺមានតែថ្នាំគ្រាប់ពណ៌ខ្មៅៗ ដូចជាអាចម៍ទន្សាយអ៊ីចឹង ។ រីឯការរៀប



កងយោធាខ្មែរក្រហម ដើរចូលបន្ទាយទាហាននៅក្នុងទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ចំគ្រួសារវិញ គឺស្ថិតនៅលើអង្គការជាអ្នកកំណត់ ។ យុវជន យុវនារី មិនមានសិទ្ធិក្នុងការជ្រើសរើសគូស្រករដោយខ្លួនឯងទេ ។ ចូច បានប្រាប់ថា ពិធីរៀបការនៅសម័យខ្មែរក្រហម គឺរៀបចំគ្រួសារម្តងៗ មានចំនួនពីដប់គូទៅម្ភៃគូ ឬមានចំនួនលើសនេះទៀត ហើយការរៀបការនេះទៀត គឺគ្មានធ្វើពិធីអ្វីច្រើននោះទេ គឺគ្រាន់តែអង្គការប្រកាសហៅឈ្មោះយុវជន ឲ្យចាប់ដៃជាមួយយុវនារីដែលជាគូរបស់ខ្លួន បន្ទាប់មក អ្នកទាំងពីរត្រូវធ្វើការប្តេជ្ញាចិត្តថា នឹងខិតខំធ្វើការបម្រើបក្ស បម្រើប្រជាជនឲ្យអស់ពីចិត្តពីថ្លើម ។ បន្ទាប់មក ក៏មានពិធីហូបចុកបន្តិចបន្តួចជាកិច្ចបញ្ចប់នៃការរៀបអាពាហ៍ពិពាហ៍នេះ ។

របបខ្មែរក្រហម ជារបបមួយដែលប្រជាជនបានដឹងថា ជារបបឃោរឃៅ និងសាហាវបំផុត ដោយមេដឹកនាំខ្មែរក្រហមបានប្រើមនុស្សឲ្យធ្វើការគ្មានពេលសម្រាក បង្អត់អាហារ និងសម្លាប់គ្មានត្រាប្រណី ។ ចូច បានប្រាប់បន្តថា សមាជិកគ្រួសាររបស់គាត់ជាច្រើននាក់ រួមនឹងប្រជាជនផ្សេងទៀត ត្រូវបានខ្មែរក្រហមសម្លាប់ចោល ដោយចោទថា ជាខ្សែរយៈ សេ.អ៊ី.អា និងក្រុមដែលក្បត់នឹងអង្គការ ។

ចូច បានឲ្យដឹងថា ពេលគាត់ដើរទៅព្រៃនៅក្រោយផ្ទះ គាត់បានឃើញកូនក្មេងត្រូវឈ្លបចាប់ជើងបោក និងកាត់ដើមល្មៀងយកមកវាយ និងបោះចូលរណ្តៅ ។ នៅសម័យនោះខ្មែរក្រហមរើសអើងពួកសក្តិភូមិ ។ មេដឹកនាំខ្មែរក្រហមបានចាត់ទុកអ្នកដែលជម្លៀសមកពីទីក្រុងថា ជាពួកសក្តិភូមិ ជាពិសេស អ្នកដែលមានស្បែកសៗ ឬធ្វើការមិនពេញដៃពេញជើង ។ អ្នកមកពីទីក្រុងនិងមានស្បែកសងាយប្រឈមនឹងការយកទៅរៀនសូត្រ ឬយកទៅសម្លាប់ចោល ដោយអង្គការគិតថា ពួកអ្នកដែលជិះជាន់កម្លាំងញើសឈាមគេ ។ នៅសម័យខ្មែរក្រហមមានមនុស្សស្លាប់ប្រហែលជា ៣.៣១៤,៧៦៨ នាក់ គឺស្លាប់ដោយសារការសម្លាប់ ស្លាប់ដោយសារជំងឺ ស្លាប់ដោយសារគ្មានចំណីអាហារបរិភោគគ្រប់គ្រាន់ ។ ការសម្លាប់ប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់នេះ ដោយសារការដឹកនាំរបស់អ្នកដឹកនាំដែលមិនមានការជឿទុកចិត្តប្រជាជន គិតខ្លាចប្រជាជនមានការបះបោរ ប្រឆាំងនឹងអង្គការ ជាពិសេសក្រុមបញ្ញវន្តដែលមានចំណេះដឹងខ្ពង់ខ្ពស់ មេដឹកនាំរបប លន់ នល់ និងពួកសក្តិភូមិ ។ មេដឹកនាំនៅសម័យខ្មែរក្រហម បានដាក់អ្នកស៊ើបការណ៍នៅតាមភូមិឃុំរបស់ខ្លួនមិនឲ្យប្រជាជនធ្វើតាមចិត្តរបស់ខ្លួននោះឡើយសូម្បីតែដាំដំណាំដែលខ្លួនឯងមាននៅតាមផ្ទះក៏មិនអាចយកទៅបរិភោគបានដែរ បើអង្គការដឹង អង្គការនឹងយកទៅដាក់គុក ឬយកទៅរៀនសូត្រ ។ នៅសម័យខ្មែរក្រហមប្រជាជនខ្មែរយើងតែងតែខ្លាចពាក្យដែលគេថាយកទៅរៀនសូត្រ គឺគាត់ខ្លាចដោយសារអ្នកដែលត្រូវគេយកទៅរៀនសូត្រ មិនដែលឃើញបានត្រឡប់មកផ្ទះវិញទេ ។ មេដឹកនាំនៅសម័យខ្មែរក្រហមបានប្រើពាក្យទុកមិនចំណេញដកចេញក៏មិនខាត ហើយពួកគេបានប្រាប់ប្រជាជនមិនឲ្យជឿលើអ្វីៗ គោរព ស្រឡាញ់បងប្អូន យាយតាឪពុកម្តាយឡើយ គឺឲ្យមនុស្សទាំងអស់គ្នាជឿលើអង្គការ គោរពស្រលាញ់តែអង្គការមួយគត់ ។ អ្នកដឹកនាំនៅសម័យខ្មែរក្រហមយកពាក្យអង្គការមកនិយាយ បើបញ្ជាឲ្យប្រជាជនធ្វើអ្វី គឺគេប្រើពាក្យថាបញ្ជារបស់អង្គការថ្នាក់លើបានបញ្ជាមក ។ កម្មាភិបាលយកពាក្យអង្គការថ្នាក់លើមកគំរាមកំហែងប្រជាជនឲ្យធ្វើការតាមបញ្ជារបស់ខ្លួន បើអ្នកណាធ្វើការមិនសូវពេញដៃពេញជើងខ្មែរ



ប្រជាជនត្រូវបានជម្លៀសចេញពីផ្ទះសម្បែងបន្ទាប់ពីកងយោធាខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ក្រហមថាអ្នកនោះមានជំងឺសតិអារម្មណ៍ ឬមិនពេញចិត្តនឹងការដឹកនាំរបស់អង្គការ ។ ខ្មែរក្រហមបានឲ្យអ្នកស៊ើបការណ៍ដើរស៊ើបពេលយប់បន្ថែមទៀតបើអ្នកណានិយាយមិនល្អ ឬលាក់អ្វី គេនឹងឲ្យឈ្លបចាប់យកទៅរៀនសូត្រ ឬយកទៅដាក់គុក ។ ជីវិតរស់នៅក្នុងរបបខ្មែរក្រហម មនុស្សទាំងអស់គ្នាតែងតែគិតថាថ្ងៃនេះគេថ្ងៃក្រោយប្រហែលជាខ្លួនឯងហើយមើលទៅ ។ ប្រជាជនមានការភ័យខ្លាចដោយសារតែជួបប្រទះនឹង ការសម្លាប់របស់កម្មាភិបាលដោយគ្មានមូលហេតុ និងមានលក្ខណៈព្រៃផ្សៃឃោរឃៅបំផុត ។

ចូច បាននិយាយថា ខ្មែរក្រហមបានសម្លាប់ឪពុកគាត់នៅនឹងមុខ ធ្វើឲ្យគាត់មានចិត្តខឹង និងចង់ដឹងថាតើអ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់សាច់ញាតិ និងប្រជាជនខ្មែរយើង ។ ចូច បានបន្តថា គាត់បានចូលធ្វើខ្មែរក្រហមនៅចុងឆ្នាំ១៩៧៩ ដោយសារចង់ដឹងថា អ្នកណាជាអ្នកបញ្ជាឲ្យសម្លាប់គ្រួសារគាត់ និងប្រជាជនខ្មែរ ។ គាត់ចូលធ្វើខ្មែរក្រហម គ្មាននរណាមកបង្ខិតបង្ខំនោះទេ គឺគាត់ចូលធ្វើដោយខ្លួនឯង ។ នៅពេលគាត់ចូលធ្វើជាខ្មែរក្រហមគាត់បានមកធ្វើការនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ គាត់ក៏បានជួបនឹង ប៉ុល ពត ផ្ទាល់នៅពេលដែលខ្មែរក្រហមហៅគាត់ឲ្យទៅប្រជុំនៅភ្នំដងរែក ។ គាត់បានសង្កេតមើលចរិតលក្ខណៈរបស់ ប៉ុល ពត ឃើញថា ប៉ុល ពត ជាមនុស្សដែលមានសណ្ដានចិត្តល្អ គាត់ជាមនុស្សស្លូតបូត ចេះស្រឡាញ់ជីវិតប្រជាជន និងចេះស្រឡាញ់ទឹកដី ។ ប៉ុល ពត មិនដែលបានបញ្ជាឲ្យសម្លាប់ប្រជាជននោះទេ ។ ការសម្លាប់ប្រជាជននេះដោយសារតែថ្នាក់ដឹកនាំជាន់ក្រោមដែលមានគំនិតជ្រុលនិយមពេក ហើយយកលេសថា ជាបញ្ជារបស់អង្គការថ្នាក់លើមកនិយាយដើម្បីគំរាម ឬសម្លាប់ប្រជាជន ។ ចូច បាននិយាយទៀតថា អ្នកដឹកនាំធំៗមិនបានដឹងរឿងបញ្ជាឲ្យសម្លាប់ប្រជាជនណាដែលក្បត់នឹងអង្គការនោះឡើយ ។ ការគ្រប់គ្រងរបស់កម្មាភិបាល សហករណ៍គឺបានធ្វើខុសនឹងការដឹកនាំដែលថ្នាក់លើបានដាក់ឲ្យធ្វើ ។ ចូច បានធ្វើជាខ្មែរក្រហម និងបានរស់នៅជាមួយ ប៉ុល ពត ឃើញថាការដឹកនាំរបស់គាត់ គឺមានភាពល្អប្រសើរមានការហូបចុកគ្រប់គ្រាន់គ្មានគំនិតឃោរឃៅដូចអ្នកដែលធ្វើការនៅថ្នាក់ក្រោមនោះទេ ។

ចូច បាននិយាយប្រាប់ខ្ញុំថា ការគ្រប់គ្រងរបស់ តាម៉ុក គឺមានភាពខុសឆ្ងាយពីការគ្រប់គ្រងក្នុងរបបខ្មែរក្រហម ។ តាម៉ុក បានជួយប្រជាជនគ្រប់គ្នា មិនឲ្យប្រជាជនខ្វះខាតអ្វីឡើយ គាត់បានប្រាប់ប្រជាជនឲ្យមានការតស៊ូ និងចេះជួយគ្នាទៅវិញទៅមក ការរស់នៅរបស់ប្រជាជនគឺខុសគ្នាពីសម័យ៣ឆ្នាំ ៨ខែ គឺប្រជាជនមានសិទ្ធិក្នុងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួន ។ គាត់បានបង្កើតសាលារៀន មន្ទីរពេទ្យ ស្ពាន ផ្លូវថ្នល់ ។ យោធាទទួលបានប្រាក់ខែ ចំណែកប្រជាជនវិញ ទទួលបានជាអង្ករ សម្ភារជារៀងរាល់ខែ ហើយព្យាបាលជំងឺដោយមិនយកលុយកាកទៀតផង ។

តាម៉ុក មិនបានបិទសិទ្ធិប្រជាជនមិនរៀនសូត្រ និងជឿជំនឿនោះទេ គឺប្រជាជនអាចរកស៊ីចិញ្ចឹមជីវិតរៀងៗខ្លួន បើខ្វះខាតអាចសុំឲ្យគាត់ជួយបាន ។ ចូច បានបន្ថែមទៀតថា នៅសម័យ តាម៉ុក មានលក្ខណៈស្រួលជាងកាលនៅសម័យខ្មែរក្រហមឆ្ងាយណាស់ដោយ នៅសម័យខ្មែរក្រហមមានការបង្ខិតបង្ខំឲ្យប្រជាជនធ្វើការគ្មានពេលសម្រាក ចំណីអាហារបរិភោគមិនគ្រប់គ្រាន់ គ្មានថ្នាំសង្កូវព្យាបាលជំងឺ ។ បើនៅសម័យ តាម៉ុក វិញ ប្រជាជនមានចំណីអាហារហូបចុកគ្រប់គ្រាន់ រស់នៅស្រួល គ្មានការបង្ខិតបង្ខំឲ្យធ្វើការងារ មានសិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ។ ចូច បាននិយាយថា គាត់អន់ចិត្ត ហើយខឹងនឹងខ្មែរក្រហមដែលសម្លាប់បងប្អូន ឪពុកម្ដាយរបស់គាត់ ហើយគាត់ក៏មិនមានចិត្តចង់សងសឹកនឹងអ្នកទាំងនោះដែរ ។

នៅពេលអនាគត ចូច ក៏ដូចជាប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែងទាំងអស់គ្នាដែរ គឺចង់ឲ្យស្រុកអន្លង់វែង ក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមួយដែលជាសមិទ្ធផលដែលបានបន្សល់ទុកពីសម័យខ្មែរក្រហមសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកទស្សនាឲ្យបានច្រើន ជាពិសេសគឺភ្ញៀវទេសចរជាតិយើង ។

ប្រជាជនខ្លះមិនបានដឹងថាស្រុកអន្លង់វែង ជាកន្លែងដែលមេដឹកនាំខ្មែរក្រហមកាន់កាប់ចុងក្រោយទេ ។ គាត់បានសំណូមពរឲ្យមានការអភិវឌ្ឍនៅក្នុងតំបន់អន្លង់វែងនេះ ដើម្បីជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរទៅមុខជាបន្តទៀត ។

**ធឿប សារឿត**

# ការសួរនាំពីបទពិសោធជីវិតក្នុងរបបខ្មែរក្រហមរបស់សិស្ស និស្សិតក្នុងដំណើរទស្សនកិច្ចសិក្សានៅតំបន់អន្លង់វែង

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់សិស្ស និស្សិត ទៅកាន់តំបន់អន្លង់វែង ។ ក្នុងឱកាសនោះសិស្ស និស្សិត ក៏បានស្តាប់ការធ្វើបទបង្ហាញពីវាគ្មិនអំពីព្រឹត្តិការណ៍សំខាន់ៗក្នុងប្រវត្តិសាស្ត្រខ្មែរក្រហម សង្គ្រាម ជម្លោះ អំពើហិង្សា និងជាពិសេស វិធីសាស្ត្រសម្ភាសន៍ប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែង សម្រាប់ជាមូលដ្ឋានដើម្បីសិក្សាស្វែងយល់បន្ថែមពីរបបខ្មែរក្រហម ។ បន្ទាប់មក សិស្ស និស្សិតទាំងអស់ក៏ត្រូវបានផ្តល់ឱកាសឲ្យចុះទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រមួយចំនួនក្នុងតំបន់អន្លង់វែង និងជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាជនដើម្បីសរសេរអត្ថបទខ្លីៗទាក់ទងនឹងទស្សនៈ ប្រវត្តិផ្ទាល់ខ្លួនដែលឆ្លងកាត់របបខ្មែរក្រហមរបស់អ្នកផ្តល់បទសម្ភាសន៍ និងរឿងរ៉ាវទាក់ទងនឹងតំបន់អន្លង់វែង ។

ខាងក្រោមនេះ ជាកិច្ចសម្ភាសន៍រវាងសិស្ស និស្សិតជាមួយនឹងអ្នកដែលរួចរស់ជីវិត និងធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ៖

**១) គេង ពេជ្រវិច្ចិកា បានជួបសម្ភាសន៍ជាមួយ ផាន់ សុផលៈ**

ផាន់ សុផល រស់នៅក្នុងភូមិព្រលាន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ គាត់មានអាយុ៥ ៤ឆ្នាំ និងមានកូន ២នាក់ ហើយកូនៗរបស់គាត់បានរៀបចំឲ្យមានគ្រួសារអស់ហើយ ។ សព្វថ្ងៃ សុផល មិនបានប្រកបរបររកស៊ីអ្វីទេ ។ នៅពេលដែលខ្ញុំបានទៅជួបគាត់ៗ បាននិយាយរៀបរាប់អំពីបទពិសោធនៃជីវិត



និស្សិតស្ម័គ្រចិត្តគម្រោងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងចុះសម្ភាសន៍ប្រជាជនទាក់ទងនឹងបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម និងតំបន់អន្លង់វែង

របស់គាត់ដែលធ្លាប់បានឆ្លងការរបបខ្មែរក្រហមប្រាប់ខ្ញុំថា ៖

នៅពេលដែលខ្មែរក្រហមបានកាន់កាប់អំណាចទាំងស្រុង ខ្មែរក្រហមបានជម្លៀសគាត់ចេញពីភ្នំពេញទាំងបង្ខំឲ្យទៅកាន់ស្រុកកោះធំ ដោយហេតុផលថា បោសសម្អាតខ្មាំងដែលនៅសេសសល់ ។ ពេលនោះ ខ្មែរក្រហមបានប្រើឲ្យគាត់លើកទំនប់ជារៀងរាល់ថ្ងៃ ការងារនៅពេលនោះ មិនសូវធ្ងន់ប៉ុន្មានទេ ។ អំឡុងពេលស្នាក់នៅស្រុកកោះធំ បងប្អូនជីដូនមួយរបស់គាត់ម្នាក់បានស្លាប់ដោយសារខ្វះអាហារ និងមិនមានថ្នាំសង្កូវសម្រាប់ព្យាបាលជំងឺ ។

សុផល បានឲ្យដឹងថា នៅពេលបងប្អូនគាត់ឈឺ ខ្មែរក្រហមមិនបានយកចិត្តទុកដាក់ព្យាបាលជំងឺឡើយ ។ បន្ទាប់ពីបានស្នាក់នៅក្នុងស្រុកកោះធំអស់រយៈពេលប្រាំទៅប្រាំមួយខែ អង្គការបានជម្លៀស សុផល និងក្រុមគ្រួសារគាត់ឲ្យទៅរស់នៅស្រុកភ្នំស្រុក ខេត្តបាត់ដំបងវិញ ។ ពេលទៅដល់ស្រុកភ្នំស្រុកដំបូង របបហូបចុកមានគ្រប់គ្រាន់ តែដល់ក្រោយមកការហូបចុកក៏ចាប់ផ្តើមមានការខ្វះខាត ហើយប្រជាជនចាប់ផ្តើមមានជំងឺហើម ព្រោះគ្មានបាយហូប ។ នៅពេលនោះ សុផល ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការនៅកងចល័ត ហើយការងារដែលត្រូវធ្វើនោះគឺ លើកភ្លឺស្រែ បោចស្ទូងស្រែ រីឯនារីៗវិញ ត្រូវចុះដកស្ទូង ។ ការរស់នៅគឺត្រូវឃ្លាតឆ្ងាយពីក្រុមគ្រួសារ និងឪពុកម្តាយ ។ ប្រជាជនទាំងអស់ត្រូវបង្ខំឲ្យធ្វើការធ្ងន់ ហើយម្នាក់ៗមិនមានពេលទំនេរឡើយ ។ ក្នុងមួយស្រុកមានពេទ្យតែម្នាក់ប៉ុណ្ណោះ សម្រាប់មើល និងព្យាបាលជំងឺ ។ ថ្នាំដែលពេទ្យផ្តល់ឲ្យ គឺគ្មានអ្វីក្រៅពីថ្នាំសូទ្យជាគ្រាប់ពណ៌ខ្មៅ ដែលគេហៅថា "ថ្នាំអាចម៍ទន្សាយ" នោះទេ ។

នៅឆ្នាំ១៩៧៧ អំឡុងពេលដែលកម្មាភិបាល និងយោធាមកពីភូមិភាគនិរតីចូលមកដល់ ប្រជាជនត្រូវបានខ្មែរក្រហម ប្រើឲ្យធ្វើការងារធ្ងន់ជាងមុន ហើយការហូបចុកវិញក៏មិនគ្រប់គ្រាន់ដែរ ។ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដែលមកពីភូមិភាគនិរតី ប្រជាជនទាំងប្រុសទាំងស្រីត្រូវបានចាប់ខ្លួនយកទៅសម្លាប់ សូម្បីតែកម្មាភិបាលខ្មែរក្រហមគ្នាឯងក៏ត្រូវបានចាប់យកទៅសម្លាប់ដែរ ។ ចំពោះការរៀបអាពាហ៍ពិពាហ៍វិញ យុវជន និងយុវនារីត្រូវបានអង្គការរៀបចំរៀបការឲ្យដោយពេលរៀបការម្តងៗមានពីដប់គូរហូតដល់ទៅមួយរយគូ ។ បន្ទាប់ពីរៀបការហើយ ប្តីប្រពន្ធត្រូវរស់នៅជាមួយគ្នា តែចេញទៅធ្វើការតាមកន្លែងរៀងៗខ្លួន ។

នៅឆ្នាំ១៩៧៩ សុផល បានស្ម័គ្រចិត្តចូលធ្វើជាទាហានក្នុងរបបរដ្ឋកម្ពុជា ។ មួយរយៈក្រោយមក ទាហានវៀតណាមបានប្រាប់គាត់ឲ្យទៅរស់នៅស្រុកកំណើត ប្រសិនបើគាត់ចង់ទៅ ។ គាត់ក៏បានធ្វើដំណើរវិលត្រឡប់មកភ្នំពេញវិញ ។ តែនៅពេលធ្វើដំណើរមកដល់ស្រុកក្រឡាញ់ ខេត្តសៀមរាប សុផល បានសម្រេចចិត្តចូលធ្វើទាហានម្តងទៀត ដោយនៅពេលនោះគាត់មានអាយុ១៧ឆ្នាំ ។ សុផល ឈរជើងនៅស្រុកភ្នំស្រុកដើម្បីវាយជាមួយខ្មែរក្រហមដែលនៅសេសសល់ ។ ក្រោយមក អង្គភាពទ័ពរបស់ សុផល បានផ្លាស់ប្តូរទៅនៅបោះទីតាំងនៅខេត្តកំពង់ធំវិញ ។ សុផល បានរៀបការពេលដែលគាត់មានអាយុជាង២០ឆ្នាំ ។ គាត់បានផ្លាស់មករស់នៅក្នុងស្រុកអន្លង់វែងនៅឆ្នាំ២០០៣ ។ សុផល បាននិយាយប្រាប់ខ្ញុំជាចុងក្រោយថា ក្នុងជីវិតរបស់គាត់ ជួបប្រទះតែការឈឺចាប់ជាច្រើន ហើយគាត់មិនចង់ឲ្យរបបខ្មែរក្រហមកើតមានជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជាឡើយ ។

### ២) វ៉ែម សំណាង សិស្សថ្នាក់ទី ១២ "B" បានជួបសម្ភាសន៍ជាមួយ ឈុត ស៊ីឡាដែត ៖

ឈុត ស៊ីឡាដែត អាយុ៥២ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ធំ ។ ស៊ីឡាដែត ជាមនុស្សម្នាក់ដែលបានរួចជីវិតពីរបបខ្មែរក្រហម ហើយគាត់បានរំឭកប្រាប់ខ្ញុំថា ការរស់នៅក្នុងរបបខ្មែរក្រហម គឺរស់នៅមានលក្ខណៈជាក្រុម ជាកង ហើយអ្នកគ្រប់គ្រង គឺជាមនុស្សដែលមានភាពកាចសាហាវ ។ ស៊ីឡាដែត បានឲ្យដឹងថា នៅក្នុងរបបខ្មែរក្រហមពិតជាមានការលំបាកខ្លាំងណាស់ ព្រោះពេលនោះមនុស្សម្នាក់ៗគ្មានសិទ្ធិសេរីភាព គ្មានសម្ភារជាលក្ខណៈឯកជនឡើយ ។ អ្វីៗទាំងអស់ជារបស់រួម ទាំងការហូបចុក ទាំងការធ្វើការងារ ទាំងការស្នាក់នៅ ។ គាត់បានរំឭកថា ពេលឈឺម្តងៗ មិនមានថ្នាំអ្វី ក្រៅពីថ្នាំអាចម៍ទន្សាយទេ ។ អ្នកដឹកនាំក្រុមរបស់ស៊ីឡាដែត មានឈ្មោះថា "ពូពីរ" ។ "ពូពីរ" នេះហើយដែលបានបញ្ជាឲ្យសម្លាប់ឪពុកម្តាយ និងបងប្អូនរបស់គាត់ ។ ចំណែកអ្នកខ្លះទៀត ត្រូវខ្មែរក្រហមយកទៅដាក់នៅមន្ទីរឃុំឃាំង ហើយធ្វើទារុណកម្មរហូតដល់ស្លាប់ ដោយចោទថា "ក្បត់នឹងអង្គការ" ។ ខ្មែរក្រហមបានលុបបំបាត់សាសនា ដោយចាប់បង្ខំព្រះសង្ឃឲ្យសឹក

ហើយបញ្ជូនឲ្យទៅធ្វើស្រែចម្ការនៅតាមជនបទដូចជាប្រជាជនធម្មតាដែរ ។ ពេលនោះ ខ្មែរក្រហមបានប្រែក្លាយទីវត្តអារាមឲ្យក្លាយទៅជាគុកសម្រាប់ដាក់ និងធ្វើទារុណកម្មមនុស្ស ។ កុមារៗដែលមានវ័យកំពុងសិក្សាពុំបានចូលសាលារៀនទេ ។ ស៊ីឡាដែត បានឲ្យដឹងទៀតថា ការរៀបចំគ្រួសារវិញគឺអង្គការជាអ្នកសម្រេច ។ យុវជន និងយុវនារី បានរៀបការម្តងៗមានចំនួនពីដប់គូទៅម្ភៃគូ ហើយពីធីរៀបការ គឺគ្មានឪពុកម្តាយ អាណាព្យាបាល បងប្អូនសាច់ញាតិ និងក្រុមគ្រួសារចូលរួមឡើយ ។ គាត់បានបន្តទៀតថា ចំណែកការធ្វើប្រព័ន្ធប្រឡាយទឹក ដើម្បីស្រោចស្រពលើផ្ទៃដីស្រែ គឺប្រើដោយកម្លាំងប្រជាជនទាំងស្រុង ។

ឆ្នាំ១៩៧៩ ក្រោយពេលដែលប្រទេសកម្ពុជា ត្រូវបានរំដោះចេញពីរបបខ្មែរក្រហម ស៊ីឡាដែត បានទៅរស់នៅក្រោមការដឹកនាំរបស់តា ម៉ុក នៅអន្លង់វែង ។ គាត់បាននិយាយបន្តថា តាម៉ុក ជាមនុស្សម្នាក់មិនផ្តាច់ការនោះទេ ។ ស៊ីឡាដែត មានសេចក្តីរីករាយដែលបានរួចផុតពីរបបខ្មែរក្រហម ហើយប្រជាជនទូទាំងប្រទេសមានសិទ្ធិសេរីភាពពេញបរិបូណ៌ លើសពីនេះ ប្រជាជនមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការប្រកបមុខរបររកស៊ីដើម្បីរកប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសាររៀងៗខ្លួន ។

### ៣) វ៉ែ ខាត់នី បានជួបសម្ភាសន៍ជាមួយអ្នកមីង ប៊ុន សាវ៉ ពីបទពិសោធន៍នៃជីវិតក្នុងរបបខ្មែរក្រហម ៖

ប៊ុន សាវ៉ អាយុ៣៥ឆ្នាំ មានស្រុកកំណើតនៅភូមិព្រលាន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ សាវ៉ មានកូនប្អូននាក់ (ប្រុសពីរស្រីពីរ) ។ គ្រួសាររបស់គាត់ជាអ្នកធ្វើស្រែចម្ការ ចំពោះជីវភាពក្នុងគ្រួសាររបស់ សាវ៉ មានការលំបាកខ្លះ ព្រោះមុខរបរធ្វើស្រែរបស់គាត់ គឺរង់ចាំទឹកភ្លៀង ហើយដីក៏កាន់តែខ្សោះជីជាតិ ។ ការធ្វើស្រែចម្ការប្រវាស់ជាមួយទឹកភ្លៀងគឺមិនសូវជាល្អប៉ុន្មានទេ បើឆ្នាំណាមានភ្លៀងធ្លាក់ជោគជាំនោះទិន្នផលក៏ទទួលបានប្រសើរ តែបើឆ្នាំណាមិនសូវសម្បូរទឹកភ្លៀង ទិន្នផលស្រូវក៏ទទួលបានតិចតួចទៅតាមនោះដែរ ។ ទាក់ទងទៅនឹងបទពិសោធន៍ជីវិតក្នុងរបបខ្មែរក្រហម សាវ៉ បានរៀបរាប់ពីជីវប្រវត្តិរបស់គាត់ផ្ទាល់ដែលធ្លាប់បានឆ្លងកាត់ប្រាប់មកកាន់ខ្ញុំថា ៖

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហម



ទិដ្ឋភាពផ្លូវលំ និងផ្ទះរបស់ប្រជាជននៅក្នុងភូមិ នៅជិតជើងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

បានប្រាប់ប្រជាជននៅទីប្រជុំជន និងទីក្រុងថា អាមេរិកនឹងមកទម្លាក់គ្រាប់បែក ។ បន្ទាប់មក ខ្មែរក្រហមបានជម្លៀសប្រជាជនឲ្យទៅរស់នៅតាមទីជនបទ ។ នៅពេលនោះ មេដឹកនាំខ្មែរក្រហមបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើការងារកសិកម្ម ។ អ្នកដឹកនាំខ្មែរក្រហមមានផែនការធ្វើស្រូវរយៈពេលបួនឆ្នាំឲ្យបានទិន្នផលស្រូវបីតោនក្នុងមួយហិកតា ដោយប្រើជីធម្មជាតិដូចជាជីអាចម៍គោ ជីអាចម៍មាន់ ជីលាមកមនុស្ស លាយជាមួយនឹងដើមទន្រ្ទានខែត្រ ។ ប្រជាជនត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការរួមគ្នា ហូបរួមគ្នា និងដេករួមគ្នា ។ តែការហូបចុក មិនបានហូបគ្រប់គ្រាន់ទេ ហើយរបបអាហារដែលប្រជាជនបានទទួលនោះគឺ បបររាវៗស្ទើរតែគ្មានគ្រាប់អង្ករ ។ ការបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំងរួមផ្សំជាមួយនឹងរបបហូបចុកតិចតួច បានធ្វើឲ្យគាត់នាំគ្នាគាស់គល់ចេក និងដើរបេះរុក្ខជាតិបៃតងផ្សេងៗទៀតដែលអាចហូបបានមាន ដូចជា ស្លឹកដំឡូងឈើ ស្លឹកដំឡូងមី និងត្រកួន យកមកលាយជាមួយបបរហូបដើម្បីបំបាត់សេចក្តីស្រេកឃ្លាន ។

ទាក់ទងនឹងការរៀបការ សាវ បានប្រាប់ឲ្យដឹងថា ការរៀបការម្តងៗ គឺបើតិចគូមានចាប់ពី៣គូទៅ១០គូ តែបើច្រើនគូវិញ គឺមានចាប់ពី៣០គូទៅ៦០គូ ។ ការរៀបការនៅក្នុងសម័យនោះយុវជន-យុវនារីភាគច្រើនមិនសូវជាពេញចិត្តប៉ុន្មានទេ (អ្នកខ្លះត្រូវបានបង្ខំឲ្យរៀបការជាមួយមនុស្សដែលខ្លួនមិនដែលធ្លាប់ស្គាល់ពីមុនមក ឬក៏អាចបង្ខំឲ្យរៀបការជាមួយយុទ្ធជនពិការដៃពិការជើង ឬពិការភ្នែកក៏មាន តែក៏មានគូខ្លះបានស្គាល់គ្នា យល់ចិត្តយល់ថ្លើមគ្នា និងស្រលាញ់គ្នាដែរ) ។ ការរៀបការត្រូវធ្វើឡើងទាំងបង្ខំ យុវជន-យុវនារីដែលជាសាមីខ្លួនផ្ទាល់ គ្មានសិទ្ធិសម្រេចលើដោគវាសនារបស់ខ្លួនឡើយ គឺមានតែអង្គការទេ ជាអ្នកសម្រេច ។ សាវ បាននិយាយបន្តថា មិនមានសាលារៀនត្រឹមត្រូវឲ្យក្មេងៗអង្គុយរៀនទេ គឺរៀននៅក្រោមដើមឈើ ឬនៅតាមផ្ទះរបស់ប្រជាជន ។ ចំណែកគ្រូបង្រៀនវិញ មិនមានចំណេះដឹងជ្រៅជ្រះទេ គ្រាន់តែចេះអាន និងចេះសរសេរតិចតួចប៉ុណ្ណោះ ។ ក្រៅពីការសិក្សា កុមារត្រូវបានខ្មែរក្រហមប្រើឲ្យដើររើសអាចម៍គោ កាប់ដើមទន្រ្ទានខែត្រយកមកធ្វើជីដាក់ស្រែ ។ ចំណែក សាសនាវិញ ត្រូវបានខ្មែរក្រហមលុបបំបាត់មិនឲ្យគោរពព្រះ និងគោរពព្រះសង្ឃឡើយ ។ ព្រះពុទ្ធប្បដិមា ត្រូវបានខ្មែរក្រហមវាយកម្ទេចយកទៅកប់ចោលក្នុងដី និងយកទៅបោះចោលក្នុងទឹកស្រះ ឬត្រពាំង ។ រីឯព្រះសង្ឃត្រូវខ្មែរក្រហមចាប់ផ្សឹក ហើយឲ្យទៅធ្វើស្រែចម្ការដូចជាប្រជាជនដទៃទៀតដែរ ។ ឯវត្តអារាម ក៏ដូចជាសាលារៀនត្រូវបានយកទៅធ្វើជាជម្រុកស្រូវ ឬក៏ធ្វើជាមន្ទីរឃុំឃាំងសម្រាប់ដាក់អ្នកទោស ។ ចំពោះមន្ទីរពេទ្យមិនសម្បូរទេ ចំណែកពេទ្យវិញមានតែពេទ្យដែលដើរតាមថ្នាក់ដឹកនាំផ្ទាល់តែប៉ុណ្ណោះ ។ រីឯប្រជាជនធម្មតាវិញ ពេលមានជំងឺ គឺនិយមប្រើថ្នាំខ្មែរដើម្បីព្យាបាលខ្លួន ។

សាវ បានឲ្យដឹងទៀតថា អង្គការគិតថា សត្រូវរបស់ខ្លួនមាននៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា ជនសង្ស័យភាគច្រើនត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថា ជាអ្នកស៊ើបការណ៍របស់អាមេរិក ឬអ្នកស៊ើបការណ៍របស់វៀតណាម ហើយក្រោយមក អ្នកទាំងអស់នោះត្រូវបានយកទៅសម្លាប់ដោយមិនបានជំនុំជម្រះទោស ។ នៅពេលអង្គការចង់ចាប់អ្នកណាម្នាក់ អង្គការតែងប្រើពាក្យថា «ស្នើទៅរៀនសូត្រ» ហើយអ្នកទាំងនោះ គឺត្រូវបាត់ខ្លួនជារៀងរហូត ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលរបបខ្មែរក្រហមបានដួលរលំ ។ ប្រជាជនកម្ពុជាទាំងអស់បានរួចចាកផុតពីរបបដ៏អប្រិយ៍នេះ និងបានវិលត្រឡប់ទៅរស់នៅស្រុកកំណើតរៀងៗខ្លួនវិញ ។ សាវ បានឲ្យដឹងទៀតថា តំបន់អន្លង់វែងជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ។ តំបន់នេះត្រូវបានគ្រប់គ្រងដោយ តាម៉ុក ។ តាម៉ុក ជាមនុស្សល្អ និងបានផ្តាច់ខ្លួនចេញពី ប៉ុល ពត ។ តាម៉ុក បានកសាងជា ស្ពាន សាលារៀន និងមន្ទីរពេទ្យ ហើយប្រជាជន ដែលនៅតំបន់នោះ ក៏មានជីវភាពធូរធាបន្តួរ ដោយ តាម៉ុកជាអ្នកឧបត្ថម្ភជាស្បៀងដល់ពួកគាត់ ។ ជាចុងក្រោយ សាវ ក៏ដូចប្រជាជននៅក្នុងស្រុកអន្លង់វែងទាំងអស់ ចង់ឲ្យប្រទេសជាតិទាំងមូលមានសុខសន្តិភាពពេញបរិបូណ៌ ហើយម៉្យាងទៀត គាត់ចង់ឲ្យតំបន់អន្លង់វែងនេះ ក្លាយទៅជាតំបន់ទេសចរណ៍មួយដែលមានភ្ញៀវទេសចរជាតិ និងអន្តរជាតិ ធ្វើដំណើរមកកម្សាន្តនៅទីនេះ និងបានសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្ររបស់ខ្មែរក្រហមនៅក្នុងតំបន់នេះ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ទន្លេជាជីវិត

កោះរងាវ គឺជាកោះដែលធំជាងគេនៅទន្លេមេគង្គ ដែលស្ថិតក្នុងស្រុកសម្បូរណ៍ ខេត្តក្រចេះ ។ កោះរងាវ មានប្រវែង៤៥គីឡូម៉ែត្រ និងមានបួនភូមិ គឺភូមិកោះដ្តៅ ភូមិសូភិន ភូមិកំពង់ក្របី និងភូមិអំពិលទឹក ។ ប្រជាពលរដ្ឋដែលរស់នៅកោះរងាវភាគច្រើនប្រកបរបរធ្វើស្រែចម្ការ និងនេសាទ ។ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែជីវភាពខ្វះខាត ទើបប្រជាជនមួយចំនួន ដែលភាគច្រើនជាយុវវ័យសម្រេចចិត្តចាកចេញពីផ្ទះទៅធ្វើការនៅក្រៅស្រុក ឬក៏ប្រទេសថៃ ។ កោះរងាវ មានសាលាត្រឹមកម្រិតអនុវិទ្យាល័យប៉ុណ្ណោះ ហើយបើសិស្សចង់សិក្សាដល់ថ្នាក់វិទ្យាល័យសិស្សត្រូវទៅរៀនបន្តនៅឯវិទ្យាល័យនៅស្រុកសម្បូរណ៍ ។ បើតាមលោកតា សេង ឃីម អាយុ៧៩ឆ្នាំ ដែលជាចាស់ទុំមួយរូបក្នុងភូមិកោះដ្តៅបានឲ្យដឹងថា ពីដើមឡើយ នៅកោះរងាវនេះ មិនសូវមានមនុស្សរស់នៅច្រើនកុះករនោះទេ ។ កោះនេះ មានព្រៃឈើក្រាស់ៗ និងសត្វព្រៃគ្រប់ប្រភេទ ។ បើនិយាយពីត្រីវិញ គឺមិនខ្វះនោះទេ គ្រាន់តែបង់តែមួយសំណាញ់អាចបរិភោគបានពីរបីថ្ងៃឯណោះ គឺសម្បូរខ្លាំងណាស់ ។

លោកតា ឃីម បានរម្លឹកថា ក្រោយរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ មក ភូមិកោះដ្តៅ ក៏ដូចជាកោះរងាវទាំងមូលត្រូវបានគ្រប់គ្រងដោយខ្មែរក្រហម ។ ខ្មែរក្រហមបានធ្វើការឃោសនាប្រជាជនឲ្យចូលរួមចលនាតស៊ូបដិវត្តន៍ប្រឆាំងនឹងរបបលន់ នល់ ដើម្បីដណ្តើមយកអំណាចថ្វាយសម្តេចសីហនុវិញ ។ បន្ទាប់ពីជ័យជម្នះទូទាំងប្រទេសរបស់ខ្មែរក្រហម នៅថ្ងៃទី១៧មេសា ឆ្នាំ១៩៧៥ មក អង្គការបានចាត់តាំង តាឃីម ជាមេក្រុមគ្រប់គ្រងអ្នកជម្លៀស១៧មេសា ចំនួន១០គ្រួសារ ។ គាត់មាននាទីដឹកនាំការងារ និងអប់រំប្រជាជន១៧មេសា ។ គាត់បានឲ្យដឹងថា គាត់មិនដែលធ្វើបាបប្រជាជនថ្មីទាំងអស់នេះទេ ហើយការហូប



សេង ឃីម រៀបរាប់ពីជីវិតរបស់គាត់ដែលប្រកបរបបនេសាទត្រី និងជីវិតដែលរស់នៅក្នុងរបបខ្មែរក្រហម នៅក្រោមផ្ទះរបស់គាត់នៅភូមិកោះរងាវ



កោះរង៉ាវ ស្ថិតក្នុងស្រុកសម្បូរណ៍ ខេត្តក្រចេះ

ចុកគឺហូបរួមជាមួយគ្នា អ្នកជម្ងឺសហូបអ្វី គាត់ក៏ហូបដូចគ្នាដែរ ។

នៅអំឡុងឆ្នាំ១៩៧៧-១៩៧៨ មានការចាប់ខ្លួនកម្មាភិបាលជាច្រើន ហើយប្រធានរបស់ តាឃីម មួយចំនួនក៏ត្រូវបាត់ខ្លួន ឬអង្គការផ្លាស់ទៅកន្លែងថ្មី ប៉ុន្តែមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញឡើយ ។ តាឃីម ក៏ត្រូវអង្គការចាត់តាំងឲ្យដឹកនាំប្រជាជនថ្មីទៅលើកទំនប់នៅខាងកោះដំបងដែរ ប៉ុន្តែអ្វីដែលគាត់ដឹងនោះគឺ ចង់ចាប់កំហុសគាត់ ចាប់ខ្លួនគាត់ ។ ដោយសារតែទង្វើល្អរបស់ តាឃីម ចំពោះប្រជាជនថ្មីទាំងនោះ ទើបធ្វើឲ្យអង្គការមិនអាចចាប់កំហុសគាត់បាន ។ គាត់ និងក្រុមបានបំពេញគ្រប់ផែនការដែលអង្គការប្រគល់ឲ្យ ។ តាឃីម ក៏រួចជីវិតតាំងពីពេលនោះមក ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ តាឃីម បាននាំគ្រួសារមករស់នៅភូមិកោះផ្តៅវិញ ។ បច្ចុប្បន្ន តាឃីម រស់នៅជាមួយប្រពន្ធ និងកូនស្រីម្នាក់ ចំណែកកូនប្រុសទាំង៧នាក់របស់គាត់ បានរៀបការ និងបែកផ្ទះរស់នៅផ្សេងពីគាត់ ហើយខ្លះទៀតទៅធ្វើការនៅស្រុកឆ្ងាយ ។ រាល់ពេលបុណ្យចូលឆ្នាំខ្មែរទើបកូនចៅរបស់គាត់មកជួបជុំគ្នា ។ តាឃីម នៅតែនឹកឃើញជានិច្ចចំពោះអនុស្សាវរីយ៍ដ៏រីករាយរបស់គាត់កាលពីយុវវ័យ ។ គាត់បានឲ្យដឹងថា ពីមុន នៅតំបន់កោះរង៉ាវនេះ សម្បូរទៅដោយព្រៃឈើ សត្វព្រៃជាច្រើន ។ ចំពោះត្រី គឺសម្បូរខ្លាំងណាស់ មិនដូចពេលបច្ចុប្បន្នទេ ។ ពេលនេះ មានជនទុច្ចរិត ជាច្រើនមកនេសាទខុសច្បាប់ ប្រើឧបករណ៍ឆក់ត្រី ដែលជាហេតុធ្វើឲ្យត្រីមួយចំនួនស្ទើរតែផុតពូជទៅហើយ ។ អ្នកទាំងនោះច្រើនតែមកពីស្រុកផ្សេង បើតាមអ្នកភូមិនៅកោះរង៉ាវនេះគ្រាន់តែនេសាទជាលក្ខណៈគ្រួសារប៉ុណ្ណោះ ។ តាឃីម បន្តដោយសំណើចថា គាត់នៅចាំពាក្យស្លោកដែលអ្នកភូមិតែងតែនិយាយលេងថា "ទង្គិចគូទ (កន្ទុយទូក) ត្រីពេញទូក" គឺមិនចាំបាច់ប្រើសំណាញ់បង់នោះទេ ។ ប៉ុន្តែមកដល់ពេលបច្ចុប្បន្ន ធនធានព្រៃឈើ និងសត្វព្រៃទាំងនោះបានបាត់បង់អស់ហើយ ជាពិសេសគឺត្រីតែម្តង ។ អ្វីដែលសំខាន់នោះ ប្រជាជនដែលរស់នៅតាមបណ្តាកោះនៃទន្លេមេគង្គនេះ គឺអាស្រ័យផលលើការនេសាទ និងធ្វើស្រែចម្ការ ហេតុនេះ ទន្លេមេគង្គនេះ គឺពិតជាមានសារសំខាន់ណាស់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទាំងនេះ ។ សម្រាប់ តាឃីម អនុស្សាវរីយ៍ដ៏រីករាយកាលពីអតីតកាល នៅតែដិតជាប់ក្នុងចិត្តគាត់ជានិច្ច ។ តាឃីម មិនចង់រស់នៅទីណាក្រៅពីកោះរង៉ាវនេះទេ ព្រោះគាត់មានអនុស្សាវរីយ៍ជាច្រើនជាមួយគ្រួសារនៅទីនេះ ។

**ឆាយ សារះមុនិន្ទ**

# ការផ្លាស់ប្តូរដ៏គួរឱ្យសោកស្តាយ

## ប្រវត្តិឃុំកំពង់ភ្លុក

នៅពេលល្ងាចថ្ងៃមួយ ក្រោយពេលបំពេញការងាររួចរាល់ ខ្ញុំបានអង្គុយសំណេះសំណាលជាមួយលោកតាម្នាក់នៅផ្ទះរបស់គាត់ក្បែរមាត់ទឹកនៃបឹងទន្លេសាប ដែលស្ថិតនៅក្នុងឃុំកំពង់ភ្លុក និងបានសួរនាំគាត់ពីរឿងរ៉ាវផ្សេងៗ ។ គាត់មានឈ្មោះ សួរ ឈួ សព្វថ្ងៃ គាត់មានវ័យ៧០ឆ្នាំ ។ ជាមនុស្សដែលរួសរាយម្នាក់ តាឈួ បានរ៉ាយរ៉ាប់ប្រាប់ខ្ញុំអំពីប្រវត្តិខ្លះៗដែលទាក់ទងនឹងឃុំកំពង់ភ្លុក ។

តាឈួ បានឲ្យដឹងថា កាលពីយូរលង់ណាស់មកហើយ តំបន់កំពង់ភ្លុកនេះ ពោរពេញទៅដោយព្រៃក្រាស់ៗ ជាពិសេស សម្បូរទៅដោយហ្វូងដំរី ជាច្រើនបានដើរឆ្លងកាត់ រហូតធ្វើឲ្យផ្លូវដែលហ្វូងដំរីដើរកាត់រាល់ថ្ងៃក្រហូងក្លាយជាព្រែក ។ គាត់ធ្លាប់ឮចាស់ៗដំណាលប្រាប់ពីការកកើតនៃឈ្មោះឃុំកំពង់ភ្លុក់នេះថា ដើមឡើយប្រជាជននៅក្នុងភូមិនេះ បាននាំគ្នាជីកដីដើម្បីពូនជាទួលសម្រាប់ធ្វើវត្ត ។

ពេលកំពុងជីក ក៏បានប្រទះឃើញភ្លុកដំរី ដែលកប់ក្នុងដី ។ បន្ទាប់ពីសាងសង់វត្តរួច អ្នកភូមិក៏យកភ្លុកដំរីនោះ ទៅរក្សាទុកនៅក្នុងវិហារ ។ ចាប់តាំងពីពេលនោះមក អ្នកភូមិក៏ដាក់ឈ្មោះតំបន់នោះថា កំពង់ភ្លុក រហូតមកដល់បច្ចុប្បន្ន ។ ប៉ុន្តែ បន្ទាប់ពីប្រទេសជួបនឹងសង្គ្រាមជាច្រើនលើកច្រើនសាមក ភ្លុកដំរីដែលរក្សាទុកក្នុងវិហារនោះ ក៏បានបាត់មិនដឹងថា អ្នកណាយកទៅណានោះទេ ។

## ប្រជាជន និងការរស់នៅ



សួរ ឈួ បានរៀបរាប់ពីប្រវត្តិនៃការនេសាទនៅឃុំកំពង់ភ្លុក រហូតដល់សម័យខ្មែរក្រហមចូលមកគ្រប់គ្រង ឆ្នាំ១៩៧៥


ការនេសាទរបស់ប្រជានេសាទ នៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប

ដោយសារតែឃុំកំពង់ភ្លុកនេះជាតំបន់លិចទឹក និងជាប់បឹងទន្លេសាប ប្រជាជនភាគច្រើនប្រកបរបរនេសាទ ។ តាឈួ និងគ្រួសារ ក៏ជាអ្នកនេសាទដែរ ។ របរនេសាទនេះ គាត់ធ្វើតាំងពីជំនាន់ឪពុកម្តាយគាត់មកម្ល៉េះ ។ គាត់បានរម្លឹកថា គាត់ធំដឹងក្តីឡើងនៅក្នុងគ្រួសារដែលមានជីវភាពទីទាល់ក្រ ។ គាត់បានរៀនសូត្រត្រឹមថ្នាក់ទី១០ (សង្គមចាស់) ប៉ុណ្ណោះ ។ គាត់បានឈប់រៀនមកស៊ីឈ្នួលរាយមង និងដាក់លបឲ្យថៅកែ ដើម្បីបានប្រាក់កម្រៃខ្លះមកផ្គត់ផ្គង់ជីវភាពគ្រួសារ ។

## ជីវិតក្នុងរបបខ្មែរក្រហម

តាឈួ បានរៀបការនៅឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ។ នៅឆ្នាំ១៩៧២ ចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហម បានគ្រប់គ្រងភូមិស្រុកដែលគាត់រស់នៅ ។ ពេលនោះ ខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជននៅភូមិកំពង់ភ្លុកទាំងអស់ ទៅរស់នៅបេងមាលា ខាងស្រុកស្វាយលើ ។ ពេលទៅដល់ទីនោះដំបូង ខ្មែរក្រហមបានចាត់តាំងប្រជាជនទាំងអស់ឲ្យធ្វើស្រែ និងដាំដំណាំ ។ មួយឆ្នាំក្រោយមក ដោយអ្នកស្រុកកំពង់ភ្លុកភាគច្រើនដែលមានជំនាញខាងនេសាទ ទើបខ្មែរក្រហមបានចាត់ឲ្យប្រុសៗដែលពេញកម្លាំងទៅនេសាទត្រីមកផ្គត់ផ្គង់សហករណ៍ ។ តាឈួ និងសមាជិកនេសាទទាំងអស់ប្រមាណ៣០០នាក់ បានទៅនេសាទរាល់ថ្ងៃ ។ គាត់បានឲ្យដឹងថា ត្រីពេលនោះសម្បូរខ្លាំងណាស់ និងមានគ្រប់ប្រភេទ ទាំងត្រីតូច ទាំងត្រីធំ ។ ក្នុងមួយថ្ងៃក្រុមនេសាទរបស់គាត់ អាចរកត្រីបាន៥តោន សម្រាប់ផ្គត់ផ្គង់សហករណ៍ និងចែកចាយទៅកាន់តំបន់ផ្សេងៗ ។ ត្រីទាំងនោះភាគច្រើនមានត្រីឆ្តោក ត្រីឆ្តោ ត្រីប្រា ត្រីរៀល ជាដើម ។ អ្វីដែលខ្វះខាតនៅពេលនោះ គឺអង្ករ ហើយរបបដែលខ្មែរក្រហមចែកឲ្យត្រឹមតែអង្ករមួយកំប៉ុង សម្រាប់បបរចែកគ្នា១០នាក់ ។ ចំពោះត្រីដែលរកបាន ខ្មែរក្រហមឲ្យក្រុមនេសាទហូបតាមចិត្ត ។ អ្នកខ្លះហូបត្រីរហូតដល់ថ្នាក់រាក និងឈឺទៀតផង ព្រោះមានតែសាច់ត្រី ។ តាឈួធ្វើការនៅក្នុងកងនេសាទនេះ ពេញមួយរបបខ្មែរក្រហម ។

## ស្ថានភាពឃុំកំពង់ភ្លុកក្រោយរបបខ្មែរក្រហម

ក្រោយរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ តាឈួ និងគ្រួសារបានត្រឡប់ មករស់នៅ និងចាប់ផ្តើមជីវិតថ្មីនៅឃុំកំពង់

ភ្លុក ដែលជាស្រុកកំណើតវិញ ។ គាត់បានឲ្យដឹងថា មកដល់ដំបូង ឃុំទាំងមូលស្ងាត់ជ្រងំ ផ្ទះសម្បែង វត្តអារាម ត្រូវបានខ្មែរក្រហម កម្ទេចគ្មានសល់ ។

គាឈួ ក៏ដូចជាអ្នកភូមិដទៃទៀត បានចាប់ផ្តើមជីវិតថ្មីជាមួយនឹងរបរនេសាទដដែល ។ គាត់បានរម្លឹកថា ពេលនោះត្រីមិនខ្វះហូបទេ ត្រីនៅច្រើនដដែលដូចជំនាន់ខ្មែរក្រហមដែរ ។ ក្នុងមួយថ្ងៃគាត់ និងកូនៗអាចរកបានត្រីប្រហែល៣០០គីឡូឯណោះ ប៉ុន្តែបច្ចុប្បន្នមិនអាចរកបានដូចពេលនោះទេ ។

## ការបង្រៀនកូន និងការបន្តវេន

គាឈួ តែងតែបង្ហាត់បង្រៀនកូនៗរបស់គាត់ អំពីរបៀបនេសាទត្រី ។ គាត់បង្រៀនកូនអំពីរបៀបចែវទូក វាយមង ដាក់លប និងរបៀបមើលពណ៌ទឹក ។ សព្វថ្ងៃដោយសារវ័យជរា និងជំងឺ គាឈួ មិនបានទៅនេសាទជាមួយកូនៗដូចមុនទៀតទេ ។ គាត់តែងតែរម្លឹកប្រាប់ចៅៗអំពីភាពសម្បូរនៃត្រីគ្រប់ប្រភេទនៅក្នុងបឹងទន្លេសាប ។ ប៉ុន្តែអ្វីដែលគាត់សោកស្តាយ នៅពេលបច្ចុប្បន្ននេះ ធនធានត្រីមិនសម្បូរដូចពីមុនទៀតឡើយ ។ គាត់ប៉ាន់ស្មានបានថា "ពីមុនយើងមានត្រី១០០ភាគរយ ប៉ុន្តែបច្ចុប្បន្ននេះ ត្រីរបស់យើងមានមិនដល់៣០ភាគរយផង" ។

គាឈួ បានឲ្យដឹងថា ចាប់តាំងពីឆ្នាំ១៩៨៣មក ធនធានត្រីមានការថយចុះជាបន្តបន្ទាប់ ដោយសារមានជនទុច្ចរិតមកនេសាទ និងប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ដែលភាគច្រើនអ្នកទាំងនោះជាប្រជាជនដែលមកតំបន់ផ្សេងៗ ។ អ្នកទាំងនោះប្រើប្រាស់ឧបករណ៍ធំៗ អូសគៀរត្រីតូច ធំគ្មានសល់ ។ សព្វថ្ងៃនេះ ត្រីមួយចំនួនស្ទើរតែផុតពូជហើយ ។ ទន្ទឹមនឹងការនេសាទ ខុសច្បាប់នេះ ការសាងសង់ទំនប់វារីអគ្គិសនីពីសំណាក់ ប្រទេសជិតខាងដែលនៅខាងលើប្រទេសយើង ក៏ជាមូលហេតុដែលធ្វើឲ្យធនធានត្រីមានការថយចុះដែរ ។

**ឆាង សារៈមុនិន្ទ**



ផ្ទះបណ្តែតទឹក នៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប

# សាក្សីបន្តផ្តល់សក្ខីកម្មទាក់ទងខេត្តបាត់ដំបង និងស្រុកត្រាំកក់

សាក្សីមិនបង្ហាញអត្តសញ្ញាណ 2-TCW-971 បានបន្តផ្តល់សក្ខីកម្ម ។ លោកបានផ្តល់ភ័ស្តុតាងទាក់ទងការងារ និងស្ថានភាពរស់នៅក្នុងខេត្តបាត់ដំបង និងស្រុកត្រាំកក់ ក៏ដូចជាការផ្លាស់ប្តូរកម្មាភិបាលគ្រប់គ្រង ។

**ការដាក់ពាក្យសុំការពិនិត្យសម្រេចផ្ទាល់មាត់**

វគ្គដំបូង ការដាក់ពាក្យសុំការពិនិត្យសម្រេចផ្ទាល់មាត់នូវប្រធានបទចំនួនពីរត្រូវបានធ្វើឡើង ។ ទី១) ពាក់ព័ន្ធនឹងការស្នើសុំរបស់ការិយាល័យសហព្រះរាជអាជ្ញា ដើម្បីស្តាប់ការបំភ្លឺពីសាក្សីពីររូបទៀត និងយោបល់របស់ពួកគេពាក់ព័ន្ធលើឯកសារគន្លឹះ ។ ទី២) ការស្នើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឲ្យមានការទទួលយកឯកសារ ។ សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គាំចាន់ បានបកស្រាយថា មានសាក្សីពីររូបទៀតដែលមានការពាក់ព័ន្ធជាមួយតួនាទីរបស់ជនជាប់ចោទ ។ បន្ថែមពីលើនេះទៀត ពួកគេមិនបានចាត់ទុកថា ការបំភ្លឺលើឯកសារគន្លឹះក្នុងផ្នែកនេះមានសារសំខាន់នោះទេ ដោយសារតែឯកសារទាំងនេះគួរតែបង្ហាញក្នុងវគ្គបិទបញ្ចប់ ។ ពួកគេនឹងធ្វើការឆ្លើយតប ប្រសិនបើភាគីទាំងអស់មានបំណងចង់បង្ហាញឯកសារគន្លឹះរបស់ពួកគេ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានការជំទាស់ក្នុងការស្តាប់ការបំភ្លឺរបស់សាក្សីបន្ថែមទាំងពីររូបឡើយ ហើយពួកគេក៏ពុំមានឯកសារបន្ថែមដើម្បីបង្ហាញដែរ ។

ផ្ទុយទៅវិញ ក្រុមមេធាវីការពារក្តីឲ្យ ខៀវ សំផន បានធ្វើការជំទាស់ដាច់ខាត ។ លោកស្រី អានតា ហ្គីសេ្ស បានលើកឡើងថា សំណើរបស់សហព្រះរាជអាជ្ញាមានការយឺតយ៉ាវ ។ សំណើត្រូវបានដាក់ក្រោយពេលកំណត់ដែលភាគីទាំងអស់បានអង្គុតមើលដើម្បីកំណត់ធាតុផ្សំ និងសារណា ដែលពួកគេមានបំណងចង់ដាក់ដើម្បីសុំការពិនិត្យសម្រេច ក៏ដូចជាសាក្សីដែលបានស្នើសុំបង្ហាញខ្លួន ។ ក្នុងចំណោមសាក្សីទាំង១០ ដែលសហព្រះរាជអាជ្ញាបានស្នើសុំ មាន៨រូបបានបង្ហាញខ្លួន ។ ការកោះហៅសាក្សីថ្មីក្នុងវគ្គនៃ


មន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ

ដំណើរការកាត់ក្តី អាចមានការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសិទ្ធិការពារដ៏ត្រឹមត្រូវមួយ ។

ក្រុមមេធាវីការពារក្តីឲ្យ នួន ជា បានប្រកាសថា ពួកគេពុំមានឯកសារគន្លឹះដើម្បីបង្ហាញឡើយ ។ ក្នុងករណីមានសាក្សីថ្មី មេធាវីបាននិយាយថា ពួកគេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងជាមួយនឹងសំណើថ្មីនេះ ហើយពួកគេមិនឃើញពីហេតុផលថា ហេតុអ្វីបានជាសាក្សីថ្មីត្រូវបានកោះហៅ ឬពួកគេមានអ្វីដើម្បីនិយាយបកស្រាយពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទនោះទេ ។ ពួកគេពុំឃើញពីភាពពាក់ព័ន្ធរបស់សាក្សីជាមួយនឹងតួនាទីរបស់ជនជាប់ចោទនោះទេ ដូច្នេះហើយពួកគេបានបដិសេធក្នុងការកោះហៅសាក្សី ។

សហមេធាវីអន្តរជាតិបានមានប្រសាសន៍ថា របាយការណ៍សរសេរពេលការសម្ភាសន៍ ត្រូវបានធ្វើឡើងក្រោយពេលដែលបញ្ជីឈ្មោះសាក្សីត្រូវបានដាក់ជូនតុលាការដោយសហព្រះរាជអាជ្ញា ។

លោកស្រី អានតា ហ៊ុីស្សេ បានថ្លែងថា ប្រសិនបើសាក្សីត្រូវបានកោះហៅនេះសបញ្ជាក់ពីភាពបរាជ័យនៃការកាត់ក្តីនេះ ។ វាជាការខូចខាតនៃយុត្តិធម៌ ។

បន្ទាប់មក សហមេធាវីនាំមុខ បានស្នើឲ្យមានការដាក់បញ្ចូលរបាយការណ៍ក្នុងសៀវភៅ *Cambodia's Hidden Scars* ដើម្បីធ្វើការពិភាក្សា ។ សហមេធាវីនាំមុខអន្តរជាតិ លោកស្រី ម៉ារី ហ៊ីរ៉ូដ បានបញ្ជាក់ថា ឯកសារនេះត្រូវបានចងក្រងដោយសាកលវិទ្យាល័យស្តេនហ្វដ ។ សហព្រះរាជអាជ្ញាបានគាំទ្រការស្នើសុំនេះ ។ មេធាវីការពារក្តីឲ្យ នួន ជា បានលើកឡើងថា ស្តេនហ្វដ ជាសកលវិទ្យាល័យមានកេរ្តិ៍ឈ្មោះល្អ តែតម្លៃបញ្ជាក់នៃរបាយការណ៍នេះមិនសូវខ្ពស់នោះទេ ។ សហមេធាវីនាំមុខ ម៉ារី ហ៊ីរ៉ូដ បានឆ្លើយតបថា ក្រុមការពារក្តីឲ្យ នួន ជា គួរតែបង្កើតការដាក់សុំពិនិត្យសម្រេចដោយខ្លួនឯង ទាក់ទិននឹងតម្លៃបញ្ជាក់នៃរបាយការណ៍ ។

### ***សាក្សី 2-TCW-971***

*សាក្សី 2-TCW-971* បានបំភ្លឺតាមរយៈតំណភ្ជាប់តាមប្រព័ន្ធសោតទស្សន៍ ។ សាក្សីបានចាប់ផ្តើមផ្តល់សក្ខីកម្មដំបូង ប៉ុន្តែមិនអាចផ្តល់សក្ខីកម្មបានរយៈពេលជាងកន្លះម៉ោងទេដោយសារតែបញ្ហារអាក់រអួលប្រព័ន្ធអ៊ីនធឺណិត ។ ថ្ងៃនេះ ការផ្តល់សក្ខីកម្មរបស់លោកក៏មានសភាពយឺតយ៉ាវដោយសារតែប្រព័ន្ធអ៊ីនធឺណិតមានភាពរអាក់រអួលជាច្រើនលើកច្រើនសា ។

អង្គសវនាការត្រូវបានប្រគល់ទៅឲ្យមេធាវីការពារក្តីឲ្យ នួន ជា ។ លោកមេធាវី កូប៉េ បានសាកសួរពីទីតាំងឃ្លាំងស្តុកស្រូវ ថា តើឃ្លាំងនោះមានទីតាំងនៅថ្មគោលមែនឬទេ?

តាម៉ុក បានបញ្ជាសាក្សីឲ្យធ្វើដំណើរទៅខេត្តបាត់ដំបង ។ ប្រជាជនក្នុងកងចល័តត្រូវបានគេប្រើប្រាស់ ហើយមិនត្រូវបានឃុំឃាំងនោះទេ ។ តាឆាយ បានណែនាំសាក្សីថា ប្រជាជនដែលស្ថិតនៅក្នុងកងចល័តអនុញ្ញាតឲ្យវិលត្រឡប់ទៅផ្ទះវិញបាន ។

### ***ការធ្វើឲ្យការងារ និងស្ថានភាពរស់នៅមានភាពប្រសើរឡើង***

លោកមេធាវី កូប៉េ បានសាកសួរថា តើឃ្លាំងស្តុកស្រូវក្នុងស្រុកថ្មគោលមានទីតាំងនៅកន្លែងណា ។ សាក្សីមិនដឹងថាមានស្រូវចំនួនប៉ុន្មានត្រូវបានគេស្តុកទុកក្នុងឃ្លាំងនោះទេ ។ ឃ្លាំងមួយនោះស្តុកពាងស្ករត្នោត និងអង្ករ ។ វាមានទីតាំងនៅតំបន់៣ ។ លោកមេធាវី កូប៉េ បានសាកសួរបន្តទៀតថា ឃ្លាំងក្នុងតំបន់ដូនទាវនោះមានទីតាំងស្ថិតនៅត្រង់ចំណុចណា ។

លោកមេធាវី កូប៉េ បានស្នើឲ្យបិទវីដេអូ ហើយស្តាប់សំឡេងវិញ ។ លោក គាំចាន់ បានគាំទ្រការស្នើសុំនេះ ហើយពុំមានភាគីផ្សេងទៀតជំទាស់ឡើយ ។ នៅទីនោះពុំមានស្រូវអង្ករឡើយ ។ លោកមេធាវី កូប៉េ បានសាកសួរថា តើនៅកន្លែងផ្សេងទៀតមានឃ្លាំងស្រដៀងឃ្លាំងនៅថ្មគោលដែរឬទេ ។ លោកមេធាវី បានសាកសួរថា តើសាក្សីអាចដោះស្រាយការខ្វះខាតស្រូវតាមរបៀបគ្រប់គ្រងដែរឬទេ ។ លោកមេធាវី កូប៉េ បានចោទសួរថា សាក្សីដឹងដោយរបៀបណាថាស្រូវត្រូវបានស្តុកទុកនៅឃ្លាំងថ្មគោល ។ សាក្សីបានតបថា មានស្ត្រីប្រាប់គាត់ពីរឿងនេះ ហើយលោកបានធ្វើការចែកចាយស្រូវគុណភាពមិនល្អទៅកាន់ភូមិជិតៗ ។ ពួកគេមកពីស្រែអំបិលនៅជិតនោះ ។ លោកមេធាវី កូប៉េ បានសំដៅទៅរបាយការណ៍ប្រចាំសប្តាហ៍ថ្មីដែលបញ្ជាក់ពីកន្លែងលាក់ស្រូវ ។ សាក្សីបានថ្លែងថា លោកមិនដែលឮពីរឿងនេះទេ ។ លោកមេធាវី កូប៉េ បានសួរថា សាក្សីបានធ្វើអ្វីដើម្បីសម្រាលស្ថានភាពការងាររបស់ប្រជាជនទេ ។ សាក្សីបានឆ្លើយតបថា លោកបានចែកចាយ

អាហារដែលស្តុកទុកក្នុងឃ្លាំង ។ តាឆាយ បានណែនាំកុមារ និងកងចល័តឲ្យវិលត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ។

លោកមេធាវី កូប៉េ បានសាកសួរថា សាក្សីមានន័យដូចម្តេចនៅពេលដែលលោកនិយាយថាពួកគេកម្ទេចសកម្មភាពទាំងនោះចោល ។ សាក្សីបានឆ្លើយថា លោកបានបញ្ឈប់ប្រជាជនពីការធ្វើការលើសម៉ោង ហើយផ្តល់របបអាហារឲ្យពួកគេគ្រប់គ្រាន់ ។ លោកបានប្រកាសថា អ្នកទាំងអស់គ្នាគួរតែត្រឡប់ទៅផ្ទះវិញ ។ នៅពេលដែលលោកទៅខេត្តបាត់ដំបង លោកមិនបានទៅមើលគ្រប់កន្លែងនោះទេ ។ លោកបានឃើញប្រជាជនធ្វើការនៅវាលស្រែជាក្រុមៗ នៅស្រុកថ្មគោល និងស្រុកមង្គលបុរី ។ ពួកគេពុំមានផ្ទះសម្បែងសមរម្យនោះទេ ។ លោកមេធាវី កូប៉េ បានសាកសួរថា សាក្សីមានការយល់ស្របជាមួយនឹងការអង្កេតរបស់ អៀង ធីរិទ្ធ ដែរឬទេ ដែលថាមានភាពខុសប្រក្រតីកំពុងតែកើតឡើងនៅខេត្តនោះ ។ សាក្សីបានបញ្ជាក់ថា លោកយល់ស្រប ហើយលោកបាននិយាយថា លោកបានឃើញប្រជាជនធ្វើការនៅវាលស្រែ ។ លោកមេធាវី កូប៉េ បានថ្លែងថា លោកស្រី អៀង ធីរិទ្ធ បាននិយាយថា ស្ថានភាពមានភាពផ្ទុយគ្នាពីគោលការណ៍ការងារ ។ សាក្សីបានឆ្លើយថា លោកបានឃើញអ្វីដូចដែល អៀង ធីរិទ្ធ បានរៀបរាប់ ។ ប្រជាជនពុំមានផ្ទះសម្បែងសមរម្យឡើយ ហើយនេះល្មើសនឹងវិន័យ ចំណែកឯប្រជាជនធ្វើកិច្ចការងារលំបាកយ៉ាងខ្លាំង ។ លោកមេធាវី កូប៉េ បានសាកសួរថា សាក្សីបានចាត់វិធានការអ្វីដើម្បីសម្រាលបន្ទុកការងាររបស់ប្រជាជន ។ សាក្សីបានតបថា លោកយល់ឃើញថា ស្ថានភាពនឹងមានភាពល្អប្រសើរឡើងប្រសិនបើពួកគេធ្វើការរៀងខ្លួននៅតាមភូមិ ជាជាងធ្វើការតាមក្រុម ។ សាក្សីពុំបានកាត់បន្ថយម៉ោងធ្វើការនោះទេ ហើយលោកបានថ្លែងថា លោកនៅទីនោះតែរយៈពេលខ្លីតែប៉ុណ្ណោះ ។

ចំពោះម៉ោងធ្វើការ សាក្សីបានឆ្លើយថា ប្រជាជនសម្រាកម៉ោង១១ព្រឹក ប៉ុន្តែម៉ោងចូលធ្វើការវិញគឺពុំមានភាពទៀងទាត់ឡើយ ។ លោកមេធាវី កូប៉េ បានសាកសួរថា តើវិន័យបានកំណត់ថាប្រជាជនចាប់ផ្តើមធ្វើការ៨ម៉ោងក្នុងមួយថ្ងៃ ដោយមានពេលសម្រាកចំនួន១៥នាទីក្នុងរយៈពេលមួយម៉ោង ហើយចំពោះម៉ោងបាយថ្ងៃត្រង់អាចសម្រាកបានយូរមែនឬទេ ។ សាក្សីបានឆ្លើយថា ពុំមានកាលវិភាគត្រឹមត្រូវឡើយ ដោយម៉ោងធ្វើការងារមានសភាពមិនទៀងទាត់ ។

សាក្សីពុំបានដឹងពីការអង្កេតពាក់ព័ន្ធការកាប់សម្លាប់ខុសច្បាប់ឡើយ ហើយលោកស្គាល់តែអ្នកដែលមកខេត្តបាត់ដំបងជាមួយក្រុមលោកទេ ។ លោកមិនដឹងថាអ្នកទាំងនោះមកពីភូមិភាគនិរតីនោះឡើយ ។

លោកមេធាវី កូប៉េ បានសាកសួរថា តើសាក្សីដឹងថាមូលហេតុនៃការចាប់ខ្លួន រស់ ញឹម គឺមកពី រស់ ញឹម មានការពាក់ព័ន្ធជាមួយនឹងការសម្លាប់ខ្មែរក្រោមមែនឬយ៉ាងណា ។ សាក្សីបានឆ្លើយថា លោកមិនដឹងពីរឿងនេះឡើយ ហើយលោកក៏មិនដឹងពីរឿងពាក់ព័ន្ធនឹង រស់ ញឹម ដែរ ។ លោក គាំចាន់ បានសួររកឯកសារយោង ។ លោកមេធាវី កូប៉េ បានឆ្លើយថា ភ័ស្តុតាងពាក់ព័ន្ធនឹងការលើកឡើងរបស់លោកមិនបានដាក់បញ្ចូលឡើយ ។

លោកមេធាវី កូប៉េ បានសាកសួរថា សាក្សីបានដឹងឮរឿងអ្វីពាក់ព័ន្ធការចាប់ខ្លួនរបស់ រស់ ញឹម ដែរឬទេ ។ សាក្សីបានឆ្លើយថាលោកពុំធ្លាប់ឮឡើយ ។

**ការចាត់តាំង**

អន្តរសវនាការត្រូវបានប្រគល់ជូនសហព្រះរាជអាជ្ញា ។ សាក្សីពុំធ្លាប់ស្គាល់យាយ រឹម ទេ ។ លោក គាំចាន់ បានសាកសួរថា សាក្សីធ្លាប់បានឮពីការសម្លាប់ខ្មែរក្រោមនៅស្រុកបាកាន ក្នុងឆ្នាំ១៩៧៨ ដែរឬទេ ។ លោកមេធាវី កូប៉េ បានសួររកឯកសារយោង ។

សាក្សីនៅពេលនោះមានភាពភ័យខ្លាច ។ បងប្អូនជីដូនមួយរបស់សាក្សីបានស្លាប់នៅពេលដែលពួកគេប្រយុទ្ធជាមួយទាហានលន់ នល់ ។ សាក្សីត្រូវបានគេចាត់តាំងមកស្រុកមង្គលបុរី មុនពេលទាហានវៀតណាមចូលមកដល់ ។ សាក្សីបានឆ្លើយថា នៅពេលដែលទាហានវៀតណាមចូល ពួកគេពុំទាន់ចូលទឹកដីខេត្តភ្នំៗនោះទេ ។ សាក្សីបានបន្តថា នាពេលនោះ តាម៉ុក ពុំមែនជាលេខាតំបន់ឡើយ ។ សាក្សីនឹងធ្វើការរាយការណ៍ផ្ទាល់ទៅ តាឆាយ ។ បើតាមលោកដឹង តាឆាយ នឹងបន្តរាយការណ៍ទៅ តាម៉ុក ។ ពុំមានការប្រកាសជាផ្លូវការណាមួយបញ្ជាក់ថា អ្នកណាជាអ្នកគ្រប់គ្រងតំបន់ឡើយ ។

លោកមេធាវី កូប៉េ បានសាកសួរសាក្សីថា តើតាធំជាលេខាតំបន់៣ នៅពេលដែលសាក្សីទៅកាន់តំបន់នោះមែនឬទេ ។ សាក្សីបានឆ្លើយថាតំណែងនេះនៅទំនេរ ហើយលោកពុំឃើញអ្នកណានៅក្នុងមន្ទីរពាណិជ្ជកម្មឡើយ ។ សាក្សីធ្លាប់ឮថា តាធំ ជាលេខាតំបន់ ប៉ុន្តែលោកពុំដែលឃើញតាធំឡើយ ហើយលោកក៏មិនដឹងថាតាធំ បាត់ខ្លួននៅពេលណាដែរ ។

សាក្សីឃើញស្រូវនៅពេលដែលលោកដើរចូលឃ្លាំង ។ ស្រូវមិនត្រូវបានគេលាក់ទុកនោះទេ ។ ស្រូវមួយចំនួនពុំត្រូវបានគេប្រើប្រាស់ឡើយ ដោយសារតែវាត្រូវបានគេស្តុកទុកក្នុងឃ្លាំងយូរពេក ។ លោកពុំបានឃើញគេដឹកស្រូវចេញនោះឡើយ ។

លោកសហព្រះរាជអាជ្ញា គាំចាន់ បានសាកសួរពីការនាំស្រូវចេញ ។ នៅពេលដែលលោកគាំចាន់ បានសាកសួរថាសាក្សីធ្លាប់ឮពីការពន្យល់បកស្រាយថា ការខ្វះស្បៀងគឺបណ្តាលមកពីការនាំស្រូវចេញទេ លោកមេធាវី កូប៉េ បានថ្លែងថាការពន្យល់បកស្រាយនេះពុំមានភាពខុសប្លែកឡើយ ដោយស្រូវនៅតែត្រូវបានគេលាក់ទុក ។ លោកគាំចាន់ បានអានសេចក្តីដកស្រង់ ដែលបង្ហាញថាមានការខ្វះខាតស្បៀង ហើយស្រូវត្រូវបានគេនាំចេញ ។ សាក្សីបានឆ្លើយថាលោកមិនដឹងទេដោយសារតែមន្ទីរពាណិជ្ជកម្មរបស់លោកពុំមានការពាក់ព័ន្ធជាមួយនឹងការដឹកជញ្ជូនឡើយ ។

### **វេចនាសម្ព័ន្ធដឹកនាំ**

លោក គាំចាន់ បានសាកសួរថា សាក្សីធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលនៅភ្នំពេញដែរឬទេ ។ សាក្សីបានបដិសេធ ។ សាក្សីក៏ពុំធ្លាប់បានជួប ខៀវ សំផន ឬ នួន ជា ដែរ ។ លោកមិនចាំពីពេលវេលាដែលក្រុមកម្មាភិបាលពីភូមិភាគនិរតីបានមកដល់ភូមិភាគពាយ័ព្យលើកដំបូងទេ ។ ក្រោយពេលលោកមកដល់ លោកបានទៅកាន់កងរបស់លោក ហើយសាកសួរប្រជាជនថា លោកស្ថិតក្នុងទីតាំងណា ។ លោកត្រូវបានគេប្រាប់ថា តាធំ ជាអ្នកទទួលបន្ទុកក្នុងតំបន់ ប៉ុន្តែលោកមិនដឹងថាលោកធ្វើដំណើរទៅកាន់ទីណានោះទេ ។ លោកមិនបានជួបកម្មាភិបាលទាំងអស់ក្នុងតំបន់នោះទេ ។ លោកបានឃើញប្រជាជនខ្លះធ្វើការ ហើយមានស្ត្រីខ្លះមកពីស្រែអំបិល ។ ប្រជាជនទាំងនោះខ្លះមកពីភូមិភាគនិរតី ហើយបម្រើការនៅមន្ទីរពាណិជ្ជកម្ម ។

លោក គាំចាន់ បានអានការដកស្រង់ពីចម្លើយរបស់សាក្សីត្រង់ចំណុចដែលលោកឆ្លើយថា ប្រជាជនត្រូវបានបែងចែកជាពីរទៅបីក្រុម ។ សាក្សីបានឆ្លើយថា ប្រជាជនត្រូវបានគេអនុញ្ញាតឲ្យរស់នៅក្នុងសហករណ៍ ដោយសារតែពួកគេមានវ័យចំណាស់ ហើយប្រជាជនក្មេងៗត្រូវបានគេអនុញ្ញាតឲ្យរស់នៅកងកុមារ ។ លោកមិនអាចបែងចែកថា អ្នកណាជាប្រជាជនថ្មីឬចាស់ទេ ។ លោក គាំចាន់ បានសាកសួរថា គេចាត់តាំងសាក្សីឲ្យធ្វើអ្វី នៅស្រុកដូនទាវ ។ សាក្សីបានឆ្លើយថា លោកបានទៅទីនោះរយៈពេលដប់ថ្ងៃដើម្បីពិនិត្យសហករណ៍ និងកង ។ លោក គាំចាន់ បានសាកសួរពីការងាររបស់សាក្សីនៅស្រុកថ្មគោល ។ សាក្សីបានឆ្លើយថា លោកទទួលបន្ទុកក្នុងការចែកចាយសម្ភារក្នុងឃ្លាំង ។ លោកមិនដែលស្គាល់ប្រធានកសិកម្ម ឬប្រធានរោងម៉ាស៊ីនកិនស្រូវនោះទេ ។ លោក គាំចាន់ បានថ្លែងថា បញ្ជីរបស់ការិយាល័យសហមេធាវីស៊ើបអង្កេតបានបញ្ជាក់ថា លឹម ម៉ន គឺជាប្រធានកសិកម្ម ហើយអ៊ឹង អាំអេន គឺជាប្រធានរោងម៉ាស៊ីនកិនស្រូវ ។ លោក គាំចាន់ បានសួរថា សាក្សីមានការចងចាំពីការចាប់ខ្លួនរបស់ពួកគេទាំងពីរនាក់នេះទេ ។ សាក្សីបានឆ្លើយថា លោកមិនដែលឃើញឬស្គាល់អ្នកទាំងពីរនេះទេ ហើយលោកក៏មិនដែលស្គាល់ វង់ ឡាត និង ហៃ លុប ដែរ ។ លោក គាំចាន់ បានសាកសួរពីឈ្មោះ ឆាយ ឆន ហៅ ឈន ។

លេខាស្រុកបរវេលត្រូវបានចាប់ខ្លួនក្នុងខែមិថុនា ឆ្នាំ ១៩៧៧ ហើយអនុលេខា គឹម ត្រូវបានចាប់ខ្លួនក្នុងខែមករា ឆ្នាំ១៩៧៨ ។ លោក គាំចាន់ បានសួរសាក្សីថា លោកដឹងពីការចាប់ខ្លួនថ្នាក់ដឹកនាំស្រុកបរវេលដែរឬទេ ។ សាក្សីបានបដិសេធដោយឆ្លើយថា លោកមានឋានៈទាប ហើយលោកមិនដឹងថាអ្នកណាជាមេស្រុកចាស់ដែរ ។ លោកធ្វើការតាមការណែនាំរបស់ តាឆាយ ។ លោក គាំចាន់ បានសាកសួរសាក្សីថាស្គាល់ វង់ ដែរឬទេ ។ សាក្សីធ្វើការបដិសេធ ។

បន្ទាប់មក លោក គាំចាន់ បានសាកសួរសាក្សីថាធ្លាប់បានឮតាម៉ុកនិយាយពីសត្រូវដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនដឹងថា គេចាត់ទុកអ្នកណាជាសត្រូវនោះទេ ។ លោក គាំចាន់ បានដកស្រង់ចម្លើយរបស់សាក្សី ដែលលោកបានឆ្លើយថា ពួកគេមាន

ការប្រុងប្រយ័ត្នចំពោះសត្រូវខាងក្នុង ។ ពាក្យនេះត្រូវបានគេប្រើប្រាស់ក្នុងការប្រជុំដឹកនាំដោយ តាឆាយ ។ ការប្រជុំជារឿយៗតែងតែផ្តោតលើផលិតផលកសិកម្ម ។

សាក្សីបានរៀបរាប់ថា ពួកគេនិយាយពីកម្លាំងបង្កប់ដែលសំដៅទៅលើកម្លាំង លន់ នល់ ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ។ ពួកគេត្រូវបានប្រាប់ថា មានការប្រុងប្រយ័ត្ន ។

លោក តាំចាន់ បានផ្តល់ឯកសារយោងពីការសម្លាប់ខ្មែរក្រោមដែលលោកបានលើកឡើងមុននេះបន្តិច ។ ជាមួយនឹងឯកសារយោងនេះ លោកបានធ្វើការសរុបការសាកសួររបស់លោក ។

**ការចាត់តាំងនៅស្រុកត្រាំកក់**

អង្គសវនាការត្រូវបានប្រគល់ទៅឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឡោ ឈុនទី ។ លោក ឈុនទី ចង់ដឹងពីតួនាទីរបស់សាក្សីនៅស្រុកត្រាំកក់ពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ។ សាក្សីបានឆ្លើយថា លោកជាគ្រូបង្រៀនកុមារ និងយុវជន ។ នៅពេលសាកសួរពីជីវភាពរស់នៅ សាក្សីបានឆ្លើយថា ប្រជាជនទទួលបានបាយដើម្បីបរិភោគតែប៉ុន្មានខែតែប៉ុណ្ណោះ ហើយក្រោយមកពួកគេបរិភោគបបរ ។ លោកមិនដឹងថាមានកម្មាភិបាលប៉ុន្មាននាក់ត្រូវបានគេបញ្ជូនទៅខេត្តបាត់ដំបងនោះទេ ។ សាក្សីបានឆ្លើយថា ពួកគេត្រូវបានបញ្ជូនមកជាលើកទីបី ហើយពួកគេភាគច្រើនជាកុមារនិងយុវជន ។ ក្នុងសហករណ៍ ប្រជាជនបរិភោគធម្មតា ប៉ុន្តែនៅក្នុងកងចល័ត ពួកគេបរិភោគខុសប្លែកពីគេ ។ នៅពេលដែលសាក្សីសួរថ្នាក់លើថាហេតុអ្វី ពួកគេប្រាប់លោកថា នេះដោយសារតែមានបញ្ហាផ្នែកដឹកជញ្ជូន ។

លោក ឈុនទី បានសួរថា ខ្លឹមសារសំខាន់ក្នុងការប្រជុំជាមួយ តាម៉ុក គឺអ្វី? សាក្សីបានឆ្លើយថា លោកមិនដែលចូលរួមការប្រជុំជាមួយ តាម៉ុក ទេ តែលោកធ្លាប់ចូលរួមប្រជុំជាមួយ តាឆាយ ។ សាក្សីត្រូវបានគេណែនាំឲ្យវាយកង ប៉ុន្តែវាមិនមានភាពស៊ីសង្វាក់ជាមួយនឹងការណែនាំផ្សេងទៀតដែលលោកទទួលបានឡើយ ។ វាហាក់ដូចជាមានក្រុមពីរផ្សេងគ្នា ។ ពួកគេបានធ្វើការផ្ទេរតាមការចាត់តាំងរបស់ពួកគេ ដោយសារតែពួកគេមានភាពភ័យខ្លាច ។ សាក្សីខ្លាចគេចោទថាលោកស្ថិតក្នុងក្រុមក្បត់ ។ លោកត្រូវបានគេផ្ទេរចេញ ហើយលោកមិនដឹងថាក្រោយមកមានរឿងអ្វីកើតឡើងទៀតឡើយ ។

សាក្សីស្គាល់ តាទិត ដែលធ្លាប់ជាព្រះសង្ឃតែសឹកក្នុងឆ្នាំ១៩៧៥ ហើយចាប់តាំងពីពេលនោះមក សាក្សីពុំបានដឹងថា តាទិតមានតួនាទីឬធ្វើអ្វីឡើយ ។

សាក្សីស្គាល់យាយថែម ដែលមកពីខេត្តតាកែវ ប៉ុន្តែយាយថែម ទៅភូមិភាគពាយ័ព្យមុនលោក ហើយបើតាមលោកដឹង ពេលយាយថែម នៅភូមិភាគពាយ័ព្យ យាយថែម ធ្វើការនៅគណៈស្រុកភ្នំស្រុក ។

ប្រជាជននៅកងចល័តពេលនោះកំពុងប្រមូលផលស្រូវ ហើយអ្នកផ្សេងទៀតលើកទំនប់ ។ ស្របពេលជាមួយគ្នានេះ លោក ឈុនទី បានធ្វើការសរុបការសាកសួររបស់លោក ។

បន្ទាប់មក លោកចៅក្រម ឡាវីញ បានដាក់សំណួរទៅកាន់សាក្សី ។ លោកចៅក្រមចង់ដឹងថា បងប្អូនជីដូនមួយរបស់សាក្សីដែលបានស្លាប់ក្នុងជំនាន់ លន់ នល់ នោះ ជាទាហាន លន់ នល់ ឬជាទាហានបដិវត្តន៍ ។ សាក្សីបានឆ្លើយថា ពួកគេជាទាហានបដិវត្តន៍ ។ ពូរបស់សាក្សីស្លាប់ក្រោយឆ្នាំ១៩៧៥ ។ លោកចៅក្រម បានសាកសួរថា ពូរបស់សាក្សីជាគ្រូបង្រៀនមែនឬទេ ។ សាក្សីបានឆ្លើយថា ពូរបស់លោកជាគ្រូបង្រៀនតាំងពីជំនាន់សង្គមរាស្ត្រនិយម រហូតដល់ជំនាន់ លន់ នល់ ។ សាក្សីក្រោយមកទើបក្លាយជាគ្រូបង្រៀន ។ ការបាត់ខ្លួនរបស់ពូលោកធ្វើឲ្យមានការព្រួយបារម្ភ ដោយសារតែសាច់ញាតិរបស់លោកស្លាប់ដោយគ្មានមូលហេតុ ។ សាច់ញាតិរបស់លោកមួយចំនួនបានស្លាប់ ។ ប្អូនស្រីរបស់លោកស្លាប់ក្នុងកងចល័តដោយសារជំងឺ ។ លោកបានឮគេនិយាយពីក្រាំងតាចាន់ តែលោកមិនថាវាមានទីតាំងនៅកន្លែងណានោះទេ ហើយលោកក៏មិនដែលទៅទីនោះដែរ ។ បងស្រីជីដូនមួយលោកធ្វើការនៅកងចល័ត ហើយឪពុករបស់បងស្រីជីដូនមួយម្នាក់នោះគឺជាអតីតទាហាន ។ ដោយហេតុផលនេះហើយ បងស្រីជីដូនមួយរបស់លោកត្រូវបានគេបញ្ជូនទៅកាន់កងចល័ត ហើយក៏បានបាត់ខ្លួនរហូត ។ សាក្សីពុំដឹងពីហេតុផលនៃការបាត់ខ្លួនរបស់ពូលោកនោះទេ ។

សាក្សីត្រូវបានសាកសួរពីការប្រជុំជាមួយ តាម៉ុក ។ សាក្សីបានឆ្លើយថា លោកកម្រជួប តាម៉ុក ណាស់ ។ លោកពុំហ៊ានទៅជួប

តាម៉ុក ទេ ប្រសិនបើគ្មានការកោះហៅឲ្យទៅខេត្តបាត់ដំបង ។ លោកបានជួប តាម៉ុក នៅពេលដែល តាឆាយ ហៅលោកទៅខេត្តបាត់ដំបង ។

## សំណួរពីចៅក្រម

ចៅក្រម ឡាវែញ បានសាកសួរថា សាក្សីធ្លាប់បានឃើញ នួន ជា ឬ ខៀវ សំផន នៅពេលលោកទៅស្រុកត្រាំកក់ តំបន់១៣ ដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនដែលឃើញពួកគេតាំងពីឆ្នាំ១៩៧០ មកម៉្លេះ ។ មានមេស្រុកម្នាក់មានឈ្មោះ ឈឿន ក៏ជាប្រធានពាណិជ្ជកម្មផងដែរ ។ សាក្សីបានបញ្ជាក់ថាលោកទាក់ទង ឈឿន នៅពេលមានចម្ងល់ ។ មនុស្សបួននាក់ធ្វើការនៅមន្ទីរពាណិជ្ជកម្ម រួមមាន ឈឿន សាក្សី ហើយមនុស្សពីរនាក់ផ្សេងទៀត ។ ពាក់ព័ន្ធនឹងការងាររបស់សាក្សីនៅផ្នែកពាណិជ្ជកម្ម សាក្សីបាននិយាយថា មន្ទីរមានទីតាំងនៅកន្លែងដែលគេស្តុកស្រូវដើម្បីចែកចាយ ដែលមិនមែនសម្រាប់ធ្វើជំនួញ ។ ចំណែកឯនៅស្រុកត្រាំកក់ មន្ទីរមិនសូវមានភាពមមាញឹក ហើយពួកគេមានពេលសម្រាក ។ ក្នុងខេត្តបាត់ដំបង មន្ទីរមានភាពមមាញឹកជាងកន្លែងផ្សេងៗ ។

លោកចៅក្រម ឡាវែញ ចង់ដឹងថាតើសាក្សីដឹងពីរបបអាហារកំណត់ដែលប្រជាជនទទួលបានដែរឬទេ ។ សាក្សីបានឆ្លើយថា មនុស្សម្នាក់ទទួលបានអាហារមួយកំប៉ុង ។ បើតាមលោកដឹង ប្រជាជននៅស្រុកត្រាំកក់ និងខេត្តបាត់ដំបងក៏ទទួលបានរបបដូចនេះដែរ ។ មានមនុស្សផ្សេងៗគ្នាដែលទទួលខុសត្រូវដើម្បីឲ្យប្រាកដថា របបអាហារត្រូវបានចែកទៅប្រជាជន ។ ប្រធានក្រុមរាយការណ៍មកសាក្សី និងសមមិត្តផ្សេងទៀត ហើយសាក្សីបន្តរាយការណ៍ទៅប្រធាន ។ ចុងឆ្នាំ របបអាហារមានចំនួនតិចជាងដើមឆ្នាំ ដូច្នេះពួកគេធ្វើការកាត់បន្ថយរបបអាហារ ។ សាក្សីបានជួបប្រទះហេតុការណ៍បែបនេះនៅស្រុកត្រាំកក់ ។ លោកចៅក្រម ឡាវែញ បានសួរថា សាក្សីបានដឹងពីការខ្វះខាតអាហារនៅស្រុកត្រាំកក់ដែរឬទេ ។ សាក្សីបានបញ្ជាក់ថាលោកដឹង ។ ការប្រជុំប្រចាំខែត្រូវបានគេផ្តោតលើទិន្នផល ។ ផែនការនៃការផលិតស្រូវមានចំនួន៣តោនក្នុងមួយហិកតា ហើយចំនួនកូតានេះកន្លែងណាក៏ពុំអាចសម្រេចបានដែរ ។ កន្លែងដែលពុំអាចសម្រេចចំនួនកំណត់ទុកនេះ នឹងទទួលបានរបបអាហារតិច ។ កន្លែងដែលអាចសម្រេចបានច្រើន ទទួលបានផលប្រយោជន៍ខ្លះ ។ ពួកគេទទួលបានការរាយការណ៍ពីសហករណ៍ និងស្រុកទាក់ទិននឹងទិន្នផលសរុបប្រចាំឆ្នាំ ។

លោកចៅក្រម ឡាវែញ បានបង្ហាញឯកសារទៅកាន់សាក្សី ដែលបង្ហាញពីផលិតផលស្រូវ ហើយលោកចៅក្រមបានសាកសួរថាសាក្សីធ្លាប់ឃើញដែរឬទេ ។ សាក្សីបានឆ្លើយថា លោកមិនដែលឃើញរបាយការណ៍បែបនេះឡើយ ។

លោកចៅក្រម ឡាវែញ បានសាកសួរថាតើស្រូវត្រូវបានគេធ្វើការផ្លាស់ប្តូរជាមួយនឹងផលិតផលផ្សេងទៀតដែរឬទេ ។ សាក្សីបានបដិសេធ ដោយឆ្លើយថា លោកមិនយល់ពីសំណួរនេះឡើយ ។ បញ្ជីនេះគឺជាបញ្ជីចំនួនស្រូវដែលពួកគេទទួលបាន ។ សាក្សីមិនដឹងថាអ្នកណាជាអ្នកគ្រប់គ្រងរោងម៉ាស៊ីនកិនស្រូវនោះទេ ។ ប្រសិនបើរោងម៉ាស៊ីនមានទំហំធំ នោះវាស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងភូមិភាគ មិនមែនស្ថិតក្រោមតំបន់ឡើយ ។ លោកចៅក្រម ឡាវែញ បានបង្ហាញឯកសារទៅកាន់សាក្សីដែលនិយាយពីការខ្វះខាតអាហារក្នុងឆ្នាំ១៩៧៧ ។ លោកចៅក្រម បានសួរថាតើមានការទាក់ទងជាមួយនឹងរបាយការណ៍ដែលសាក្សីទទួលបាននៅមន្ទីរស្រុកដែរឬទេ ។ សាក្សីបានឆ្លើយថា លោកពុំដែលទទួលរបាយការណ៍បែបនេះទេ ដោយសាររបាយការណ៍ត្រូវគេបញ្ជូនទៅគណៈស្រុក មិនមែនទៅមន្ទីរពាណិជ្ជកម្មឡើយ ។ លោកបានបង្ហាញឯកសារមួយទៀត ហើយបាននិយាយថាលោកមិនដឹងពីការចំណាយនេះទេ ។ លោកពុំអាចចំណាំថាអក្សរនេះសរសេរដោយអ្នកណាឡើយ ។ លោកចៅក្រម ឡាវែញ បានសាកសួរថា សាក្សីដឹងទេថា ប្រជាជននៅស្រុកត្រាំកក់ត្រូវបានចាប់ខ្លួនដោយសារតែពួកគេលួចចំណីអាហារ ។ អ្នកភូមិរាយការណ៍ទៅថ្នាក់ស្រុក ហើយថ្នាក់ស្រុកបន្តទៅថ្នាក់លើ ។ សាក្សីពុំបានដឹងឡើយថាក្រណាត់ត្រូវបានគេយកទៅទុកនៅទីតាំងណានោះទេ ។

លោកចៅក្រម ឡាវែញ បានសរុបការសាកសួរ ហើយ អង្គសវនាការត្រូវបានប្រគល់ជូនមេធាវីការពារក្តីឲ្យខៀវ សំផន ។ សហមេធាវីជាតិ លោក គង់ សំអូន បានប្រកាសថាពួកគេពុំមានសំណួរទេ ។ **លីអ៊ូនី គីវេស្តី**

# ចំណាប់អារម្មណ៍របស់សិស្សានុសិស្សអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(ពីឆ្នាំ១៩៧៥-១៩៧៩)

នៅក្នុងខែឧសភានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនសម្រាប់សិស្សវិទ្យាល័យ ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) ជាមួយសិក្សានុសិស្សមកពីវិទ្យាល័យអនុវត្តន៍ចំនួន៧១នាក់ ។ កម្មវិធីនេះធ្វើឡើងក្នុងវិចិត្រសាលសិល្បៈសហសម័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា អាគារ H នៃវិទ្យាស្ថានជាតិអប់រំ ។ នេះគឺជាវេទិកាលើកទី២១ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំឡើងតាមវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ ។ ចាប់តាំងពីឆ្នាំ២០១៦មក វេទិកាថ្នាក់រៀនមានសិស្សានុសិស្សចូលរួមសរុបទាំងអស់ចំនួន១៥៩១នាក់ ។ វេទិកានេះធ្វើឡើងដើម្បីជាការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ ដើម្បីជួយដល់ការពង្រីកចំណេះដឹងរបស់សិស្សានុសិស្សក្នុងការបង្កើនការគិតយ៉ាងស៊ីជម្រៅពីការកសាងសន្តិភាព ការផ្សះផ្សា ព្យាបាលរបួសផ្លូវចិត្តដល់ជនរងគ្រោះ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជានាពេលអនាគត ។

វេទិកាថ្នាក់រៀន មិនត្រឹមតែជាការបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនោះទេ យើងមានទាំងការបង្រៀនសិស្សឲ្យចេះសម្ភាសន៍ ពិភាក្សាយ៉ាងស៊ីជម្រៅពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមទៅកាន់ជនរងគ្រោះដូចជា ឪពុកម្តាយ ជីដូនជីតា អ្នកជិតខាង ព្រមទាំងអតីតកម្មាភិបាលខ្មែរក្រហម ។

យុវតី ហេង លីហ័ង អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត មានស្រុកកំណើតនៅទ្បួមខេត្តក្រចេះ ហើយផ្លាស់មករស់នៅទីក្រុងភ្នំពេញតាំងពីតូច ។ លីហ័ង ធ្លាប់តែឮយាយតានិយាយ



សិស្សឡើងសួរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ - ៧៩)

ពីរបបខ្មែរក្រហមថា ពិបាក អត់ឃ្លាន ធ្វើការគ្មានពេលឈប់សម្រាក រស់នៅយ៉ាងវេទនា និងបានរៀនតាមរយៈលោកគ្រូអ្នកគ្រូនៅក្នុងសាលាបានតិចតួច តែមិនដឹងពីមូលហេតុអ្វីដែលបង្កឲ្យកើតឡើងរបបខ្មែរក្រហម ។ ក្រោយពីបានចូលរួមស្តាប់ពីវេទិកានេះ លីហ័ង បាននិយាយថា «ខ្ញុំមានការជឿជាក់ថា ការរៀនប្រវត្តិសាស្ត្រខ្មែរក្រហមពិតជាមានសារសំខាន់សម្រាប់រូបខ្ញុំផ្ទាល់ និងមិត្តភក្តិឯទៀត ព្រោះព្រឹត្តិការណ៍ទាំងនោះកើតឡើងនៅប្រទេសរបស់យើង ហេតុនេះយើងជាក្មេងជំនាន់ក្រោយត្រូវរៀនយល់ដឹង ព្រោះមានជាតិសាសន៍ដទៃទៀតក៏គេចង់ដឹង ។ ក្នុងនាមខ្ញុំជាអ្នកសិក្សា និងត្រូវធ្វើការងារទៅថ្ងៃអនាគត ពិតជាជួបនឹងអ្នកដែលចង់ដឹងពីរឿងរ៉ាវនាសម័យនោះ ហេតុនេះហើយ នៅពេលដែលខ្ញុំយល់ដឹងកាន់តែច្រើន ខ្ញុំអាចនិយាយពីហេតុការណ៍ដែលកើតមាននៅប្រទេសកម្ពុជាទៅកាន់ជនបរទេស និងក្មេងៗជំនាន់ក្រោយ យ៉ាងហោចណាស់ក៏ខ្ញុំអាចនិយាយពីគោលការណ៍ទាំងប្រាំបីចំណុចរបស់ខ្មែរក្រហមប្រាប់ទៅអ្នកដទៃ និងមូលហេតុនៃការស្លាប់របស់ប្រជាជនយ៉ាងច្រើនក្នុងសម័យខ្មែរក្រហម ។ ចំណុចដែលពិសេសបំផុតសម្រាប់រូបខ្ញុំក្នុងនាមជាកូនរបស់ជនរងគ្រោះ ការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺជាសំណាងដែលមានឥទ្ធិពលមិនអាចកាត់ថ្លៃបាន ព្រោះខ្ញុំអាចយករឿងរ៉ាវទាំងនេះទៅពិភាក្សាដល់កូនចៅជំនាន់ក្រោយរបស់ខ្ញុំបន្ត ។ ការបានរៀន បានយល់ដឹងវាជាការផ្សះផ្សា និងបង្ការទប់ស្កាត់កុំឲ្យមានរបបនោះកើតឡើងសាជាថ្មីទៀតក្នុងប្រទេសយើង» ។

ចំណែកយុវតី ថា ដាណៃ មានអាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត ក៏ធ្លាប់សួរឪពុកម្តាយ អ្នកជិតខាងចាស់ៗ ដែលធ្លាប់ឆ្លងកាត់មក និងធ្លាប់ពិភាក្សាពីរឿងខ្មែរក្រហមជាមួយឪពុកម្តាយដែរ ព្រមទាំងលើកសំណួរជាច្រើនទៅកាន់ពួកគាត់ មានដូចជាៈ ថាវាមានរឿងអ្វីខ្លះកើតឡើងនៅពេលនោះ? មូលហេតុអ្វីបានជាមានការធ្វើទារុណកម្ម? មូលហេតុអ្វីបានជាមានការជម្លៀសប្រជាជនពីភ្នំពេញទៅជនបទក្នុងគោលបំណងអ្វី? តែចម្លើយដែល ដាណៃ ទទួលបានមកវិញពីឪពុកម្តាយនិងចាស់ៗ ត្រឹមតែឆ្លើយយ៉ាងខ្លី «វាជារឿងប្រវត្តិសាស្ត្រ» នេះជាមូលហេតុមិនអាចធ្វើការពិភាក្សាឲ្យកាន់តែស៊ីជម្រៅបាន ។ តែក្រោយពេលចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដាណៃ បាននិយាយថា «ការពិត ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមវាជារឿងសំខាន់សម្រាប់ក្មេងជំនាន់ក្រោយដូចជាខ្ញុំ នៅតាមសាលាគួរតែមានការ



រូបខាងឆ្វេង ៖ លោក សុខ វណ្ណៈ ជាវាគ្មិន ឆ្លើយសំណួររបស់សិស្សដែលសួរទាក់ទងនឹងបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម

បញ្ឈប់ឲ្យបានដូចវេទិកាថ្ងៃនេះ ។ ដារ៉ែណ បានបន្ថែមទៀតថា ជនរងគ្រោះតែងតែមានប្រតិកម្មទៅនឹងសំណាងដែលតុលាការផ្ដល់ជូនជារួម តែចំពោះខ្ញុំ ខ្ញុំគិតថាសំណាងជាការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មានគុណតម្លៃខ្ពស់ ព្រោះវាជាចំណេះដឹងដល់ខ្ញុំនឹងក្មេងជំនាន់ក្រោយៗក្នុងការយកទៅពិភាក្សាបន្ត និងបង្ការកុំឲ្យកើតរបបខ្មែរក្រហមឡើងបានទៀត ។ ចំពោះយុវតី អ៊ុន មុនី អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ ក៏មានចំណាប់អារម្មណ៍ដូចគ្នានឹងមិត្តភក្ដិដែរ ។ មុនី និយាយថា ចំពោះរូបខ្ញុំការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យវាមានសារសំខាន់ចំពោះជនរងគ្រោះ ខណៈពេលដែលក្មេងៗចេះសួរនាំ ពិភាក្សា យល់ដឹងពីរបបខ្មែរក្រហម វាជាការរួមចំណែកមួយនៃការទទួលស្គាល់ពីទុក្ខលំបាកនៃជនរងគ្រោះនាសម័យខ្មែរក្រហម ជួយរំលែកការឈឺចាប់របស់គាត់ ហើយក៏បន្តពួតដៃគ្នាបង្ការកុំឲ្យមានអំពើអមនុស្សធម៌កើតឡើងសាជាថ្មីនាពេលថ្ងៃអនាគត ។

យុវសិស្ស កាត វិសុទ្ធ អាយុ១៩ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យអនុវត្ត ធ្លាប់បានស្ដាប់រឿងរ៉ាវពីជីដូន ជីតា នាសម័យបីឆ្នាំ ។ ជីដូនជីតារបស់ វិសុទ្ធ គ្រាន់តែនិយាយអំពីការរស់នៅខ្វះៗរបស់គាត់ដែលខុសពីជនរងគ្រោះឯទៀត ជីដូនជីតា វិសុទ្ធ មិនសូវជួប ទុក្ខលំបាក ឬខ្វះខាតច្រើននោះទេ ។ គាត់មានអ្នកគ្រប់គ្រងចិត្តល្អ ការបរិភោគមិនសូវខ្វះខាតដូចតំបន់ផ្សេង ។ តែគាត់ត្រូវលាក់បាំងប្រវត្តិរូបគាត់ពីទាហានខ្មែរក្រហម ព្រោះជីតាធ្លាប់ធ្វើជាគ្រូបង្រៀននៅរបបសង្គមរាស្ត្រនិយម ។ ដោយជីតាដឹងថា ក្នុងរបបនោះ គេសម្លាប់អ្នកចេះដឹងចោល ជីតាគាត់សុខចិត្តធ្វើពុតជាមិនចេះ ហើយធ្វើតាមអ្វីដែលខ្មែរក្រហមចាត់ឲ្យធ្វើ ដូចជា ធ្វើស្រែ ដាំបន្លែជាដើម ។ វិសុទ្ធ បន្ថែមទៀតថា ខ្ញុំរំពឹងថា នឹងបានយល់ដឹងឲ្យច្រើនពីរបបខ្មែរក្រហម ហើយខ្ញុំមានអារម្មណ៍សប្បាយចិត្តដែលបានចូលរួម ។ ខ្ញុំក៏ពេញចិត្តនូវការបង្រៀនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំគិតថាការរៀនសូត្រអំពីប្រវត្តិសាស្ត្រខ្មែរនិងរបបកម្ពុជាប្រជាធិបតេយ្យ គឺពិតជាសំខាន់ណាស់សម្រាប់កូនខ្មែរគ្រប់រូបឲ្យបានយល់ដឹង និងជាប្រយោជន៍ចំពោះមុនវិជ្ជាប្រវត្តិសាស្ត្រខាងមុខ ។ ដោយសារខ្ញុំយល់ពីសារសំខាន់ ខ្ញុំនឹងចែករំលែកពីការយល់ដឹងពីរបបខ្មែរក្រហមនៅថ្ងៃនេះទៅអ្នកដទៃ និងពិភពលោកឲ្យបានដឹងថាកម្ពុជាជាប្រទេសមួយដែលបានរងគ្រោះនូវរបបប្រល័យពូជសាសន៍ ។ លើសពីនេះ ខ្ញុំនឹងចូលរួមជួយក្នុងការផ្សះផ្សាសង្គម ដោយមិនរើសអើងបងប្អូន សាច់ញាត្តិកម្មាភិបាលខ្មែរក្រហមនោះទេ ព្រោះគាត់ក៏អាចជាជនរងគ្រោះមួយដែរ ។ ចំណាប់អារម្មណ៍យុវតី ចំរើន បញ្ញា អាយុ១៨ឆ្នាំ និយាយថា មុនពេលចូលរួម ខ្ញុំមានអារម្មណ៍ថាឆ្ងល់ នឹងចង់ដឹងថាអ្វីទៅជាខ្មែរក្រហម? ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ខ្មែរដូចគ្នា? ហើយពួកគេធ្វើដើម្បីប្រយោជន៍អ្វី? សំណួរទាំងនេះ ខ្ញុំតែងតែសួរទៅយាយរបស់ខ្ញុំ ។ យាយគាត់ឆ្លើយមកវិញថា ម្នាក់ៗគ្មានសិទ្ធិសេរីភាព ត្រូវបង្ខំឲ្យធ្វើការធ្ងន់ ការរស់នៅដោយភាពភ័យខ្លាចបំផុត ដឹងតែធ្វើការ មិនដែលចេះគិតនោះទេ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ ។ បញ្ញា បន្ថែមទៀតថា ក្រោយពេលចូលរួមវេទិកាថ្នាក់រៀន ខ្ញុំបានស្រាយចម្ងល់ជាច្រើនរបស់ខ្ញុំ ។ ខ្ញុំអាចយកទៅប្រាប់យាយរបស់ខ្ញុំ ពីមូលហេតុដែលកើតឡើងចំពោះគាត់ ព្រមទាំងជនរងគ្រោះឯទៀត ជាពិសេសគឺប្អូនៗរបស់ខ្ញុំដែលមិនបានចូលរួមក្នុងថ្ងៃនេះ ។

មឿន វិសាលធាន អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២ បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះ វេទិកាថ្នាក់រៀនថាៈ ខ្ញុំមានភាពសប្បាយរីករាយណាស់ ដែលបានចូលរួមស្ដាប់ទាក់ទងទៅនឹងសារសំខាន់នៃការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ខ្ញុំធ្លាប់បានសាកសួរម៉ាក់ ព្រមទាំងលោកយាយរបស់ខ្ញុំអំពីស្ថានភាពរស់នៅក្នុងរបបខ្មែរក្រហម ។ ក្នុងរបបខ្មែរក្រហមគេធ្វើទារុណកម្មសព្វបែបយ៉ាងគ្មានត្រាប្រណីឡើយ បាយក៏ញុំាមិនគ្រប់គ្រាន់ ។ ចំណែកយាយរបស់ខ្ញុំ ដោយសារតែមានជំនាញចម្អិនអាហារឆ្ងាញ់ ទើបប្រធានកងឲ្យធ្វើអាហារសម្រាប់ខ្លួនផ្ទាល់ ជាហេតុធ្វើឲ្យគាត់បានរស់នៅស្រួល និងហូបបានគ្រប់គ្រាន់ ។ ម្យ៉ាងទៀត មកពីប្រធានកងរបស់គាត់ជាមនុស្សចិត្តល្អ មិនដែលរាយការណ៍ពីកំហុសរបស់គាត់ និងសមាជិកគ្រួសារគាត់ទៅសហករណ៍ឡើយ ។

ជាចុងក្រោយ ទោះក្រុមគ្រួសាររបស់ខ្ញុំមិនដែលជួបការពិបាកនៅក្នុងសម័យនោះក៏ពិតមែន តែខ្ញុំត្រូវស្វែងយល់បន្ថែមទៀតពីសម័យខ្មែរក្រហម ។

**មីន សាណាស់**

# ដំណឹងស្វែងរកគ្រួសារដែលបាត់ខ្លួន

ខ្ញុំបាទឈ្មោះ គ្រីស្ទីន ឡៅ ។ ខ្ញុំសូមប្រកាសរកមីងរបស់ខ្ញុំដែលមានឈ្មោះ សុខ អៀងលីម ឬអាចហៅឈ្មោះម្យ៉ាងទៀតថា មួយ ស៊ុយ ដែលគិតមកដល់បច្ចុប្បន្នគាត់មានអាយុ ៧៧ឆ្នាំ និង ពូរបស់ខ្ញុំឈ្មោះ វីយ៉ាន ចាន់គ្រាន រួមជាមួយនឹងកូនរបស់គាត់ដែលមានឈ្មោះដូចខាងក្រោម ៖


រូបរាប់ពីឆ្វេង ៖ ស៊ូ ហ៊ុន (សព្វថ្ងៃរស់នៅអាមេរិក), ប៉ែន បេនកៀង និង ប៉ែន បេនណាំ

ទី១) ស៊ូ ហ៊ុន ឥឡូវមានអាយុប្រហែល ៥៤ឆ្នាំ

ទី២) ប៉ែន បេនកៀង ឥឡូវមានអាយុប្រហែល ៥២ឆ្នាំ

ទី៣) ប៉ែន បេនណាំ ឥឡូវមានអាយុប្រហែល ៤៨ឆ្នាំ

សូមបញ្ជាក់ថាក្នុងចំណោមក្មេងៗទាំងបីនាក់នេះ មានក្មេងស្រីម្នាក់ (ស៊ូ ហ៊ុន) ដែលបច្ចុប្បន្នរស់នៅប្រទេសអាមេរិក ។ ចំណែកអ្នកផ្សេងទៀត ខ្ញុំមិនដឹងថានៅរស់ ឬយ៉ាងណាទេ ហើយក៏មិនមាននរណាម្នាក់ធ្លាប់បានឃើញ និងទទួលដំណឹងពីពួកគាត់ដែរ ។ ខ្ញុំគ្រាន់តែដឹងថា ក្រោយឆ្នាំ១៩៧៩ មានសាច់ញាតិរបស់ខ្ញុំបានវិលត្រឡប់មកផ្ទះមីងពូរបស់ខ្ញុំដែរ ប៉ុន្តែផ្ទះនោះមិនមានមនុស្សរស់នៅទេ ។

ខ្ញុំមិនមានព័ត៌មានច្រើនទេទាក់ទងនឹងមីងពូរបស់ខ្ញុំ ហើយវាពិតជាពិបាកណាស់សម្រាប់គ្រួសាររបស់ខ្ញុំនៅពេលដែលនិយាយពីហេតុការណ៍បែកបាក់ដែលបានកើតឡើង ។ អ្នកដែលខ្ញុំបានសួរទាំងអស់ មិនចង់រំឮកឬចងចាំពីរឿងទាំងនេះទេ ។

ខ្ញុំបានស្វែងរកតាមរយៈការពិនិត្យ និងផ្ទៀងផ្ទាត់រូបថតគ្រួសារមីងរបស់ខ្ញុំដែលថតនៅក្នុងអំឡុងពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៣ ដែលផ្តល់ដោយមិត្តភក្តិរបស់គាត់ដែលនៅរស់ ជាមួយនឹងរូបថតជាច្រើនដែលមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា តែខ្ញុំមិនបានប្រទះឃើញរូប មីង ពូ និងកូនៗរបស់គាត់ទេ ។

មុនរបបខ្មែរក្រហម ពូរបស់ខ្ញុំជាម្ចាស់ក្រុមហ៊ុន ម៉េវ្យាមី នំបញ្ចុក និង គុយទាវ ដែលមានឈ្មោះ វ៉េង លី នៅមុំផ្សារអូរឫស្សី ។ ក្រុមគ្រួសារធំរបស់ខ្ញុំបានបែកបាក់គ្នានៅពេលខ្មែរក្រហមចូលមកភ្នំពេញ ។ សមាជិកគ្រួសាររបស់ខ្ញុំជាច្រើនបានភៀសទៅប្រទេសវៀតណាម ប៉ុន្តែអ្នកទាំងនោះបានធ្វើដំណើរបែកគ្នាទៅតាមផ្លូវផ្សេងៗ ។ ព័ត៌មានដែលខ្ញុំបានដឹងចុងក្រោយ គឺក្រុមគ្រួសារខ្ញុំចេញទៅប្រទេសវៀតណាម បន្ទាប់មកទើបភៀសខ្លួនទៅប្រទេសថៃ ។


រូបរាប់ពីឆ្វេង ៖ វីយ៉ាន ចាន់គ្រាន និង សុខ អៀងលីម ហៅ មួយ ស៊ុយ

ប្រសិនបើបងប្អូនណាបានទទួលដំណឹង ឬស្គាល់ឈ្មោះដូចបានរៀបរាប់ខាងលើ សូមទាក់ទងខ្ញុំបានតាមរយៈអ៊ីម៉ែល ៖ nycristinelao@gmail.com ឬទូរសព្ទ ៖ 1-631-372-6403 ផ្លូវលេខ ៖ 6909 Woodside Avenue ផ្ទះលេខ ៖ Woodside NY 11377, USA សូមអរគុណ។

**គ្រីស្ទីន ឡៅ**

# «សារាណីយ»

***(តពីលេខមុន)***

*នៅឆ្នាំ១៩៧៧ អង្គការចាត់ឲ្យក្មេងៗដូចពួកខ្ញុំ និងប្រជាជនដទៃទៀតឲ្យទៅទប់ទឹកទន្លេ ។ អ្នកស្រុកនាំគ្នាខ្សឹបខ្សៀវចំអកថា គ្មានម៉ែឪអាណា ទប់ទឹកទន្លេជាប់ទេ ។*

*ចំណែកអ៊ំខ្ញុំ ត្រូវនៅមើលក្មេងៗ ។ នៅពេលនោះគាត់មានជំងឺហើម រាក និងដំបៅ ជើង ។ ដំបៅនៅស្មងជើងរបស់គាត់រីកដូចផ្កាខាត់ណា ។ ខ្ញុំតែងឃើញគាត់យកដង្កៀបដកសាច់ជ្រួញប្រាញនោះ ។ នឹកឃើញកាលណា ខ្ញុំព្រឺខ្លួន ។ មិនដឹងគាត់ចេះរបៀបព្យាបាលពីណា ។ គាត់តែងតែកម្ទេចផ្លែ "ឡាក់" លាយប្រេងដូងជាមួយគីង្គក់យកមករុំ ។ យូរណាស់ ទើបដំបៅនោះសះ ។ មានម្តងនោះ អង្គការដើរឆែកឆេរតាមផ្ទះ ប្រមូលសម្ភារដាក់ឃ្លាំង សហករណ៍ ។ គេឆែកញឹកញាប់ណាស់ ។ នៅផ្ទះខ្ញុំ អង្គការឆែកបានកំសៀវទឹកមួយដែលជាវត្ថុចុងក្រោយ ។ អ៊ំខ្ញុំទៅប្រទាញយកមកវិញ ហើយត្អូញថា កូនទៅបែកអស់ហើយ គ្មាននរណាបម្រើគាត់ពេលឈឺ ។ កំសៀវនេះ ខ្ញុំទុកគ្រាន់ដងទឹកផឹក ។ គេក៏ឲ្យមកវិញ ។ កំសៀវនោះនៅដល់សព្វថ្ងៃ ។ តាមពិតក្រៅពីដាំទឹកកំសៀវនោះប្រើជាឆ្នាំងបាយ ជាខ្ទះលីងពោត ។ ជាញឹកញយ ខ្ញុំតែងឃើញគាត់រើសធ្យូងពិសា ។ ពេលសួរគាត់ គាត់ប្រាប់ថា គ្រូពេទ្យចាស់ម្នាក់ឈ្មោះគាត បានប្រាប់ថា បើចង់រស់ ត្រូវដាំដើមគ ត្រូវចេះស៊ីផេះ ស៊ីធ្យូង ។ ក្រោយមក គាត់កើតជំងឺលឿង ដោយសារតែចូលចិត្តពិសាក្រញូងបារី ។ បារីគាត់ធំៗ ក្មេងប្រុសម្នាក់ហៅគាត់ថា យាយព្រះអាទិត្យ ។ គាត់តែងឲ្យពួកខ្ញុំដឹកមាក់ឃ្លៀលាយខ្ទិះដូង ឬក្បាលខ្លាយលាយខ្ទិះដូង ។ ថ្នាំនោះពិបាកលេបណាស់ តែខ្លាចរំពាត់ចេះតែទ្រាំលេបទៅ ។ ថ្នាំនេះ គឺដើម្បីទម្លាក់ព្រូន គេនញា អៀន ។ បើថ្នាំព្យាបាលជំងឺលឿងវិញ គាត់បានយកអាចម៍ដែក រើសចេញពីឡ ដុះដែកមកត្រាំទឹកដូងឲ្យផឹក ។*

*ខ្ញុំសង្កេតឃើញថា ឲ្យតែដល់រដូវវស្សាបបរកាន់តែរាវទៅៗ ជួនកាលនៅការដ្ឋាន គ្មានទាំងអង្ករបបរផង ។ មានល្ងាចមួយពេលខ្ញុំត្រឡប់ពីធ្វើការទៅហូបបបរនៅការដ្ឋានស្រាប់តែគេចែកពោតឲ្យម្នាក់មួយផ្លែ ផ្លែចេកមួយ ជំនួសបបរពេលល្ងាច ។ ខ្ញុំបានហូបពោត ហើយកាន់ផ្លែចេកមកផ្ទះ តែដោយឃើញក្មេងម្នាក់ឈរយំ ព្រោះគ្មានអីហូប ខ្ញុំក៏ឲ្យចេកនោះទៅគេ ។ ពេលព្រលប់បន្តិចសេចក្តីស្រេកឃ្លានមកបៀតបៀនខ្ញុំ ។ ខ្ញុំពុំដឹងខ្លួនឯងថាវា ធ្វើទុក្ខបែបណាទេ គ្រាន់តែចាំថា ពេលនោះអ៊ំខ្ញុំបន្ទោសថា អើអ្ហែងចិត្តល្អសមតែដាច់ពោះស្លាប់ទៅ ។ ទោះជាគាត់ខឹង ក៏គាត់នៅតែខំលៃរបបគាត់ឲ្យខ្ញុំ ។ ជារៀងរាល់ថ្ងៃពិសេសពេលល្ងាច អ៊ំ និងម៉ែ តែងសម្រិតយកកាកបបរទុកឲ្យខ្ញុំ និងប្អូន ឯពួកគាត់លាយត្រកួន ជួនកាលក៏លបលួចដាំបបរបន្ថែម ពេលណាលួចដូរអង្ករគេបាន ។ ក្នុងរបបខ្មែរក្រហម ក្រុមដែលធ្វើការខាងកិនអង្ករ ស្រិតអង្ករ តែងលួចលាក់អង្ករដាក់តាមថ្នក់ចង្កេះ ។ ម៉ែតែងលួចទាក់ទងក្រុមនោះ ។ ជួនកាលបានមកពីបងស្រីខ្ញុំលួចបបូត ។ បើមិនមានបន្ថែមខាងក្រៅទេ គ្រួសាររបស់ខ្ញុំច្បាស់ជាដាច់ពោះស្លាប់ដូចគេដែរហើយ ។*

*ការហូបចុកមិនគ្រប់គ្រាន់ ហើយការងារក៏មមាញឹក ព្រោះថានៅរដូវវស្សាជារដូវធ្វើស្រែ ។ នៅឆ្នាំ១៩៧៧ ឬ៧៨ ទឹកទន្លេឡើងខ្លាំង ហេតុនេះ ត្រូវធ្វើការទាំងយប់ទាំងថ្ងៃ គឺលើកទំនប់ទប់ទឹកទន្លេ ។ អ្នកធ្វើស្រែចាត់ទុកថា គ្រាន់បើខ្លះតែបើកងពិសេស ដែលអង្គការប្រើឲ្យកាប់ក្រចៅវិញ រឹតតែក្តៅគគុកទៀត កងនេះគេយកតែបុរសៗ ។ ខ្ញុំឮគេនិយាយថា អ្នកទៅធ្វើការនៅទីនោះ ស្លាប់ច្រើនដោយលង់ទឹក ។*

*បងប្រុសជីដូនមួយខ្ញុំម្នាក់ក៏បានស្លាប់ដោយពុំដឹងទីតាំងពិតប្រាកដដែរ ។ ពេលដឹងថាកូនឈឺ អ៊ំស្រីខ្ញុំ (ពុំមែនអ៊ំដែលខ្ញុំនៅជាមួយទេ ។ អ៊ំដែលខ្ញុំនៅជាមួយ គាត់គ្មានកូនទេ) បានសុំច្បាប់ប្រធានភូមិទៅមើលកូន ។ គាត់ខំលួចលាក់ស្ងោរមាន់មួយយកទៅផ្ញើ ពេលទៅដល់កន្លែងធ្វើការ សួរមេកង ហើយមេកងប្រាប់ថា*

"បញ្ជូនមកពេទ្យព-២" (បច្ចុប្បន្នជាពេទ្យយោធភូមិភាគ៥) ។ ពេលមកដល់ គាត់សួរអ្នកគ្រប់គ្រងពេទ្យ គេថាពុំឃើញឈ្មោះហ្នឹងទេ ។ គាត់ឈ្មោះ "ដែង ឡឿម" ។

## ការជម្លៀសក្នុងឆ្នាំ១៩៧៧-១៩៧៨

ខ្ញុំកត់សម្គាល់ឃើញថា ការជម្លៀសនេះ ចែកជាពីរផ្នែក ។ ដំបូងអង្គការជម្លៀសអ្នកថ្មី គឺអ្នកដែលមកពីក្រុងភ្នំពេញ និងតាមទីប្រជុំជន ។ ចំណែកពួកខ្ញុំ ត្រូវជម្លៀសនៅក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៨ ព្រោះពេលទៅដល់កន្លែងមិនយូរប៉ុន្មាន គេចាប់ផ្ដើមប្រូតស្រូវ ។ មូលហេតុនៃការជម្លៀសនេះ ព្រោះតែនៅក្នុងឆ្នាំ១៩៧៨ នោះ ទឹកទន្លេធំណាស់ ។ ចាស់ៗថា ជាឆ្នាំរោង ។ ស្រូវដំណាំទាំងឡាយត្រូវលិចទឹកអស់ ទោះបីអង្គការប្រើឲ្យទប់ ទំនប់ទាំងយប់ទាំងថ្ងៃយ៉ាងណាក៏ដោយ ។ ឆ្នាំនោះសម្បូរត្រីណាស់ ជាពិសេសកំពឹស ។ អ្នកភូមិខ្ញុំរស់នៅដោយសារកំពឹស និងត្រកួន ។ ប៉ុន្តែកំពឹសនេះ ត្រូវលួចដង ។ ម្ដាយខ្ញុំពុំដឹងគាត់លួចដងតាំងពីម៉ោងប៉ុន្មានទេ តែពេលខ្ញុំភ្ញាក់ពីដេក គឺមានកំពឹសហូបតែម្ដង ។ មានម្ដងនោះ ខ្ញុំមិនដឹងខឹងម្ដាយខ្ញុំរឿងអ្វីទេ ខ្ញុំដើរស្រែកឡូឡាអំពីរឿងម្ដាយលួចដងកំពឹស និងលួចចម្អិនអាហារផ្សេងៗ ។ អ៊ំខ្ញុំស្ទុះមកលួងលោមខ្ញុំ ។ តែរឿងនេះដូចជាខ្ញុំប្រណែននឹងប្អូនស្រីខ្ញុំបានរឿងបានហូបតិចច្រើនជាងគ្នា ។ ខ្ញុំក៏ស្ងាត់មាត់ អ៊ំខ្ញុំក៏ចាប់ខ្ញុំវាយ ហើយប្រាប់ថា រឿងនេះអាចធ្វើឲ្យខ្ញុំស្លាប់ ។

ឥឡូវនេះ ខ្ញុំសូមនិយាយអំពីការជម្លៀសវិញម្ដង ។ កាលណោះ អង្គការផ្ដើមជម្លៀសអ្នកថ្មីមុន ប៉ុន្តែមិនដឹងថាជម្លៀសទៅទីណាទេ ។ ចំណែកអ្នកចាស់ ជម្លៀសចេញស្ទើរតែទាំងអស់ អង្គការទុកតែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះសម្រាប់រុះរើផ្ទះ ។ កាលមុនអង្គការរុះរើតែផ្ទះស័ក្តិសី ប៉ុន្តែមកដល់ឆ្នាំ១៩៧៨នេះ ក៏បញ្ជាឲ្យរុះរើទាំងផ្ទះក្បឿងទៀត ។ គ្រួសារខ្ញុំត្រូវទៅទាំងអស់ លើកលែងតែបងស្រីបន្ទាប់ខ្ញុំ ត្រូវបងជីដូនមួយសុំកម្មាភិបាលខ្មែរក្រហមទុកនៅជាមួយគាត់ ដើម្បីមើលកូនគាត់ ។ គ្រួសារខ្ញុំដើរបានបន្តិច ក៏មានឡានទ្រុងធំមួយមកដឹក ។ ខ្ញុំអត់ចង់ជិះឡានទេ ព្រោះខ្លាចពុលតែពុំដឹងធ្វើម៉េច ។ ខ្ញុំក្អួតជាប់តាមផ្លូវ ។ ដំបូង អង្គការយកទៅដាក់ទ្រុងទា ។ អង្គការស្ងោរស្ពៃសដាក់ពងទា ជាម្ហូបដែលខ្ញុំពុំធ្លាប់ហូបទេ ។ នៅទីនោះ អង្គការឲ្យហូបបាយ ។ នៅទីនោះបានប៉ុន្មានថ្ងៃ អង្គការចាប់ផ្ដើមបំបែកគ្រួសារ ដែលនៅរោងទាទៅកន្លែងផ្សេងៗ ។ គ្រួសារខ្ញុំឲ្យទៅនៅកុដិលោកមុខវត្តកៀនកេស ។ កុដិ នោះគ្មានបន្ទប់ទេ ហើយក៏គ្មានជញ្ជាំងមុខដែរ ។ អង្គការឲ្យនៅប្រហែលជាបីបួនគ្រួសារ ។ នៅម្ខាងផ្លូវ គឺជាបង្គន់ដែលគេប្រើត្រងទុកសម្រាប់ធ្វើជី ។ ពេលណាគេមកយកជីម្ដងៗ មានក្លិនស្អុយពិបាកទ្រាំណាស់ ។ នៅខាងក្រោយកុដិខ្ញុំ គឺជាកន្លែងសង្គមកិច្ចផលិតថ្នាំគ្រាប់ដែលចាស់ៗហៅថា ថ្នាំអាចម៍ទន្សាយ ។ ខ្ញុំនៅក្នុងភូមិជាមួយអ៊ំស្រី និងបងជីដូនមួយ ។ ឯប្អូនស្រី បងប្រុស បងស្រីទី២ ទៅនៅវាលស្រែដើម្បីប្រូតស្រូវ ។ ការរស់នៅទីនោះ ពុំធូន់ដូចនៅស្រុកកំណើតខ្ញុំទេ ។ អ៊ំខ្ញុំ អង្គការចាត់ឲ្យក្រងស្បូវ ត្បាញកន្ទេលជាមួយបងស្រីជីដូនមួយខ្ញុំ ។ ខ្ញុំត្រូវអង្គការចាត់ឲ្យទៅធ្វើការនៅការដ្ឋាន និងរៀនផង ។ ពេលព្រឹក ខ្ញុំត្រូវទៅ រើសកួរស្រូវ ហើយពេលថ្ងៃមករៀន ។ ខ្ញុំចាំបានថា ការរៀននោះមានលក្ខណៈប្រសើរជាងនៅស្រុកខ្ញុំ តែរៀននេះ គឺរៀននៅក្រោមដើមឈើ គ្មានក្ដារខ្មៀន ខ្មៅដៃ សៀវភៅទេ គឺរៀនទន្ទេញនឹងមាត់ ។ ខ្ញុំរៀនជាមួយក្មេងៗ ដែលនៅភូមិនោះ ។

ថ្ងៃមួយ ពេលត្រឡប់មកពីរើសកួរស្រូវវិញ អំឡុងពេលបាយថ្ងៃត្រង់ ខ្ញុំឃើញយោធា ខ្មែរក្រហមដើរមួយខ្សែតាមផ្លូវធំ ។ មានយោធាម្នាក់សួរថា "តើផ្លូវណាទៅបរវេល?" អ្នកស្រុកយើងឆ្លើយថា "ទៅតាមផ្លូវហ្នឹងហើយ ឆ្ពោះទៅលិចឲ្យត្រង់ទៅ" ។ យោធាទាំងនោះ ខ្លះពិការជើងម្ខាង ខ្លះត្រូវសែង ។ មកដល់ផ្ទះទើបខ្ញុំដឹងថា យោធាទាំងនោះ ជាយោធាខ្មែរក្រហមបាក់ទ័ព ។ យោធាទាំងនោះ ត្រូវជិះរថភ្លើងទៅដល់ព្រំដែន តែពុំដឹងមកពីមូលហេតុអ្វីទើបនាំគ្នាចុះនៅត្រង់ថ្មគោល ហើយដើរទៅខាងលិចវិញ ។ ក្រោយពីនោះបានមួយអាទិត្យ ក៏ឮស្នូរកាំភ្លើងនៃការប្រយុទ្ធគ្នានៅខាងថ្មគោល ហើយពេលនោះ ខ្ញុំនៅតែម្នាក់ឯង ។ អ៊ំស្រីរវល់ជូនក្មួយជីដូនមួយខ្ញុំទៅការដ្ឋានវិញ ។ ខ្ញុំភ័យណាស់ អត់រត់ពួនទេ គឺគិតតែប្រមូលភួយមុង ។ ពេលអ៊ំស្រីមកដល់ យើងនាំគ្នាទៅពួននៅជិតឡផលិតថ្នាំ ។ ក្រោយស្ងប់សំឡេងគ្រាប់ ម្ដាយខ្ញុំបានមកយកយើងទៅជាមួយគាត់នៅវាលស្រែដែលជាកន្លែងគាត់ប្រូត ។ នៅទីនោះបានពីរបីថ្ងៃ គ្រួសាររបស់ខ្ញុំក៏ដូចជាគ្រួសារដទៃទៀត បាននាំគ្នាធ្វើដំណើរទៅស្រុកកំណើតវិញ ។ តាមផ្លូវធ្វើដំណើរអ្វីដែលយើង

ភ័យខ្លាចនោះ គឺខ្លាចខ្មែរក្រហមមកកៀរទៅជាមួយ ។ យើងបានធ្វើដំណើរមកដល់ភូមិប្រោយសំរោង និងស្នាក់នៅទីនោះបានមួយអាទិត្យ រួចក៏បន្តដំណើរទៅស្រុកកំណើតទៀត ។

ពេលដែលមានការប្រយុទ្ធគ្នារវាងកងទ័ពវៀតណាម និងខ្មែរក្រហម ប្រជាជនជ្រួលច្របល់មិនដឹងទៅណានោះទេ ហើយទន្ទឹមនឹងនោះក៏មានការប្រកាសថា «បើចង់រស់ត្រូវទៅកើត» ។ ព្រោះពាក្យនេះ ទើបយើងនាំគ្នាត្រឡប់ក្រោយ ។ ពេលនោះ ខ្មែរក្រហមតែងតែឆ្មៀតកៀរប្រជាជន ។ អំឡុងពេលនោះ ខ្ញុំ និងគ្រួសារស្នាក់នៅវាលទ្រា ។ នៅទីនោះបានប៉ុន្មានថ្ងៃក៏ឮដំណឹងថា ខ្មែរក្រហមនឹងវាយចូលមក ហេតុនេះគ្រួសាររបស់ខ្ញុំបានរៀប ចំចេញដំណើរបន្តទៀត ។

នៅតាមផ្លូវធ្វើដំណើរក៏មានការឆែកឆេរដែរ ក្រែងមានខ្មែរក្រហមបង្កប់ចូលក្រុង ។ គេយកដំពុះទង់ចាក់បាវស្រូវក្រែងយើងមានលាក់អាវុធ ។ មកដល់ភូមិ យើងឃើញភូមិមានសភាពស្ងប់ស្ងាត់ ពុំទាន់មានមនុស្សមកច្រើនទេ ។ ម្ដាយខ្ញុំពុំហ៊ាននាំគ្នាចូលមកស្នាក់នៅផ្ទះយើងទេ ព្រោះផ្ទះខ្ញុំត្រូវចូលតាមដងអូរប្រហែល ៥០០ម៉ែត្រពីផ្លូវធំ ។ ពេលថ្ងៃ គាត់នាំខ្ញុំ និងប្អូនមកមើលផ្ទះ ។ ខ្ញុំភ័យណាស់ ។ ផ្ទះខ្ញុំគ្មានសល់អ្វីទេ សល់តែកញ្ចក់រូបថតប្អូនប្រាំ និងអក្សរវៃខ្សែមួយ ។

ក្រោយពេលរបបខ្មែរក្រហមដួលរលំ ខ្ញុំឃើញមានការសម្លាប់សងសឹកគ្នាជាច្រើន បានកើតឡើង ហើយការយាមកាមក៏តឹងតែងដែរ ។ ពេលយប់ ប្រជាជនក្នុងភូមិមកផ្ដុំគ្នាក្បែរថ្នល់ធំរហូតដល់ចូលឆ្នាំខ្មែររួច ទើបយើងទាំងអស់គ្នា ហ៊ានសម្រាកនៅលើផ្ទះ ។ ពេលនោះដែរ អ្នកដែលធ្លាប់ធ្វើជាមេកង ក៏បានចាកចេញទៅព្រំដែនកម្ពុជា-ថៃ ។ ចំណែកបងធម៌របស់ខ្ញុំ ក៏បានលាខ្ញុំទៅដែរ ។ ពេលរដូវវស្សាមកដល់ ភាពអត់ឃ្លានក៏កើតមានឡើង ព្រោះស្បៀងដែលយើងមាន ត្រូវបានប្រើប្រាស់អស់ហើយ ។ ក្រោយរំដោះភ្លាមៗ ម្នាក់ៗគិតតែពីហូប ដើម្បីបំបាត់សេចក្ដីស្រេចឃ្លានដែលបានកប់ទុកអស់រយៈពេលជាងបីឆ្នាំមកហើយ ។ នៅក្នុងកាលៈទេសៈនោះដែរ យើងបានប្រើប្រាស់អង្ករជំនួសឲ្យក្រដាស់ប្រាក់ ដើម្បីទិញដូរសម្ភារផ្សេងៗ ។ គាប់ជួននៅក្នុងគ្រានោះដែរ ជំងឺកញ្ជ្រិលបានរាតត្បាតយ៉ាងខ្លាំង តែសំណាងដែរ ដែលខ្ញុំនិងប្អូនរបស់ខ្ញុំ មិនបានកើតជំងឺនេះនឹងគេ ។ ក្នុងគ្រួសារណាដែលមានសមាជិកកើតជំងឺនេះ ត្រូវចាយវាយអង្ករច្រើន ដើម្បីទិញថ្នាំសង្កូវ ខ្លះក៏ត្រូវស្លាប់ ។ សភាពអត់ឃ្លាននៅពេលនោះ បានជំរុញឲ្យអ្នកភូមិខ្ញុំច្រើនគ្រួសារ ចេញទៅនៅជំរំតាមជាយដែន ។ មួយចំនួនទៀត ដោយខ្លាចប្រវត្តិសាស្ត្រលង គឺភ័យខ្លាច យួនអារកដូចសម័យកាលខត្តុង្គ ។ អ៊ំខ្ញុំតែងដាស់តឿនថា «ស្រូវស្លួចកុំឲ្យដាច់ស្បៀងជិតអស់ក៏នាំគ្នាហូបបបរ» កាលនោះ មានគេចែកស្បៀងខ្លះៗដែរ ។

ចុងឆ្នាំ១៩៧៩ ខ្ញុំក៏បានចូលរៀននៅសាលាឆាន់វត្តស្វាយជ្រំដែលអ្នកស្រុកនាំគ្នាហៅថា សាលាតាជូជក់ មានពីរថ្នាក់ ប្អូនខ្ញុំរៀននៅថ្នាក់ផ្សេងមួយទៀត ។ គ្រូរបស់ខ្ញុំឈ្មោះ «ឡឹប ម៉ាន» ជាខ្មែរអ៊ីស្លាម រីឯគ្រូរបស់ប្អូនស្រីខ្ញុំមានឈ្មោះ «ឆាយ» ។ ពួកខ្ញុំអង្គុយរៀននៅលើសាបស៊ីម៉ងត៍ ហើយយកឥដ្ឋមកបន្ទុបទ្រាប់សៀវភៅសរសេរ ។ ឃ្លាំងចុងភៅវត្ត ត្រូវបានយកធ្វើជាទីកន្លែងទីស្នាក់ការឃុំ ។ នៅពេលចូលមកដល់ភ្លាម អ្នកស្រុកបានសហការគ្នាធ្វើបុណ្យឲ្យសាច់ញាតិដែលបានស្លាប់ក្នុងជំនាន់នោះ ។ អ្នកដែលបានស្គាល់រណ្ដៅសពសាច់ញាតិ ក៏បានគាស់យកអដ្ឋិធាតុទៅធ្វើបុណ្យទៅ កាលនោះវត្តក្នុងភូមិខ្ញុំក៏ បានធ្វើបុណ្យធំដែរ ។ ដំបូងក្រុមគ្រួសាររបស់ខ្ញុំធ្វើទេ ព្រោះមានអ៊ំប្រុស បងជីដូនមួយ ក្មួយជីដូនមួយ និងតាមាស្លាប់ ។ ក្រោយមក អ្នកផ្សេងទៀតចេះតែមកសុំចូលរួម ទើបបាន ក្លាយទៅជាបុណ្យធំនៅក្នុងវត្តទៅ ។

## អាហារដើម្បីរស់

ពាក្យចាស់បុរាណលោកតែងពោលថា «ព្រោះចំណី ត្រូវក្ដីច្រើនក្ដាត់» ។ ជាការពិតណាស់ ព្រោះតែសេចក្ដីស្រេចឃ្លានមនុស្សហ៊ានធ្វើអ្វីៗគ្រប់បែបយ៉ាង មានលួចជាដើម ។ ទោះបីដឹងថា ការលួចត្រូវមានទោសក៏ដោយ ។ តែនៅក្នុងរបបខ្មែរក្រហមមនុស្សនៅតែលួច ។ អ្នកខ្លះស្លាប់ខ្លួន ព្រោះលួចពោតមួយផ្លែដំឡូងមួយមើម ក្ដាមមួយ ប្លុកផ្កែបមួយ ។ ខ្លះត្រូវពុលចំណីដែលខ្លួនមិនដែលហូប ។ អ៊ំរបស់ខ្ញុំតែងប្រាប់ថា អ្នកជម្លៀសស្លាប់ច្រើនព្រោះតែអ្នកខ្លះធ្លាប់ហូបឆ្ងាញ់ៗ តែដល់ពេលអត់ឃ្លាន ត្រូវរងទុក្ខមុនគេ ។ អ្នកខ្លះទៀត ធ្លាប់តែរស់នៅក្នុងក្រុង គ្មាមិនដឹងថា របស់ណាហូបទៅពុល ហើយរបស់ណាហូបមិនកើតនោះទេ ។ មានអ្នក

ជម្ងឺសខ្លះពុលស្លាប់ដោយសារហូបពងគីង្គក់ ព្រោះមិនដឹងថាពុល ។ មានអ្នកខ្លះទៀត ពុលមើមក្តួច ខ្លះបេះផ្លែត្រដិតហូបដោយស្មានតែផ្លែជីឡូង ។ អ៊ីខ្ញុំបានបន្ថែមទៀតថា ការរស់នៅរបស់អ្នកក្រុងមានអនាម័យល្អ តែដល់ពេលរស់នៅក្នុងរបបខ្មែរក្រហម ពួកគាត់ងាយនឹងកើតជំងឺផ្សេងៗ ជាពិសេសជំងឺរាករូស ។ មានកូនអ្នកជម្ងឺសពីរនាក់ដែលធ្លាប់លេងជាមួយនឹងខ្ញុំកាលខ្ញុំនៅថ្នល់ធំក្រោយវត្ត បានពុលស្លាប់ ព្រោះអ្នកទាំងពីរបានរើសសម្បកជីឡូងពីក្នុងគុកសម្រាមមកហូប ។ តើមាននរណាអាចទ្រាំនឹងសេចក្តីស្រេកឃ្លានបាន? អ្នកមិនធ្លាប់ដាច់អាហារ មិនធ្លាប់ជួបប្រទះគ្រោះទុរ្ភិក្ស មិនដឹងសេចក្តីស្រេកឃ្លានមានទំហំធំប៉ុណ្ណាទេ? វាធ្វើទុក្ខបែបណាទេ? ខ្ញុំឃើញរូបភាព ក្មេងៗនៅប្រទេសវ៉ាន់ដា ដែលខ្វះអាហារ ខ្វះទឹក ធ្វើឲ្យខ្ញុំនឹកឃើញដល់ជីវិតពួកយើងនៅក្នុងសម័យខ្មែរក្រហម ។ កូនរបស់អ៊ីស្រីម្នាក់ឈ្មោះ "ស៊ាន" នៅភូមិជាមួយខ្ញុំ មុនដាច់ខ្យល់ស្លាប់ បានស្រែកទាររកបាយ ហើយវារសំដៅទៅរកចង្ក្រានបាយ ។ អ៊ំប្រុសខ្ញុំ ព្រោះតែស្រេកឃ្លាន ដាច់ចិត្តលើកដៃសំពះអង្វរសុំអង្ករពីប្រធានការដ្ឋាន ហើយត្រូវប្រធានសហករណ៍ហៅមកកសាង ។ គាត់ឈឺចិត្តណាស់ ព្រោះស្រូវដែលគាត់ខំធ្វើត្រូវប្រមូលដាក់ឃ្លាំង គាត់គ្រាន់តែសុំមួយកំប៉ុងមកហូប គេមិនឲ្យ បើអ្នកកាន់ឃ្លាំងនោះមិនដែលស្គាល់គ្នាក៏ហើយចុះ តែជាអ្នកភូមិជាមួយគ្នា ម៉េចក៏ដាច់ចិត្តម៉្លេះ ។ ពេលគាត់ដើរមកដល់ផ្ទះក៏ងងឹតមុខ ហើយដួលស្លាប់ទៅ ។

សរុបមកឃើញថា ចំណីអាហារផ្តល់ទោសដល់មនុស្សច្រើនណាស់ ។ ខ្មែរក្រហម ប្រើវិធីបង្អត់អាហារនេះ ដើម្បីសម្លាប់ប្រជាជនដោយប្រយោល គឺធ្វើឲ្យមនុស្សមានកំហុស ហើយចាប់យកទៅធ្វើទោស ។ ខ្មែរក្រហមមិនធ្វើទោសពីបទស្រេកឃ្លានទេ តែធ្វើទោសមនុស្សពីបទមិនគោរពវិន័យរបស់អង្គការ ។

ការពោលខាងលើ ជាគតិឲ្យមនុស្សគ្រប់អាត្មាចេះស្វែងយល់ឲ្យបានទូលាយពីតំបន់នីមួយៗដែលអ្វីហូបបាន និងអ្វីហូបមិនបាន ដើម្បីងាយសម្របខ្លួន ។ ទោះបីយើងមានសុខសន្តិភាព តែពុំដឹងពេលណាយើងជួបគ្រោះអ្វីទេ ។ ដូចកាលសម័យខ្មែរក្រហម បើយើងចាំតែរបបដែលអង្គការផ្តល់ឲ្យ ពិតជាស្លាប់ បើយើងមិនចេះផ្សេងផ្សំអ្វីៗនៅជុំវិញខ្លួនទេនោះ ។ នៅក្នុងតំបន់ដែលខ្ញុំរស់នៅ អាហារដែលអាចទ្រទ្រង់ជីវិតបានគឺ ត្រកួន កណ្តុរ កំប្រុក ក្តិបចេក ក្តិបនទោង ក្តិបត្រឡាច សូម្បីតែស្បែកកណ្តុរក៏អាចហូបបានដែរ ។ ទាក់ទងរឿងស្បែកកណ្តុរនេះ ខ្ញុំនឹកឃើញដល់អ្នកភ្នំពេញម្នាក់ឈ្មោះ "យ៉ុង" ។ ក្នុងគ្រួសាររបស់គាត់ មានសមាជិកតែពីរនាក់ គឺគាត់និងម្តាយរបស់គាត់ ។ គាត់មានរាងស្គមខ្ពស់ គេថាគាត់ជាមនុស្សឆ្កួត ។ តែក្រោយថ្ងៃរំដោះ គេថាគាត់ជាវេជ្ជបណ្ឌិត ។ កាលជំនាន់ខ្មែរក្រហម គាត់ធ្វើពុតជាឆ្កួតទេ ដើម្បីបានរស់ជីវិត គាត់ត្រូវតែធ្វើពុតបែបនេះ ។ ពួកខ្ញុំតែងលេងជាមួយគាត់ដោយឲ្យគាត់ច្រៀង តែគាត់ថា បើឲ្យច្រៀងទាល់តែរកស្បែកកណ្តុរ ឬកណ្តុរឲ្យគាត់ ។ គាត់តែងច្រៀងថា "ហា! យើងស៊ុង ហ៊ិចៗ យើងកុំភ្លេចស៊ីស្បែកកណ្តុរ" ។ មានអ្នកខ្លះគេលេបកូនកណ្តុរដែលទើបនឹងកើត ហើយគេនិយាយទៀតថា កូនកណ្តុរនោះ ជួយឲ្យបាត់ឈឺចង្កេះ ។ ខ្ញុំធ្លាប់ហូបកណ្តុរឆាជាមួយផ្កាកំប្លោក កាលនោះឆ្ងាញ់ណាស់ ហើយបានហូបតែម្តង តាំងពីផ្ទះខ្ញុំនៅក្រោយវត្ត ព្រោះពេលនោះ ក្រុមគ្រួសាររបស់ខ្ញុំ បានលួចឆាធ្វើបុណ្យឲ្យជីតាម្នាក់ដែលត្រូវជាប្អូនជីតារបស់ខ្ញុំ ។ ប៉ុន្តែការលួចធ្វើបុណ្យនៅពេលនោះគ្មានលោកសង្ឃទេ មានតែតាអាចារ្យឈ្មោះ "តាស៊ាង" ដែលជាអ្នកធ្វើកិច្ចឲ្យ ។ កាលនោះនៅលួចធ្វើបុណ្យបាន ព្រោះនៅដើមឆ្នាំ ១៩៧៦ នៅមិនទាន់តឹងរឹងដូចពួកខាងនិរតីកាន់កាប់ទេ ។ ដល់ឆ្នាំ ១៩៧៧-៧៨ គ្រួសារខ្ញុំរស់ដោយសារត្រកួន ។ អ៊ំរបស់ខ្ញុំបាននាំខ្ញុំទៅបេះត្រកួននៅពេលសម្រាក ។ គាត់បេះច្រើនទុកសម្រាប់បីបួនថ្ងៃ ។ ពេលទៅបេះម្តងៗ ខ្ញុំភ័យណាស់ ខ្លាចឈ្លបចាប់បានយកទៅធ្វើបាប ព្រោះធ្លាប់បានឃើញគេវាយធ្វើបាបបណ្តើរនៅនឹងមុខ ។ អ៊ំតែងប្រាប់ថា "ភ័យអី យើងមិនលួចអង្គការទេ គ្រាន់តែបេះត្រកួន" ។ ត្រកួនយកមកហាន់រួចស្ងោរលាយជាមួយរបរយកមកពីការដ្ឋាន និងបង់អំបិលតិចៗ ។

អំបិលកាលនោះថ្លៃណាស់ ។ ពាក្យនេះ ធ្វើឲ្យខ្ញុំនឹកឃើញរឿងភាពយន្តមួយថា "អំបិលថ្លៃជាងមាស" ពិតដូច្នេះមែនក្នុងសម័យនោះ គឺមាសគ្មានតម្លៃទេ ព្រោះហូបមិនកើត ។ ម្តាយខ្ញុំ និងចាស់ៗមួយចំនួន មិនហ៊ានហៅអំបិលទេ គាត់ហៅថា "ពងកំពត" ឬ "ឆាក្រិប" តើនៅតំបន់ផ្សេងៗ មានធ្លាប់ឮពាក្យនេះទេ? ។ អំបិលពិបាករកដូរណាស់ ទាល់តែស្គាល់ជិតដិតនឹងចុងភៅធ្វើម្ហូបនៅការដ្ឋាន ។

នៅតំបន់លិចទឹក ក្រៅពីត្រកួន នៅមានដៃកំប្លោក ផ្កាកំប្លោក កំពឹងពួយ ព្រលឹត ជន្ទល់ភ្នំ រំចង់ ។ល ។ រំចង់គេអាចហូបមើមបាន ផ្លែព្រលឹត គេអាចយកធ្វើជាម្សៅកូរនំដូចម្សៅអង្ករ តែបន្លែទាំងនេះនៅចាញ់ត្រកួន ។ ត្រកួនងាយរក ហើយកែច្នៃបានច្រើនមុខ ។ ននោង ត្រឡាច ដែលគេធ្លាប់ហូបឆ្អិន ពេលនោះគេហូបឆៅ ។ គិតទៅសម័យខ្មែរក្រហម អ្វីក៏ឆ្ងាញ់ដែរ ។ ក្ដួយជីដូនមួយរបស់ខ្ញុំម្នាក់ធ្លាប់បានប្រាប់ថា «សាច់ថ្លែន សាច់បង្គួយ ឆ្ងាញ់ដូចសាច់មាន់អ៊ីចឹង» ។ ខ្ញុំមិនដែលហូបសត្វទាំងនោះទេ ។ នៅរដូវវស្សា ស្រុកខ្ញុំសម្បូរត្រី កំពឹស ។ ម្ដាយខ្ញុំប្រាប់ថា កំពឹសកម្របានឆ្អិនណាស់ គឺនាំគ្នាហូបឆៅពេលធ្វើការ ។ គ្រួសារខ្ញុំធ្លាប់ហូបត្រួយត្រឡុង ផ្លែត្រដិត ។ ផ្លែត្រដិតយកមកលីងដាក់លាយទឹកប្រហុក ដូចត្រប់ពុតញាង ។ ឲ្យតែបានបាយជាមួយអំបិលគឺឆ្ងាញ់ណាស់ ។ ជុំវិញផ្ទះខ្ញុំមានដាំដើមចេក តែពុំដែលបានហូបទេ ។ ឲ្យតែបានចាស់ល្មម គេកាប់យកទៅដាក់ការដ្ឋាន ។ ខ្ញុំធ្លាប់ហូបបានតែ ត្រាវ សាគូ ព្រោះអាចលួចបាន គឺអ៊ំខ្ញុំគាត់កាយយកតែមើមទុកដើមនៅដដែល ។ គិតទៅសម័យខ្មែរក្រហមសម្បូរចោរណាស់ ។ ចាស់ៗនិយាយថា របបនេះបង្រៀនមនុស្សឲ្យចេះធ្វើចោរ ។ សាកគិតលមើល បើគេចាប់បានត្រូវធ្វើទារុណកម្ម ដួនណាសម្លាប់ចោល ហេតុអ្វីក៏មនុស្សនៅតែហ៊ានលួច? នេះបញ្ជាក់ឲ្យឃើញថា លួចក៏ស្លាប់ មិនលួចក៏ស្លាប់ ។ ស្លាប់ព្រោះដាច់ពោះ បំណាច់នឹងស្លាប់ឲ្យបានហូបអ៊ីចឹងហើយ បុរាណ តែងពោលថា «ព្រោះចំណី ត្រូវក្ដីច្រើនក្ដាត់» ។

បើនិយាយពីផ្លែឈើវិញ ខ្ញុំធ្លាប់ហូបផ្លែប៉េងប៉ោះស្រោម ផ្លែសាវម៉ាវព្រៃ ផ្លែអារអូត (ដើមដុះតាមគុម្ពោតព្រៃតូច) គេច្រើនតែដាំនៅតាមរបង (ផ្លែជើងចាប) ដើមនេះច្រើនដុះនៅតាមរបងដែរ ផ្លែវាតូចៗប៉ុនគ្រាប់សណ្ដែក ឬធំជាងបន្តិច ដាចង្កោម ពេលទុំផ្លែវាមានពណ៌ក្រម៉ៅ ហើយមានរសជាតិផ្អែម ។ ក្រៅពីនេះនៅមានផ្លែស្នាយ ពេលទុំ ផ្លែវាមានពណ៌លឿង ហើយមានរសជាតិផ្អែម ។ បើផ្លែសាវម៉ាវព្រៃវិញ ផ្លែវាពេលទុំមានពណ៌លឿងដែរ ផ្លែវាប៉ុនមេដៃ មេជើង គេហូបសាច់ខាងក្នុងមានរសជាតិជូរអែម ។ រីឯផ្លែប៉េងប៉ោះស្រោមវិញ ពេលទុំសាច់ពណ៌ស្រអាប់ រសជាតិផ្អែមបែបភ្ញាវ ហូបច្រើនពុល ធ្វើឲ្យវិលមុខ ក្អួតចង្អោរ ។

**ល្បិច និងទណ្ឌកម្ម**

ខ្ញុំតែងតែឆ្ងល់ថា ហេតុអ្វីបានជាអ្នកចេះ ឲ្យអ្នកល្ងង់ចោកបាន? ចាប់យកទៅសម្លាប់ទាំងខ្សែៗ? ក្រោយមក ទើបខ្ញុំដឹងថា ខ្មែរក្រហមពូកែប្រើភាសាខ្មែរ ។ ការវិភាគអក្សរសិល្ប៍របស់លោក វ៉ាន់ឌីកាអុន លើការប្រើភាសាខ្មែរក្នុងរឿង «ធនញ្ជ័យ» បញ្ជាក់ឲ្យឃើញថា ធនញ្ជ័យ យកឈ្នះលើមនុស្សដ៏ច្រើននៅស្រុកខ្មែរ ក៏ព្រោះតែគាត់ចេះប្រើ និងបកស្រាយភាសាខ្មែរបានល្អ ។ យ៉ាងណាមិញ ខ្មែរក្រហម ក៏ប៉ុនប្រសពខាងប្រើភាសាខ្មែរនេះដែរ ។ សុភាសិតបុរាណខ្មែរឲ្យតម្លៃណាស់លើភាសាដូចជា «អណ្ដាតជាអាទិ៍កន្ទង ស្លាប់ផងរស់ផង ព្រោះអណ្ដាត, សំដីជាឯក លេខជាទោ, មនុស្សគេយកសម្ដី ដំរីគេយកភ្លុក ។ល ។ ប៉ុន្ដែ កូនខ្មែរពុំសូវចាប់អារម្មណ៍ វិភាគលើភាសាជាតិ ហើយក៏ពុំឲ្យតម្លៃលើភាសាខ្លួនដែរ បើកុំតែជាមុខវិជ្ជាក្នុងកម្មវិធី ប្រហែលពុំចេះអានផង ។ ផ្ទុយគិនិតមនុស្សភាគច្រើនឲ្យតម្លៃលើអ្នកចេះភាសាបរទេស ។ បើកូនខ្មែរកើតនៅស្រុកគេ អត់ចេះនិយាយភាសាខ្មែរ គេគិតថា ពុំមែនជារឿងអាក្រក់ទេ ហើយបែរជាសរសើរទៅវិញ ខុសពី យួន ចិន ចាម ។ នៅជាមួយឪពុកម្ដាយ ក្រុមគ្រួសាររបស់គេ គេនិយាយភាសាគេដល់នៅក្នុងសាលា គេប្រើភាសាខ្មែរ ។ អណិកជនខ្មែរនៅលើទឹកដីគេ ភាគច្រើននិយាយថា គ្មានពេលបង្រៀនកូន ។

ខ្មែរក្រហមមិនដែលប្រើពាក្យធ្វើទារុណកម្ម ឬសម្លាប់ទេ គឺគេប្រើពាក្យកសាង រៀនសូត្រ ហើយបើធ្ងន់ ទៅកាប់ឬស្សីនៅស្រុកលើ ។ គេប្រើពាក្យ «ស្នើ» ជំនួសពាក្យ «យក ឬហៅ» ។ កាលនោះខ្ញុំឆ្ងល់នឹងពាក្យចម្លែកៗដូចជា មិនបាច់ថ្លែង អ្នកឯងមានមាត់ហូបប៉ុន្មាន? អង្គការខុសសីលធម៌ ។ មានរឿងរ៉ាវច្រើនទាក់ទងនិងការប្រើពាក្យបង្កប់ដោយល្បិចនេះ ។ ខ្ញុំឮគេនិយាយថា ដើម្បីយកមនុស្សទៅអូសនង្គ័ល ខ្មែរក្រហមសួរថា «តើមានបងប្អូនណាធ្លាប់ធ្វើគោទេ?» មានច្រើននាក់ណាស់លើកដៃ ព្រោះគិតថា ខ្មែរក្រហមឲ្យទៅសម្លាប់គោ ។ ខ្លះទៀតគិតថា ខ្លួនពិតជាបានឆ្ងាញ់មាត់ហើយ ។ ពាក្យខ្មែរ «ធ្វើគោ, ធ្វើជ្រូក, ធ្វើត្រី គឺសម្លាប់នេះឯង» មានឯណា ខ្មែរក្រហមប្រើពាក្យនេះក្នុងន័យ «ធ្វើសត្វគោ គឺភ្ជួរស្រែនេះឯង» មានខុសឯណា ដូចសេដ្ឋីថា «ស្អីក៏ដោយឲ្យតែជ្រុះត្រូវរើស សេះដុះអាចម៍ក៏ «ជ្រុះ» អនញ្ជ័យរើសក៏មិនខុស ។

(តទៅលេខក្រោយ) **ផាន់ សុផល**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៈ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។




**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 209, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.